សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ តុលា ឆ្នាំ ២០២០

# លីអាហូណា



## មានរឿងបីយ៉ាងដែលយើងតែងតែអាចមានអំណរគុណដល់

ទំព័រ ១២

ការកំណត់ និងការដោះស្រាយការរំលោភបំពាន
ទំព័រ ៥, ១៨

ការស្វែងរកចម្លើយនៅក្នុងជំនាន់នៃការបោកបញ្ឆោត
ទំព័រ ២៤

របៀបដែលសាលជំនុំរបស់យើងជួយយើងនៅក្នុងការថ្វាយបង្គំរបស់យើង
ទំព័រ ៣៨

សាសនាចក្រ
នៅទីនេះ

# ប៊ូសាន
# កូរ៉េខាងត្បូង




រូបថតពី GETTY IMAGES

ប៊ូសានគឺជាកន្លែងដែលមានស្តេកមួយក្នុងចំណោមស្តេកទាំង ១២ នៅក្នុងប្រទេសកូរ៉េខាងត្បូង ។ ទីស្នាក់ការកណ្តាលនៃបេសកម្មមួយគឺនៅក្នុងប៊ូសាន ។ នេះគឺជាការពិតមួយចំនួនអំពីសាសនាចក្រនៅប្រទេសកូរ៉េខាងត្បូង ៖

សមាជិក — ៨៨,៤១៨

១២ — ស្តេក, ៥ មណ្ឌល, ៤ បេសកកម្ម

ក្រុមជំនុំ — ១០៣

១៨ — មជ្ឈមណ្ឌលពង្សប្រវត្តិ

ព្រះវិហារបរិសុទ្ធ ( សេអ៊ូល ) — ១

១៩៥៦ ពួកអ្នកផ្សព្វផ្សាយសាសនាជាផ្លូវការដំបូង

១៩៦៧ ព្រះគម្ពីរមរមនដែលត្រូវបានបោះពុម្ពជាភាសាកូរ៉េដំបូង

១៩៧៣ ស្តេកដំបូងបានបង្កើតឡើង

១៩៨៥ ព្រះវិហារបរិសុទ្ធសេអ៊ូលត្រូវបានឧទ្ទិសឆ្លង

១៩៩១ ព្រះគម្ពីរមរមនមួយលានក្បាលជាភាសាកូរ៉េ

២០២០ South Korean choir joins in video for final hymn in April general conference






ការងារបម្រើតាមរយៈកម្មវិធីកុមារ និងយុវវ័យ

៨







តើខ្ញុំអាចនិយាយទៅកាន់កូនៗរបស់ខ្ញុំអំពីភាពស្មើគ្នានៃភេទដោយរបៀបណា ?

១២



អម្ចតហេតុនៃការព្យាបាលតាមរយៈពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ

*រ៉េណា អ៊ី អាបើតូ*

១៨







ព្រះវរបិតា យើងសូមអរគុណព្រះអង្គ

*អែលឌើរ នែល អិល អាន់ឌើរសិន*

២៤


# ការការពារការរំលោភបំពាន

នៅក្នុងចំណាងទាក់ទងដ៏ល្អ មនុស្សសូមអភ័យទោសចំពោះពាក្យសម្ដី និងទង្វើមិនល្អ ហើយពឹងផ្អែកលើកម្លាំងដ៏ធួនរបស់ព្រះអង្គសង្គ្រោះ ដើម្បីជួយពួកគេឲ្យប្រសើរឡើង ហើយប្រែចិត្ត ។ ប៉ុន្តែនៅក្នុងស្ថានភាពដែលមិនល្អ មនុស្សបន្តប្រព្រឹត្តដោយមិនសប្បុរសចំពោះអ្នកផ្សេងទៀត ហើយចំណងទាក់ទងទាំងនោះអាចក្លាយជាការរំលោភបំពាន ។

ប្រធាន រ័សុល អិម ណិលសុន បានបង្រៀនថា « [ ការរំលោភបំពាន និង ] ទង្វើអាក្រក់ទាំងនេះ គ្មានកន្លែងនៅក្នុងនគរព្រះឡើយ » ( « ទ្រព្យសម្បត្តិខាងវិញ្ញាណ » សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៩ ) ។ អត្ថបទក្នុងទស្សនាវដ្ដីសាសនាចក្រមួយចំនួននៅក្នុងខែនេះ នឹងជួយយើងកំណត់ និងដោះស្រាយអំពីការរំលោភបំពាន ៖

- ក្នុងអត្ថបទរបស់ខ្ញុំនៅទំព័រ ១៨ ខ្ញុំនិយាយពីលក្ខណៈនៃការរំលោភបំពាន ហើយចង្អុលបង្ហាញធនធានមួយចំនួនដើម្បីជួយបងប្អូន ឬមនុស្សដែលបងប្អូនស្គាល់ ឲ្យស្គាល់ និងបានទទួលការព្យាបាលពីចំណងទាក់ទងដែលរំលោភបំពាន ។
- នៅទំព័រ ៥៨ យុវនារីម្នាក់ចែកចាយពីបទពិសោធន៍របស់នាងពីការដែលត្រូវបានរំលោភបំពានខាងផ្លូវភេទពេលនៅជាកុមារម្នាក់ និងអំពីរបៀបដែលនាងអាចស្វែងរកភាពក្លាហាន និងកម្លាំងដើម្បីនិយាយប្រាប់ និងស្វែងរកជំនួយពីមជ្ឈិមវ័យដែលនាងទុកចិត្ត ក៏ដូចជាពីព្រះអង្គសង្គ្រោះ ។
- ក្នុង *ប្រិយមិត្ត* ទំព័រ ខ១២ នៃខែនេះ បងប្អូនអាចរកឃើញសកម្មភាពសរសេរ ដើម្បីជួយពិភាក្សា « ការនិយាយទេ » ជាមួយកូនៗបងប្អូន ។ សូមពិចារណាលើការប្រើប្រាស់សកម្មភាពនេះ ជាមូលដ្ឋានសម្រាប់មេរៀនរាត្រីជួបជុំក្រុមគ្រួសារស្ដីអំពីការការពារការរំលោភបំពាន ។
- ការរំលោភបំពានខាងអារម្មណ៍ អាចបណ្ដាលឲ្យមានគ្រោះថ្នាក់ផងដែរ ការរំលោភបំពានប្រភេទផ្សេងទៀត។ សូមអាន “ការទទួលស្គាល់ ការរំលោភបំពានខាងអារម្មណ៍” នៅក្នុងការបោះពុម្ពឌីជីថល បញ្ហានេះដើម្បីរៀនពីសញ្ញាព្រមានចំនួន ៥ និង វិធីដើម្បីជួយ. ។

ប្រសិនបើបងប្អូនត្រូវបានបំពាន បងប្អូនអាចងាកទៅរកព្រះដើម្បីបានការណែនាំ និងការព្យាបាល ហើយស្វែងរកជំនួយពីបុគ្គលដែលបងប្អូនទុកចិត្តផងដែរ ។ ព្រះអម្ចាស់យល់ពីអារម្មណ៍របស់យើង ហើយទ្រង់នឹងដឹកនាំយើងទៅកាន់ទីសុវត្ថិភាព និងអំណរ ពេលយើងងាកទៅរកទ្រង់ ។

ចូរឲ្យយើងទាំងអស់គ្នាទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់នៃព្រះ ហើយទៅរកទ្រង់ជារៀងរាល់ថ្ងៃ


បណ្ឌិត ជេសិន ប៊ី វ៉េធិង

សាកលវិទ្យាល័យព្រិកហាំ យ៉ង់ សាលានៃជីវិតគ្រួសារ

# មាតិកា


៥ **ការយល់ដឹងពីការរំលោភបំពាន**

៦ **ការបង្ហាញអំពីសេចក្ដីជំនឿ**
សាគីអ៊ូសា និង សាទ្បូត មៃវីរីវី
គ្រួសារមៃវីរីវីរស់នៅដោយអំណរ និងគោលបំណងជារៀងរាល់ថ្ងៃ ថ្វីបើពួកគេមានកូនពីរនាក់បានស្លាប់ទៅក្ដី ។

៨ **គោលការណ៍នៃការងារបម្រើ**
ការងារបម្រើតាមរយៈកម្មវិធីកុមារ និងយុវវ័យ
បងប្អូនមិនចាំបាច់តែមានអាយុក្រោម ១៨ ឆ្នាំដើម្បីប្រើប្រាស់កម្មវិធីកុមារ និងយុវវ័យ ដើម្បីជួយបងប្អូនក្នុងកិច្ចខិតខំធ្វើការងារបម្រើរបស់បងប្អូននោះទេ ។

១២ **ពួកសាវក ចែកចាយសារនៃសេចក្ដីសង្ឃឹម**
របៀបដើម្បីនៅ ជាប់នឹងព្រះ ធ្វើការបម្រើក្នុងក្ដីស្រឡាញ់ និង បន្តឆ្ពោះទៅមុខដោយសេចក្ដីអំណត់ នៅក្នុងអំឡុងពេលនៃជំងឺរាតត្បាត ។

១៨ **ដួងចិត្តត្រូវបានចាក់ទម្លុះដោយរបួសដ៏ជ្រៅ ៖ ការយល់ដឹងពីការរំលោភបំពាននៅក្នុងគ្រួសារ**
*ដោយ ជេសិន ប៊ី វ៉ែធិង*
ស្គាល់ពីលំនាំប្រាំយ៉ាងនៃការរំលោភបំពាន ហើយស្វែងរកសេចក្ដីសង្ឃឹម និងការព្យាបាល ។

២៤ **ឈរលើសិលានៃវិវរណៈ**
*ដោយ អែលឌើរ លូវែន អ៊ី ខូប្រ៊ីតហ្គ*
ការស្វែងរកសេចក្ដីពិតចាប់ផ្ដើមពីការរកចម្លើយចំពោះសំណួរមូលដ្ឋានគ្រឹះទាំងឡាយ ។

៣០ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**
គ្រួសារមួយរកឃើញភាពសុខសាន្ត និងអំណរនៅក្នុងព្រះវិហារបរិសុទ្ធ ។ រូបផ្ដុំមួយផ្ដល់នូវការព្យាបាល ។ យុវជនម្នាក់ ទទួលឱកាស ជាលើកទីពរ ដើម្បីអានព្រះគម្ពីរមរមន ។ យុវជនម្នាក់បានយល់ពីគោលបំណងនៃបុណ្យជ្រមុជទឹករបស់គាត់ ។

៣៤ **ចូរមកតាមខ្ញុំ ៖ ព្រះគម្ពីរមរមន**
អត្ថបទប្រចាំសប្ដាហ៍ទាំងនេះអាចគាំទ្រដល់ការសិក្សាព្រះគម្ពីរមរមនរបស់បងប្អូននៅខែនេះ ។

៣៨ **សាលជំនុំ—កន្លែងនៃវិវរណៈ និងការថ្វាយបង្គំ**
*ដោយប៊ីស្សព ឌីន អិម ដេវីស*
សាលជំនុំរបស់បងប្អូនគឺជាកន្លែងពិសិដ្ឋមួយ ដែលអាចផ្ដល់ឱកាសជាច្រើនដើម្បីទទួលអារម្មណ៍ពីព្រះវិញ្ញាណកាន់តែខ្លាំងនៅក្នុងជីវិតបងប្អូន ។


ការអានខ្លីៗ

ការគាំទ្រ*ចូរមកតាមខ្ញុំ*



**នៅលើក្របមុខ**
រូបថតមកពី Getty Images ។

# វគ្គ


យុវមជ្ឈិមវ័យ
**៤៤**
ការញៀនអាចជាច្រវាក់មួយដែលទាញយើងឲ្យចុះក្រោម ។ យើងអាចរកឃើញសេរីភាព **កាលដែលយើងឈោងទៅព្រះអង្គសង្គ្រោះរបស់យើង** ដែលស្រឡាញ់យើង សូម្បីនៅក្នុងភាពកម្សោយ និងការលំបាករបស់យើង ។





យុវវ័យ
**៥២**
មិនថាបងប្អូនជួបការលំបាកនឹងការបម្រើប្រចាំថ្ងៃ ការជាសះស្បើយពីការរំលោភបំពាន សុខភាពផ្លូវចិត្ត ឬគ្រាន់តែជាការហៅឈ្មោះពេញលេញរបស់សាសនាចក្រក្ដី **បងប្អូនមិននៅតែឯងទេ ។**





កុមារ
*ប្រិយមិត្ត*
*រៀនអំពីជង្ហាយមួយភាគដប់ និងរបៀបដើម្បីជួយគ្រួសារបងប្អូនរស់នៅឲ្យកាន់តែរីករាយ ។*




## អត្ថបទមានតែឌីជីថលប៉ុណ្ណោះសម្រាប់ខែតុលា



**៣៧ វិធីខុសៗគ្នាដើម្បីសិក្សាព្រះគម្ពីរ**

*ដោយ ម៉ារីស្សា វីដឌីសុន*

ប្រសិនបើការអានមិនមែនជាអ្វីដែលបងប្អូនចូលចិត្ត ទេ សូមសាកល្បងសិក្សាដំណឹងល្អនៅក្នុងរបៀបមួយ ក្នុងចំណោមរបៀបទាំងនេះវិញ ។



**ការស្គាល់ពីការរំលោភបំពានខាងអារម្មណ៍**

*ដោយ ណាណាន់ ថាលី*

ទីប្រឹក្សាម្នាក់មកពីសេវាកម្មគ្រួសារចែកចាយអំពី របៀបដើម្បីស្គាល់ និងដោះស្រាយការរំលោភបំពាន ខាងអារម្មណ៍នៅក្នុងចំណងទាក់ទងរបស់បងប្អូន ។

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី Gospel Library និងនៅគេហទំព័រ liahona.ChurchofJesusChrist.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- មើលមាតិកាដែលមានតែឌីជីថលប៉ុណ្ណោះ ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬជាវដើម្បីផ្តល់ជាអំណោយ ។
- ពង្រីកការសិក្សាជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក ឬបោះពុម្ពអត្ថបទ ។
- ស្តាប់អត្ថបទដែលអ្នកចូលចិត្ត ។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

សូមផ្ញើសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ChurchofJesusChrist.org

សូមដាក់បញ្ជូនរឿងរបស់អ្នកនៅគេហទំព័រ liahona.ChurchofJesusChrist.org ឬផ្ញើសំបុត្រទៅកាន់ ៖

*Liahona*, flr. 23<br>
50 E. North Temple Street<br>
Salt Lake City, UT 84150-0023, USA

**ខែ តុលា ឆ្នាំ ២០២០ វ៉ុល ៤៤ លេខ ៥**
**លីអាហូណា ១៦៧២៥ ២៥៨**

ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌេល ជី រេនឡាន់, ជើរិត ដបុលយូ ហ្គង, អូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** រ៉ាន់ឌី ឌី ហ្វាំង

**អ្នកប្រឹក្សា ៖** ប៊ែកឃី ក្រាវិន, ស្ប៉ារ៉ុន អ៊ូបែង, គ្រីស្ទីណា ប៊ី ហ្វ្រានកូ, វ៉លធើរ ហ្វេស. ហ្គន់ហ្សាលេស, ឡារី អេស ខាឈើរ, ចេន អ៊ី ញូវមែន, អែគ្រោន អូឆៅ, ម៉ៃឃើល ធី រីងវូដ, វើន ភី ស្តេនហ្វីល

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន

**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយប៊ិហ្គ

**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន

**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ពផ្សាយ ៖** កាមីឡា ខាស្រ្ទីលលុន

**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ឌែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតរីត, ម៉ាធ្យូ ឌី ហ្វ្លីតុន, ហ្គារែត អេច ហ្គាហ្វ, អើរ៉ុន ចនស្តុន, ចន រ៉ាយអ៊ិន ជិនសិន, ឆាលឡូត ឡាកាបាល់, ម៉ៃឃល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ដុក, យ៉ូស្វេ ដេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឡូរី ហ្វូលើរ សូសា, ឆាកខែល វូដឡេ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដស៊ិន

**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន

**រចនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនធ្លី, ស៊ី ឃឹមបឹល បុត, ថូម៉ាស ឆាល, ចូស្វ៉ា ដេននីស ដេវីឌ ហ្វ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កុត អិម ម៉ូយ, អេលេនី រេហ្គីរ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, យេ នីកូល រ៉ែកយិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នៃ បេឃើ អាននី

**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** អាំមុន ហារីស

**ផលិតកម្ម ៖** អ៊ីរ៉ា ហ្គ្លែន អាឌៀ, ជូលី ប៊ីដេត, ហូសេ ឆាវេហ្ស, ថូម៉ាស ជី ខ្រូនីន, ប្រាយអែន ដបុលយូ ហ្គីជី, ជីននី ជេ នីលសុន, ម៉ារីសា អិម ស្មីធ

**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស

**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាឃើរ

សូមផ្ញើអត្ថបទ និង សំណួរនានាតាមអ៊ិនធឺរណេតនៅគេហទំព័រ liahona.ChurchofJesusChrist.org តាមអ៊ីម៉ែលទៅកាន់ liahona@ChurchofJesusChrist.org ឬ តាមសំបុត្រទៅកាន់ *Liahona,* flr.23, 50 E. North Temple St., Salt Lake City, UT 84150–0023, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាសែ្សល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។

© 2020 by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។

**For Readers in the United States and Canada:** October 2020 Vol. 19 No. 5. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.50 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.ChurchofJesusChrist.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



# ការយល់ដឹងពីការរំលោភបំពាន

ខណៈពេលដែលយើងថា មនុស្សគ្រប់គ្នានឹងទទួលបានការប្រព្រឹត្តចំពោះគ្នាដោយមានការគោរព នោះ មនុស្សមួយចំនួនព្យាយាមធ្វើឲ្យគេឈឺចាប់ គ្រប់គ្រង ឬចាត់ចែងលើអ្នកដទៃទៅវិញ ។ ឥរិយាបទ គ្រោះថ្នាក់បែបនោះត្រូវបានចាត់ទុកថាជា ការរំលោភបំពាន ។ វាផ្ទុយពីដំណឹងល្អនៃព្រះយេស៊ូវ គ្រីស្ទ ដែលបង្រៀនយើងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយត្រូវប្រព្រឹត្តចំពោះអ្នកដទៃដូចជាយើងចង់ឲ្យគេប្រព្រឹត្តចំពោះខ្លួនដែរ ( សូមមើល ម៉ាថាយ ៧:១២; យ៉ូហាន ១៣:៣៤; គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:៣៦–៣៧ ) ។

**ការរំលោភបំពានមានសញ្ញាទូទៅមួយចំនួន ។ នេះគឺជាចំណុចប្រាំយ៉ាង ដើម្បីជាការប្រុងប្រយ័ត្នជៀសវាង ឬ បញ្ឈប់ការរំលោភបំពាននេះ ៖**



**ជនរងគ្រោះតែងតែត្រូវបានរំលោភបំពានដោយជនដែលពួកគេបានស្គាល់ ។**

ជនល្មើសអាចជាសាច់ញាតិ ឬ នរណាម្នាក់ដែលពួកគេធ្លាប់ជួបពីមុនមក ។ នេះមិនមែនចង់បង្ហាញថាយើងគួរតែព្រួយបារម្ភចំពោះមនុស្សគ្រប់គ្នាដែលយើងស្គាល់នោះទេ ប៉ុន្តែ យើងអាចប្រុងប្រយ័ត្ន—ហើយបង្រៀនកូនចៅរបស់យើងឲ្យប្រុងប្រយ័ត្ន—ចំពោះសញ្ញាទាំងបួនទៀតនេះ ។

**ជាញឹកញាប់ ជនល្មើសស្វែងរកជនដែលងាយរងគ្រោះ ។**

ជនល្មើសស្វែងរកអ្នកដែលមិនអាចធ្វើការសម្រេចចិត្ត ឬ ការពារខ្លួនឯងបាន ។

**ជាញឹកញាប់ ជនល្មើសព្យាយាមធ្វើឲ្យជនរងគ្រោះនៅឆ្ងាយដាច់ដោយឡែកពីគេ ។**

ការធ្វើឲ្យនៅឆ្ងាយដាច់ដោយឡែកពីគេ ឬការគំរាមកំហែង គឺជនល្មើសព្យាយាមធ្វើឲ្យជនរងគ្រោះមិនអាចស្វែងរកជំនួយបាន ។

**ជាញឹកញាប់ ជនល្មើសចាប់ផ្ដើមដោយការរំលោភលើព្រំដែន ។**

ការរំលោភបំពានកើតឡើង នៅពេលមានការបំពានយ៉ាងធ្ងន់ធ្ងរទៅលើដែនកំណត់នៃឥរិយាបទ និងភាសាសមរម្យចំពោះអ្នកដទៃ ។ ជនល្មើសអាចមិនខ្វល់ខ្វាយនឹងដែនកំណត់ ឬ ចាប់ផ្ដើមធ្វើការបំពានតិចតួច ដើម្បីធ្វើឲ្យជនរងគ្រោះអស់សង្ឃឹម ។

**ជនល្មើសអាចព្យាយាមធ្វើឲ្យមានទំនុកចិត្តបន្តិចម្ដងៗពីមុនមានការរំលោភបំពាន ។**

ការធ្វើបែបនេះហៅថា « សម្អិតសម្អាង » ហើយជាញឹកញាប់កើតឡើងចំពោះយុវវ័យ និងកុមារ ។ ឥរិយាបទសម្អិតសម្អាងអាចរួមទាំងការសុំមានពេលវេលាដាច់ដោយឡែកមួយ ការលើកទឹកចិត្តឲ្យមានភាពសម្ងាត់ ការនិយាយពីប្រធានបទផ្លូវភេទ ឬ ការបង្ហាញរូបភាពអាសគ្រោម ឬការផ្ដួចផ្ដើមទំនាក់ទំនងខាងរូបកាយជាមួយកុមារ ។

រូបភាពគូរដោយ ដៀល រ៉ៃ រូបភាពផ្សេងទៀតមកពី រូបភាព ហ្គិតធី





# សាគីអ៊ូសា និង សាឡូត មៃរីវីរី

*ទីក្រុងសូវ៉ា កោះហ្វីជី*



*ខ្ញុំស្ទើរមិនជឿពីសេចក្ដីសុខសាន្ត និងសុភមង្គលដែលខ្ញុំបានឃើញនៅក្នុងគ្រួសារមៃរីវីរី ។ ពួកគេរស់នៅដោយអំណរ និងគោលបំណងជារៀងរាល់ថ្ងៃ ថ្វីបើមានកូនពីរនាក់បានស្លាប់ទៅហើយក្ដី ។*

**ឡេសលី នីលសុន ជាងថតរូប**

**សាឡូត ៖**

ពីរឆ្នាំក្រោយពីកូនប្រុសយើង អ៊ីសា បានស្លាប់ដោយសារមហារីកថ្លើម កូនស្រីយើង អ៊ីសាលីន បានស្លាប់ដោយសារជំងឺរលាកស្រោមខួរ ។ នៅក្នុងព្រះវិហារបរិសុទ្ធ ខ្ញុំបានទទួលការបំផុសដ៏ខ្លាំងឲ្យនិយាយជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាចំណាស់ជាស៊ីស្ទើរម្នាក់ ដែលបានបាត់បង់កូនពីរនាក់ប៉ុន្មានឆ្នាំមុននេះ ។ គាត់បានប្រាប់ខ្ញុំថា « បើប្អូនធ្វើឲ្យគេហដ្ឋានរបស់ប្អូនជាទីបរិសុទ្ធមួយ នោះប្អូនអាចមានអារម្មណ៍នៃវត្តមានរបស់កូនៗប្អូននៅទីនោះ » ។

ការណ៍នោះបានក្លាយជាគោលដៅរបស់យើង ។ អ្វីៗគ្រប់យ៉ាងដែលយើងធ្វើ គឺដើម្បីធ្វើឲ្យគេហដ្ឋានរបស់យើងជាទីបរិសុទ្ធមួយ ។ យើងចង់មានអារម្មណ៍ថាពួកគេនៅក្បែរយើង ។

**សាគីអ៊ូសា ៖**

បទពិសោធន៍នៃការបាត់បង់អ៊ីសា និង អ៊ីសាលីនទីបំផុតបាននាំឲ្យគ្រួសារយើងកាន់តែមានភាពជិតស្និតនឹងគ្នា ។ យើងប្រឹក្សាជាមួយគ្នានឹងកូនៗយើងផ្សេងទៀត ។ យើងចូលរួមនៅព្រះវិហារបរិសុទ្ធជាមួយគ្នាជាក្រុមគ្រួសារ ។ យើងរស់នៅសាមញ្ញបំផុតតាមដែលអាចធ្វើទៅបាន ហើយជ្រើសរើសការដឹងគុណជារៀងរាល់ថ្ងៃ ។ ពេលយើងនិយាយអំពីអត្ថន័យនៃការបានផ្សារភ្ជាប់ជាគ្រួសារនៅក្នុងព្រះវិហារបរិសុទ្ធ ការផ្សារភ្ជាប់នោះក្លាយជារស់រវើកចំពោះយើង ។ ហើយតាមរយៈការណ៍ទាំងអស់នេះ យើង*ពិតជា*មានអារម្មណ៍នៃវត្តមានរបស់កូនៗយើង ។

**ស្វែងរកបន្ថែម**

សូមមើលបន្ថែមទៀតអំពីដំណើរនៃសេចក្ដីជំនឿរបស់សាគីអ៊ូសា និង សាឡូត រួមទាំងរូបថតជាច្រើនបន្ថែមទៀត នៅក្នុងកំណែនៃអត្ថបទនេះនៅលើអ៊ិនធើរណែត ឬ *Gospel Library* នៅគេហទំព័រ **ChurchofJesusChrist.org/go/10206** ។

អែលឌើរ រ៉ូណាល អេ រ៉ាសបានចែកចាយពីរបៀបដែលយើងអាចពង្រឹងគេហដ្ឋានយើងឲ្យក្លាយជាទីកន្លែងនៃសេចក្ដីស្រឡាញ់ និងការការពារខាងវិញ្ញាណ នៅគេហទំព័រ **ChurchofJesusChrist.org/go/10207** ។

# គោលការណ៍នៃការងារបម្រើ

# ការងារបម្រើតាមរយៈ **កម្មវិធីកុមារ និងយុវវ័យ**

*ការអញ្ជើញអ្នកផ្សេងទៀតឲ្យលូតលាស់ និងការជួយពួកគេនៅតាមផ្លូវ គឺសំខាន់ណាស់នៅក្នុងការងារបម្រើ ។*

ឱកាសជាច្រើនសម្រាប់ការផ្ដល់ការងារបម្រើតាមរយៈកម្មវិធីកុមារ និងយុវវ័យ ។ ប្រហែលជាបងប្អូនមានកូនៗជាកុមារ ឬជាយុវវ័យរបស់បងប្អូនផ្ទាល់នៅផ្ទះ ។ ប្រហែលជាបងប្អូនជាអ្នកដឹកនាំម្នាក់នៅក្នុងកម្មវិធីនោះ ឬបងប្អូនផ្ដល់ការងារបម្រើដល់គ្រួសារដែលមានក្មេងតូចៗ និងយុវវ័យ ។ ឬប្រហែលជាបងប្អូន*ស្គាល់*កុមារ និងយុវវ័យមួយចំនួន ( សរុបទៅគឺស្ទើរតែយើងទាំងអស់គ្នា ) ។ មិនថាស្ថានភាពរបស់បងប្អូនបែបណានោះទេ មានរបៀបជាច្រើនក្នុងការប្រើប្រាស់កម្មវិធីនេះ ឬគោលការណ៍របស់វាដើម្បីផ្ដល់ពរជ័យដល់ជីវិតរបស់មនុស្សដទៃទៀត ។

**ការអភិវឌ្ឍខ្លួនយើងជាមួយគ្នា**

ចំនុចសំខាន់នៃកម្មវិធីកុមារ និងយុវវ័យ គឺផ្ដោតទៅលើការព្យាយាមជារៀងរាល់ថ្ងៃ ដើម្បីក្លាយឲ្យកាន់តែដូចជាព្រះអង្គសង្គ្រោះ ដែលបានផ្ដល់ការងារបម្រើយ៉ាងល្អឥតខ្ចោះ ។ មនុស្សជាច្រើនក្នុងចំណោមពួកអ្នកដែលបានចូលរួមក្នុងកម្មវិធីនេះបានរៀនថា បងប្អូនកាន់តែរីកចម្រើនក្នុងចំណុចនានាក្នុងជីវិតរបស់បងប្អូនច្រើនប៉ុណ្ណា នោះបងប្អូនត្រូវបានរៀបចំកាន់តែប្រសើរឡើងប៉ុណ្ណោះដែរ ដើម្បីជួយ ឬផ្ដល់ការងារបម្រើដល់អ្នកដទៃទៀត ។

ប៉ុន្តែជាមួយនឹងកម្មវិធីកុមារ និងយុវវ័យ ការផ្ដល់ពរជ័យដល់មនុស្សដទៃទៀត ពុំចាំបាច់ចាំទាល់តែបងប្អូនបានរៀនអ្វីមួយហើយនោះទេ ។ ទង្វើនៃការរៀនសូត្រផ្ទាល់ផ្ដល់នូវឱកាសទាំងឡាយដើម្បីផ្ដល់ការងារបម្រើ ។

សម្រាប់យុវជនម្នាក់ឈ្មោះប្រូហ្វិត រស់នៅប្រទេសហ្គាណា ដែលដាក់គោលដៅនៅក្នុងកម្មវិធីកុមារ និងយុវវ័យ ដើម្បីរៀនពីរបៀបលេងព្យាណូ គឺគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ ប្រូហ្វិតនិយាយថា « វាជាគោលដៅរបស់ខ្ញុំផងដែរ ដើម្បីជួយមនុស្សដទៃទៀតឲ្យដឹងពីអ្វីដែលខ្ញុំកំពុងរៀន » ។

ទោះបីជាគាត់មិនទាន់ជាគ្រូបង្រៀននៅឡើយ ក៏គោលដៅរបស់គាត់បានលូតលាស់ជាអ្វីមួយដែលកាន់តែធំជាងការដែលគាត់បានស្រមៃចទៅហើយ ។ ឥឡូវនេះមានសិស្ស ៥០នាក់កំពុងរៀនព្យា



រូបថតដោយ ចង ហ្គាន់

ណូនៅសាលជំនុំជាមួយនឹងប្រូហ្វីតដែរ ។ ហើយនរណាកំពុងបង្រៀនប្រូហ្វីត និង សិស្ស ៥០នាក់នោះ ? អាឡិចសាន់ឌឺ អិម និង ខេវិន អិម ទាំងពីរនាក់អាយុ ១៣ ឆ្នាំ ។ ខេវិននិយាយថា « យើងចង់បង្ហាញទង្វើសប្បុរសដល់មនុស្សដទៃទៀត » ។

បីថ្ងៃក្នុងមួយសប្ដាហ៍ យុវជនទាំងពីរនាក់នេះបង្រៀនមេរៀនព្យាណូជាមូលដ្ឋានចាំបាច់ដោយឥតគិតថ្លៃដល់អ្នកទាំងអស់ណាដែលមករៀន ។ វាមាននូវអត្ថប្រយោជន៍បន្ថែមលើមេរៀនព្យាណូនោះ ។ សិស្សមួយចំនួនដែលត្រូវបានណែនាំឲ្យស្គាល់សាសនាចក្រតាមរយៈមេរៀនព្យាណូ ក្រោយមកបានសិក្សាដំណឹងល្អ ហើយបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។

កាលដែលយើងខិតខំអភិវឌ្ឍខ្លួនយើង នោះយើងអាចផ្ដល់ការងារបម្រើដល់មនុស្សដទៃទៀតដោយការអញ្ជើញពួកគេឲ្យចូលរួមនឹងយើង ។





រូបថតដោយ អ៊ីសាក ដាកូ-អាឈែមផុង



រូបថតដោយ អាឡិចសាន់ឌឺ យេ បូថេង



រូបថតដោយ ចូណាស រេប៊ីកតី

**រូបមន្តដ៏ជោគជ័យមួយសម្រាប់ការងារបម្រើ**

ពេលដែល សាប្រ៊ីណា ស៊ីមួយស៍ ដេអ៊្វូស អ័រហ្គូស្តូ នៅទីក្រុងឃើរីទីបា ប្រទេសប្រេស៊ីល ជាប្រធានអង្គការបឋមសិក្សាប្រចាំស្តេកម្នាក់បានមើលឃើញពីរបៀបដែលទស្សនៈវិស័យនៃការអភិវឌ្ឍផ្ទាល់ខ្លួនរបស់កម្មវិធីផ្តល់ពរជ័យដល់កុមារ និងយុវវ័យនៅក្នុងស្តេករបស់គាត់ ។ ប៉ុន្តែគាត់ក៏បានឃើញរបៀបជាច្រើនទៀត ដើម្បីប្រើប្រាស់នូវអ្វីដែលគាត់បានរៀនអំពីការអភិវឌ្ឍផ្ទាល់ខ្លួននៅក្នុងការចាត់តាំងរបស់គាត់ ក្នុងនាមជាបងប្អូនស្ត្រីដែលផ្តល់ការងារបម្រើម្នាក់ផងដែរ ។

ស៊ីស្ទើអ័រហ្គូស្តូយាយថា « ពេលខ្ញុំអភិវឌ្ឍទេពកោសល្យមួយ ខ្ញុំអាចប្រើប្រាស់ទេពកោសល្យនោះដើម្បីផ្តល់ពរជ័យដល់មនុស្សម្នាក់ដែលខ្ញុំផ្តល់ការងារបម្រើ » ។

ស៊ីស្ទើអ័រហ្គូស្តូនបង្រៀនប្អូនស្រីម្នាក់ក្នុងចំណោមបងប្អូនស្រីដែលគាត់ត្រូវបានចាត់តាំងឲ្យ បម្រើអំពីរបៀបធ្វើនំសូកូឡា ។ ឥឡូវនេះ ប្អូនស្រីនោះធ្វើ និងលក់នំដើម្បីជួយរកចំណូលបន្ថែមដល់គ្រួសារគាត់ ។ ស៊ីស្ទើរអ័រហ្គូស្តូននិយាយថា « ប៉ុន្មានខែក្រោយមក ខ្ញុំត្រូវបានប្រទានពរ ពេលដែលប្អូនស្រីម្នាក់ទៀតបានបង្រៀនខ្ញុំឲ្យធ្វើនំប៉ុងទឹកឃ្មុំដែលខ្ញុំអាចលក់បាន » ។ « ការអភិវឌ្ឍ
និងការចែកចាយទេពកោសល្យរបស់យើង អាចផ្តល់ពរដល់ជីវិតគ្នាទៅវិញទៅមក និងពង្រឹងដល់ចំណងទាក់ទងរបស់យើង នៅក្នុងនាមជាបងប្អូនស្រីដែលផ្តល់ការងារបម្រើ » ។ ■



## តើកម្មវិធីកុមារ និងយុវវ័យ ជួយដល់បងប្អូនឲ្យផ្តល់ការងារបម្រើដោយរបៀបណា ?

១. **អញ្ជើញមនុស្សដទៃទៀតឲ្យចូលរួមក្នុងកម្មវិធីកុមារ និងយុវវ័យ ។**
បងប្អូនអាចអញ្ជើញគ្រួសាររបស់យុវវ័យ និងកុមារដែលបងប្អូនផ្តល់ការងារបម្រើដល់ ដើម្បីឲ្យចូលរួមក្នុងកម្មវិធីកុមារ និងយុវវ័យ ។ ពួកគេអាចនឹងចាប់អារម្មណ៍នៅក្នុងការចូលរួមក្នុងសកម្មភាពទាំងឡាយ ការអភិវឌ្ឍផ្ទាល់ខ្លួន ឬថែមទាំងទស្សនៈវិស័យនៃការសិក្សាដំណឹងល្អរបស់កម្មវិធីនោះទៀតផង ។ ( សម្រាប់ព័ត៌មានបន្ថែមអំពីការផ្តល់ការងារបម្រើតាមរយៈ *ចូរមកតាមខ្ញុំ* សូមមើល « ការងារបម្រើតាមរយៈ *ចូរមកតាមខ្ញុំ* » នៅក្នុងខែ កញ្ញា ឆ្នាំ ២០២០ *លីអាហូណា* ។ )

២. **គាំទ្រដល់គោលដៅរបស់ពួកគេ ។**
ក្នុងនាមជាបងប្អូនប្រុស ឬស្រីដែលផ្តល់ការងារបម្រើដល់គ្រួសារទាំងឡាយដែលមានយុវវ័យ បងប្អូនមានមុខងារដើម្បីគាំទ្រដល់គោលដៅដែលពួកគេអាចកំពុងធ្វើនៅក្នុងកម្មវិធីកុមារ និងយុវវ័យ ។ ខណៈដែលគោលដៅរបស់ពួកគេគឺជារឿងផ្ទាល់ខ្លួន បងប្អូនអាចផ្តល់ជំនួយក្នុងរបៀបផ្សេងៗ ប្រសិនបើបងប្អូនដឹងពីអ្វីដែលពួកគេចាប់អារម្មណ៍ ។ ការណ៍នេះអាចជាទម្រង់នៃការស្វែងរកគ្រឿងសិល្បៈដែលពួកគេកំពុងស្វែងរក
ការធ្វើជាអ្នកដាក់ពិន្ទុសម្រាប់ការធ្វើនំឃុកឃីរបស់ពួកគេ ឬធ្វើជាអ្នកណែនាំក្នុងផ្នែកដែលបងប្អូនមានការចេះដឹង ។ តើបងប្អូនចេះប្តូរប្រេងម៉ាស៊ីនឡានទេ ? ប៉ះសំលៀកបំពាក់ដែលរហែក ? តើបងប្អូនជាអ្នកជំនាញក្នុងការសម្អាតសម្រាប់ការងារដែរឬទេ ? បងប្អូនអាចសូមផ្តល់ការចែកចាយចំណេះដឹង ឬជំនាញដែលបងប្អូនមាន ប្រសិនបើពួកគេចាប់អារម្មណ៍ ។

៣. **អញ្ជើញមនុស្សដទៃឲ្យចូលរួមធ្វើជាផ្នែកមួយនៃការអភិវឌ្ឍផ្ទាល់ខ្លួនរបស់បងប្អូន ។**
ការអភិវឌ្ឍផ្ទាល់ខ្លួនពុំគ្រាន់តែសម្រាប់កុមារ និងយុវវ័យប៉ុណ្ណោះទេ ។ បងប្អូនអាចចូលរួមនៅក្នុងកម្មវិធីនោះខ្លួនឯងមិនថាបងប្អូនមានអាយុប៉ុន្មាននោះទេ ។ ពេលបងប្អូនចំណាយពេលអភិវឌ្ឍផ្នែកខាងវិញ្ញាណ សង្គម រាងកាយ និងប្រាជ្ញា នៃជីវិតរបស់បងប្អូន នោះបងប្អូននឹងត្រូវបានរៀបចំកាន់តែប្រសើរឡើង ដើម្បីផ្តល់ការងារបម្រើដល់បុគ្គលម្នាក់ៗ មិនថានរណាដែលបងប្អូនជួបនោះឡើយ ។ ហើយដូចជាប្រ្ញហ្វីតនៅប្រទេសហ្កាណាដែរ បងប្អូនអាចផ្តល់ពរដល់មនុស្សដទៃទៀត ដោយការអញ្ជើញពួកគេឲ្យចូលរួមជាមួយបងប្អូន មិនថាជាមេរៀនព្យាណូដែលបានរៀបចំ ការទៅហាត់ប្រាណ ឬការរៀនភាសាមួយជាមួយគ្នាឡើយ ។

៤. **ការដាក់ការងារបម្រើជាគោលដៅមួយ ។**
សូមពិចារណាពីការចំណាយពេលរាល់ថ្ងៃដើម្បីផ្តល់ការងារបម្រើ ។ វាអាចជាការផ្ញើសារមួយ ឬការទៅលេងដើម្បីដឹងពីសុខទុក្ខ ឬដើម្បីរៀបចំការជួបជុំមួយ ។ វាអាចរួមមានការយកពេលទៅកត់ថ្ងៃកំណើតរបស់ពួកអ្នកដែលបងប្អូនផ្តល់ការងារបម្រើដល់ ឬតាមដានពួកគេនៅលើបណ្តាញសង្គមដើម្បីដឹងពីអ្វីដែលពួកគេចាប់អារម្មណ៍ ឬអ្វីដែលពួកគេបានកំពុងធ្វើថ្មីៗនេះ ។ សូម្បីតែការយកពេលតែប្រាំនាទីដើម្បីគិតអំពីអ្វី ដែលនរណាម្នាក់ផ្សេងទៀតត្រូវការ អាចដឹកនាំទៅកាន់គំនិតដ៏បំផុសដែលអាចធ្វើឲ្យមានការផ្លាស់ប្តូរមួយ ។



### ម្តងម្នាក់ៗ

« សញ្ញាសម្គាល់នៃសាសនាចក្រពិត និងសកម្មរបស់ព្រះអម្ចាស់ជានិច្ចកាល នឹងត្រូវបានរៀបចំ បានដឹកនាំការខិតខំទៅរកការបម្រើដល់បុត្រាបុត្រីរបស់ព្រះ និងក្រុមគ្រួសាររបស់ពួកគេម្នាក់ៗ ។ ដោយសារនេះគឺជាសាសនាចក្ររបស់ទ្រង់ នោះពួកយើងក្នុងនាមជាអ្នកបម្រើរបស់ទ្រង់នឹងផ្តល់ការងារបម្រើដល់មនុស្សម្នាក់ៗដូចជាទ្រង់បានធ្វើ » ។

ប្រធាន រ័សុល អិម ណិលសុន « ការងារបម្រើដោយព្រះចេស្តា និងសិទ្ធិអំណាចពីព្រះ » ***Liahona*** ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៦៩ ។

### សូមចែកចាយបទពិសោធន៍របស់បងប្អូន

សូមផ្ញើមកកាន់យើងនូវបទពិសោធន៍របស់បងប្អូនអំពីការងារបម្រើដល់មនុស្សដទៃ ឬទទួលបានការងារបម្រើ ។ សូមទៅកាន់ liahona.ChurchofJesusChrist.org ហើយចុចលើ « Submit an Article or Feedback » ។

# ពួកសាវកចែកចាយ

# សារនៃសេចក្ដីសង្ឃឹម

ជាការឆ្លើយតបទៅនឹងការរីករាលដាលពាសពេញពិភពលោក អាជ្ញាធរបានដាក់ការហាមប្រាមការជួបគ្នាជាសាធារណៈ និងការអនុវត្តការនៅដោយឡែកពីគ្នា ។ សាលាត្រូវបិទ អ្នកដឹកនាំសាសនាបានលុបចោលការប្រជុំនៅតាមព្រះវិហារ និងអ្នកដែលធ្វើដំណើរនៅខាងក្រៅត្រូវពាក់ម៉ាស់មុខដើម្បីការពារ ។

ឆ្នាំនោះគឺ ១៩១៩ ហើយការរាតត្បាតជំងឺគ្រុនផ្ដាសសាយដែលរីកដុសដាលបានចាប់ផ្ដើមពីមួយឆ្នាំមុនដែលធ្វើឲ្យមនុស្សរាប់សិបលាននាក់បានបាត់បង់ជីវិត ។[១] ព្យាការីថ្មីរបស់សាសនាចក្រ ប្រធាន ហឺបើរ ចេ ក្រាន្ត ( ១៨៥៦–១៩៤៥ ) ត្រូវបានញែកចេញនៅខែវិច្ឆិកា ឆ្នាំ១៩១៨ ប៉ុន្តែអត់បានគាំទ្ររហូតដល់ខែមិថុនា ឆ្នាំ១៩១៩ ដោយសារតែសន្និសីទទូទៅខែមេសាត្រូវបានពន្យារពេល ។

នៅក្នុងអំឡុងពេលនៃកិច្ចបម្រើរបស់លោកបន្ទាប់ពីថ្ងៃដ៏លំបាកទាំងនោះ ប្រធាន ក្រាន្ត បានផ្ដល់ការប្រឹក្សាដែលត្រូវនឹងសម័យកាលរបស់យើង នៅពេលដែលលោកបានមានប្រសាសន៍ថា « យើងមកលើផែនដីនេះដើម្បីទទួលបានចំណេះដឹងប្រាជ្ញា និងបទពិសោធន៍ ដើម្បីរៀនមេរៀនទាំងឡាយ រងទុក្ខលំបាក ស៊ូទ្រាំនឹងការល្បួង ហើយទទួលបាននូវជ័យជំនះនៃជីវិតរមែងស្លាប់ » ។ តាមរយៈចំណេះដឹងដែលលោកទទួលបានតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន លោកបានបន្ថែមថា « ខ្ញុំ . . . ដឹងថា នៅគ្រាលំបាកវេទនា ពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានលួងលោម និងប្រទានពរ ហើយធូរស្រាលចិត្តដែលគ្មានមនុស្សផ្សេងទៀតទេបានទទួល ! »[២]

នៅក្នុង « ភាពដ៏លំបាករបស់យើង » បច្ចុប្បន្ន ជាមួយនឹងវីរុស កូវីណា យើងទាញយកការលួងលោម និងការធូរស្រាលចិត្តពីដំណឹងល្អដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ចំណេះដឹងរបស់យើងដែលថាព្រះវរបិតាសួគ៌ស្រឡាញ់បុត្រាបុត្រីរបស់ទ្រង់ ហើយថាទ្រង់បានហៅពួកព្យាការី និងពួកសាវកនៅក្នុងសម័យរបស់យើងដើម្បីដឹកនាំយើងឆ្លងកាត់ព្យុះនៃជីវិតរមែងស្លាប់ គឺជាពរដ៏អស្ចារ្យ ។



*ថ្នាក់ដឹកនាំសាសនាផ្ដល់ការយល់ដឹងអំពីការនៅជិតព្រះ ការងារបម្រើដោយសេចក្ដីស្រឡាញ់ និងការឆ្ពោះទៅមុខដោយអត់ធ្មត់ក្នុងពេលមានជំងឺរាតត្បាត ។*



រូបថតមកពី Getty Images

*ការបិទព្រះវិហារបរិសុទ្ធ « ផ្ដល់ឱកាសដ៏អស្ចារ្យដើម្បីរៀនបន្ថែមទៀតអំពីការស្រាវជ្រាវពង្សប្រវត្តិ ការធ្វើលិបិក្រម និងវិធីដើម្បីរៀបចំឈ្មោះជាច្រើនសម្រាប់ថ្ងៃដែលទ្វារព្រះវិហារបរិសុទ្ធបើកម្ដងទៀត » ។*

*—អែលឌើរ ដេវីដ អេ បែដណា*

ចេញពីការប្រឹក្សាដែលបានចែកចាយនៅក្នុងបទសម្ភាសន៍ថ្មីៗនេះ សមាជិកមួយចំនួននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់រម្លឹកយើងថា យើងអាចមានអារម្មណ៍នៃអំណរ ហើយទន្ទឹងមើលអនាគតដោយក្ដីសង្ឃឹម ដោយមិនគិតពីអ្វីដែលកំពុងកើតឡើងនៅជុំវិញខ្លួនរបស់យើង ។[៣]

**កិច្ចការឆ្ពោះទៅមុខ**

អែលឌើរ ប្រ៊ូស អ័រ ម៉ាកខនឃី ( ១៩១៥–៨៥ ) មានពេលមួយបានប្រៀបប្រដូចសាសនាចក្រទៅនឹង « រទេះដ៏អស្ចារ្យមួយ » ដែលឆ្ពោះទៅមុខទោះបីជាមានឧបសគ្គក៏ដោយ ។[៤] អែលឌើរ ដេវីដ អេ បែដណា បញ្ជាក់ពីសន្ទុះទៅមុខឥតឈប់ឈររបស់រទេះទៅនឹងការរៀបចំដ៏បំផុសគំនិតរបស់សាសនាចក្រ និងក្នុងប្រវត្តិសាស្ត្ររបស់វាជាមួយភាពមិនអនុគ្រោះ ។

លោកបានមានប្រសាសន៍ថា « គ្មានដៃណាអាចបញ្ឈប់ការងារនេះពីការរីកចម្រើនបានទេ »[៥] ហើយគ្មានរោគរាតត្បាតណាមួយអាចបញ្ឈប់ការងារនេះពីការរីកចម្រើនបានឡើយ ។ « នៅកណ្ដាលបញ្ហាទាំងអស់ដែលយើងកំពុងប្រឈមមុខជាមួយវីរុសនេះ កិច្ចការនេះនៅឆ្ពោះទៅមុខ ។ . . . យើងពុំដឹងថាតើវានឹងចំណាយពេលប៉ុន្មាននោះទេ ប៉ុន្តែយើងនឹងយកឈ្នះ ។ ហើយយើងប្រហែលជាមិនបន្តលំនាំជីវិតចាស់របស់យើងដូចយើងបានដឹងពីមុននោះទេ ប៉ុន្តែការសម្របខ្លួន និងការផ្លាស់ប្ដូរទាំងនោះនឹងមានលក្ខណៈវិជ្ជមាន » ។

អែលឌើរ ឃ្វីនថិន អិល ឃុក បានមានប្រសាសន៍ថាការរៀបចំប្រកបដោយការបំផុសគំនិតរបស់សាសនាចក្ររួមមានគំរូទាន់ពេលវេលាដូចជាការសង្កត់ធ្ងន់ទៅលើការប្រជុំថ្ងៃឈប់សម្រាក ការពង្រឹងដល់កូរ៉ុមបព្វជិតភាពមិលគីស្សាដែកនិងសមាគមសង្គ្រោះ ការផ្លាស់ប្ដូរការងារបម្រើ និងការណែនាំនៃ *ចូរមកតាមខ្ញុំ* រីដេអូរបស់ព្រះគម្ពីរមរមន ព្រមទាំងកម្មវិធីកុមារ និងយុវវ័យ ។

លោកបានមានប្រសាសន៍ថា « យើងនឹងក្រឡេកមើលរឿងនេះថាជាពេលវេលាគ្រឹះមួយនៃការរៀបចំ ហើយមិនមែនគ្រាន់តែជាអ្វីដែលយើងត្រូវស៊ូទ្រាំប៉ុណ្ណោះទេ » ។

ប្រធាន អិម រ័សុល បាឡឺដ ដែលជាប្រធានស្ដីទីនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក៏យល់ស្រប ។ ទោះបីជាមានការបិទព្រះវិហារបរិសុទ្ធ និងសាលជំនុំបណ្ដោះអាសន្ន ក៏សមាជិកនៃសាសនាចក្រមានឧបករណ៍ខាងវិញ្ញាណដែលពួកគេត្រូវការដើម្បីដើរឆ្ពោះទៅមុខ ។

ប្រធានបាឡឺដ ចងចាំពីអារម្មណ៍ដែលលោកបានមាននៅពេលត្រឡប់មកពីព្រះវិហារវិញនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤១ ដោយបានដឹងថាកំពង់ផែគុជត្រូវបានវាយប្រហា ហើយសហរដ្ឋជិតនឹងត្រូវចូលទៅក្នុងសង្គ្រាមលោកលើកទី២ ។ ដូចមនុស្សសព្វថ្ងៃនេះ លោកបានមានការព្រួយបារម្ភអំពីអនាគត និងមានការឆ្ងល់ថាតើ អនាគតផ្ទាល់ខ្លួនរបស់លោកនឹងត្រូវបាត់បង់ឬយ៉ាងណា ។

លោកបានមានប្រសាសន៍ថា« ប៉ុន្តែវាមិនមែនជាអ្វីដែលបានកើតឡើងនោះទេ » ។ ដូចប្រជាជនសេរីនៃពិភពលោកបានឈ្នះសង្គ្រាមនោះដែរ នោះពិភពលោកនឹងឈ្នះសង្គ្រាម ប្រឆាំងនឹងវីរុសនេះ ។ លោកបានមានប្រសាសន៍ថា « អ្វីៗនឹងល្អប្រសើរឡើងនៅពេលយើងបង្វែរចិត្តរបស់យើងទៅរកព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ហើយមើលទៅទ្រង់ និងព្រះអង្គសង្គ្រោះ ជាអង្គប្រោសលោះនៃមនុស្សជាតិទាំងអស់ » ។

វិធីម៉្យាងទៀតដែលសាសនាចក្រដើរឆ្ពោះទៅមុខនោះគឺតាមរយៈការខិតខំផ្សព្វផ្សាយសាសនារបស់ខ្លួនដែលឆ្លើយតបទៅនឹងការផ្លាស់ប្ដូរស្ថានភាពពិភពលោក ។ អែលឌើរ ឌៀថើ អេហ្វ អុជដូហ្វ បានមានប្រសាសន៍ថា អ្នកដឹកនាំសាសនាចក្របាននឹងកំពុងសិក្សាវិធីថ្មីៗក្នុងការចែកចាយដំណឹងល្អតាំងពីមុនពេលជំងឺកូវីដ១៩ចាប់ផ្ដើមរំខានដល់ការផ្សព្វផ្សាយសាសនាម៉្លេះ ។ ការរអាក់រអួលនេះរួមមានការបញ្ជូនអ្នកផ្សព្វផ្សាយសាសនារាប់ពាន់អ្នកទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ ដោយដោះលែងអ្នកខ្លះមុនពេលកំណត់ និងចាត់តាំងឡើងវិញអ្នកផ្សេងទៀត ។

លោកបានមានប្រសាសន៍ ថា « កូវីដ១៩បានបង្កើនការគិតរបស់យើងអំពីរឿងនេះយ៉ាងខ្លាំង និងបានបើកភ្នែករបស់យើងផងដែរ » ។



រូបថត ដោយ ជៀលេន ស៊ី អាន់ឌើរស៊ុន

ជាលទ្ធផល បច្ចេកវិទ្យា និងបណ្តាញសង្គម ឥឡូវនេះកំពុងបើកទ្វារដែលពីមុនត្រូវបានបិទទ្វារដោយសហគមន៍ និងផ្ទះ ព្រមទាំងអាគារផ្ទះល្វែងទាំងនោះដែលមិនអាចចូលបាន ។

អែលឌើ អុជដូហ្វ បានបន្ថែមថា « កិច្ចការផ្សព្វផ្សាយសាសនានឹងបន្តទៅមុខទោះបីជាមានរោគរាតត្បាតយ៉ាងណាក៏ដោយ » ។ « យើងបន្តរៀនអំពីរបៀបដើម្បីអភិវឌ្ឍកិច្ចការផ្សព្វផ្សាយសាសនានៅពេលនេះ និងសម្រាប់ពេលអនាគត ។ ព្រះអម្ចាស់បានសន្យាថា នឹងពន្លឿនកិច្ចការរបស់ទ្រង់សម្រាប់ជាពរជ័យដល់បុត្រាបុត្រីទាំងអស់របស់ព្រះ ( សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា ៨៨:៧៣ ) ។ ខ្ញុំមានអារម្មណ៍ថា យើងនៅពាក់កណ្តាលផ្លូវនៃដំណើរការនេះ ខណៈពេលដែលកំពុងរស់នៅឆ្លងកាត់គ្រាដ៏លំបាកនេះ ។ ពួកអ្នកផ្សព្វផ្សាយសាសនាដ៏មានតម្លៃរបស់យើង គឺជាអ្នកត្រួសត្រាយផ្លូវនៅសម័យរបស់យើង ដោយបង្ហាញផ្លូវនៃការចែកចាយដំណឹងល្អតាមវិធីថ្មីដែលសមស្របនឹងកាលៈទេសៈរបស់យើងដើម្បីឲ្យសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នឹងបន្ត « រមៀលចេញទៅដល់ទីបំផុតផែនដី » ( គោលលទ្ធិ និងសេចក្តីសញ្ញា ៦៥:២ ) ។

ឱកាសថ្មីសម្រាប់ការចែកចាយដំណឹងល្អមិនមែនជាអ្វីតែម្យ៉ាងដែលកំពុងបើកនោះទេ ។ អែលឌើរឌី ថត គ្រីស្តូហ្វើសិន បានមានប្រសាសន៍ថា ដួងចិត្តក៏បានបើកផងដែរពីព្រោះនៅពេលលំបាកតែងតែធ្វើឲ្យមនុស្សចេះបន្ទាបខ្លួន និងធ្វើឲ្យពួកគេងាកទៅរកព្រះ ។

« ពួកគេអាចនឹងបើកចំហរបន្តិចដើម្បីគិតថា ‹ ប្រហែលជាខ្ញុំត្រូវការអ្វីក្រៅពីគណនីធនាគាររបស់ខ្ញុំ ។ លោកបានមានប្រសាសន៍ថា ប្រហែលជាមានអ្វីច្រើនជាងជីវិតដែលខ្ញុំកំពុងរស់នៅនេះ › » ។

អែលឌើរឌី ថត គ្រីស្តូហ្វើសិន បានលើកទឹកចិត្តសមាជិកទាំងឡាយឲ្យរកមើលឱកាសផ្សព្វផ្សាយសាសនា ដូចជាចែកចាយសារដែលទាក់ទងទៅនឹងដំណឹងល្អ និងចែកចាយតាមរយៈបណ្តាញសង្គម ទំនាក់ទំនងជាមួយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងអំពីការជួយមនុស្សដែលពួកគេកំពុងបង្រៀនតាមអិនធើណែត និងទំនាក់ទំនងជាមួយមនុស្សដែលពួកគេមិនអាចជួបជាញឹកញាប់ ។

**ការរក្សាគម្លាតខាងសង្គម និងការឃ្លាតឆ្ងាយខាងវិញ្ញាណ**

វិធីមួយទៀតដែលសាសនាចក្រដើរឆ្ពោះទៅមុខនោះគឺតាមរយៈការឆ្លើយតបខាងវិញ្ញាណនៃពួកបរិសុទ្ធថ្ងៃចុងក្រោយចំពោះឧបសគ្គខាងសាច់ឈាមដូចជាជំងឺកូវីដ ១៩ ។ សម្រាប់ការការពាររាងកាយរបស់យើង យើងបង្កើនគម្លាតខាងរូបកាយពីអ្នកដទៃ ប៉ុន្តែដើម្បីការពារខាងវិញ្ញាណ យើងចូលកាន់តែជិតព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង និងបុត្រារបស់ទ្រង់ ។ ជំងឺរាតត្បាតកូវីដ-១៩បានផ្តល់ឱកាសដល់សមាជិកសាសនាចក្រជាច្រើនដើម្បីបង្កើនការការពារខាងវិញ្ញាណដោយធ្វើតាមការណែនាំរបស់ប្រធាន រ័សុល អិម ណិលសុន ដើម្បីស្តាប់តាមព្រះអម្ចាស់ ។

ប្រធាន រ័សុល អិម ណិលសុនបានមានប្រសាសន៍នៅខែមេសា ឆ្នាំ២០២០ នៅក្នុងសន្និសីទទូទៅថា « ព្រះវរបិតាយើងដឹងថានៅពេលយើងត្រូវបានហ៊ុំព័ទ្ធដោយភាពមិនប្រាកដប្រជា និងភាពភ័យខ្លាច អ្វីដែលនឹងជួយយើងបំផុតនោះគឺស្តាប់តាមព្រះរាជបុត្រាទ្រង់ » ។ លោកបានបន្ថែមទៀតថា « នៅពេលយើងស្វែងរកដើម្បីធ្វើជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ កិច្ចខិតខំរបស់យើងដើម្បី*ស្តាប់ទ្រង់*ចាំបាច់ត្រូវមានដោយគោលបំណងកាន់តែខ្លាំង ។ វាត្រូវការខិតខំដោយមនសិកា និងប្រកាន់ខ្ជាប់ដើម្បីបំពេញជីវិតប្រចាំថ្ងៃរបស់យើងដោយព្រះបន្ទូលរបស់ទ្រង់ ការបង្រៀនរបស់ទ្រង់ និងសេចក្តីពិតរបស់ទ្រង់ » ។[៦]

ខណៈពេលដែលយើងមិនស្វាគមន៏ការពន្យារពេលនៃការប្រជុំ ការបិទព្រះវិហារបរិសុទ្ធ ឬការបាត់បង់ការងារ ការចំណាយពេលច្រើននៅផ្ទះផ្តល់ឲ្យយើងនូវ « ឱកាសដើម្បីគិតអំពីការភ្ជាប់ខ្លួនចំពោះព្រះ » ( សូមមើល អាលម៉ា ៥:៧ ) ប្រសាសន៍របស់អែលឌើរ យុក ។ « ប្រហែលជាព្រឹត្តិការណ៍ថ្មីៗនេះអាចជានាឡិការោទិ៍ខាងវិញ្ញាណដែលផ្តោតលើយើងនូវរឿងដែលសំខាន់បំផុត ។ ប្រសិនបើដូច្នោះមែន វាគឺជាពរជ័យមួយដ៏អស្ចារ្យនៅក្នុងរយៈពេលនេះដើម្បីផ្តោតលើអ្វីដែលយើងអាចធ្វើឲ្យល្អឥតខ្ចោះនៅក្នុងជីវិតរបស់យើង និងរបៀបដែលយើងអាចផ្តល់ពរដល់ជីវិតអ្នកដទៃទៀត នៅពេលយើងភ្ញាក់រលឹកចំពោះព្រះហើយដើរលើផ្លូវនៃសេចក្តីសញ្ញា » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន បានបន្ថែមថា « ពេលវេលាបែបនេះអញ្ជើញយើងឲ្យមើលទៅក្នុងព្រលឹងរបស់យើង ដើម្បីមើលថាតើយើងចូលចិត្តអ្វីដែលយើងបានឃើញនៅទីនោះដែរឬទេ ។ នោះគឺជាពេលដែល [ យើង ] គិតថាតើ [ យើង ]ជានរណា និងអ្វីដែលសំខាន់ » ។

អែលឌើរ ហូឡិន បានមានប្រសាសន៍ថា ពេលវេលាបែបនេះអញ្ជើញយើងឲ្យបង្កើនសេចក្តីជំនឿ ការបម្រើ និងការដឹងគុណ



របស់យើង ដែលជំរុញយើងឲ្យ « ពិចារណាលើការពឹងផ្អែករបស់យើងទៅលើព្រះ និងពរជ័យទាំងឡាយដែលមកពីទ្រង់ដែលជារឿយៗយើងតែងតែមិនសូវចាប់អារម្មណ៍ » ។ « យើងជំពាក់ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ដើម្បីដឹងគុណបន្ថែមទៀត មានអំណរគុណបន្ថែមទៀត និងមានទំនោរបន្ថែមទៀតដើម្បីចាំពីបញ្ហាជាច្រើនដែលត្រូវបានដោះស្រាយដោយសារព្រះ ពួកទេវតា កិច្ចព្រមព្រៀងនៃការសន្យា និងការអធិស្ឋាន » ។

នៅចំកណ្ដាលនៃការដឹងគុណរបស់យើងគឺជាពរជ័យនៃការចងចាំ « តើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាងណាដល់កូនចៅមនុស្ស ចាប់តាំងពីកំណើតលោកអ័ដាមមក រហូតមកដល់ពេល [ នេះ ] » ( អាលម៉ា១០:៣ ) ។ សមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់បានមានប្រសាសន៍ថា នៅពេលណាដែលយើងត្រូវបានតម្រូវឲ្យ « រស់នៅនឹងកន្លែង » យើងអាចធ្វើតាមគំរូរបស់នីហ្វៃ និងអាលម៉ាដោយចងចាំថា ទ្រង់ជាអ្នកដែល « [ យើង ] ទុកចិត្ត » ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ « នឹងនៅតែដោះលែង [ យើង ] » ។ ( នីហ្វៃទី២ ៤:១៩; អាលម៉ា៣៦:២៧ ) ។ ហើយយើងអាចចាំបានដូចសាវកប៉ុលបានបង្រៀនថា គ្មានអ្វីដែល « ពង្រាត់យើងចេញពីសេចក្ដីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន » ឡើយ ( សូមមើល រ៉ូម ៨:៣៥ ) ។

អែលឌើរ ហូឡិន បានមានប្រសាសាសន៍ថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទ « ជាទីជ្រករបស់យើង » ( សូមមើល ទំនុកដំកើង ៦១:១–៤ ) ។ « ទោះបីមានអ្វីផ្សេងទៀតកើតឡើងក៏ដោយ យើងនឹងមិនត្រូវឃ្លាតឆ្ងាយពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ និងភាពជាដៃគូរបស់ទ្រង់បានឡើយ ទោះបីយើងមិនស្គាល់វានៅពេលនោះក៏ដោយ ។ ព្រះវិញ្ញាណមិនត្រូវបានរាំងស្ទះដោយវីរុស ឬដោយព្រំដែនជាតិ ឬដោយការព្យាករខាងវេជ្ជសាស្ត្រឡើយ » ។

**« ធ្វើរឿងសប្បុរស »**

ថ្មីៗនេះ នៅពេលអានរបាយការណ៍ដែលបង្កើតឡើងដោយគណៈកម្មាធិការសាសនាចក្រមួយ អែលឌើរ គ្រីស្តូហ្វឺសិន មានការព្រួយបារម្ភអំពីផលប៉ះពាល់នៃ « ការនៅតែឯងដោយបង្ខំ » ដែលអាចកើតមានឡើងចំពោះសមាជិកនៅលើរបស់សាសនាចក្រ—ទាំងនៅក្មេង និងចាស់ ។

លោកបាននិយាយថា « ការនៅតែឯងដោយបង្ខំអាចនាំទៅរកភាពឯកោ ហើយភាពឯកោអាចនាំឲ្យមានភាពអវិជ្ជមានចំពោះរាងកាយ និងបញ្ហាសុខភាពខាងសតិអារម្មណ៍ ។ « ដើម្បីទប់ទល់នឹងបញ្ហានេះ អ្នកតស៊ូមតិផ្នែកសុខភាពសាធារណៈមួយចំនួនបានផ្ដល់អនុសាសន៍ថាអស់អ្នកណាដែលមានភាពឯកោគួរស្វែងរកមធ្យោបាយដើម្បីធ្វើរឿងល្អសម្រាប់នរណាម្នាក់ » ។

អែលឌើរ គ្រីស្តូហ្វឺសិន បានមានប្រសាសន៍ថា ពួកបរិសុទ្ធថ្ងៃចុងក្រោយអាចរកវិធីដើម្បីបម្រើ ជួយ និងបរិច្ចាគដល់អ្នកដទៃជាពិសេសដល់អ្នកទាំងឡាយណាដែលឯកោ ហើយសមាជិកដែលឯកោដែលផ្ដល់ការបម្រើដល់អ្នកដទៃអាចបន្ថយអារម្មណ៍ឯកោរបស់ពួកគេបាន ។

លោកបាននិយាយថា « ផ្ដោតទៅលើការងារបម្រើ » ។ « មានរឿងច្រើនដែលយើងអាចធ្វើបានសម្រាប់គ្នាទៅវិញទៅមកដើម្បីឲ្យមានអារម្មណ៍នៃភាពជាបងប្អូនប្រុសស្រី និងភាតរភាព ។ នេះជាពេលវេលាមួយដែលកូរ៉ុមអែលឌើ និងសមាគមសង្គ្រោះពិតជាអាចចូលមកនៅក្នុងក្រុមរបស់ពួកគេផ្ទាល់ និងផ្ដល់នូវអ្វីដែលពិសេសដែលពួកគេត្រូវបានរៀបចំតែមួយគត់ដើម្បីធ្វើ » ។

លោកបានស្នើថា ជាជាងផ្ញើសារទៅនរណាម្នាក់ « ខ្ញុំគិតថាវាជាការប្រសើរណាស់ក្នុងការហៅទូរស័ព្ទទៅនរណាម្នាក់ដោយប្រើបច្ចេកវិទ្យាចាស់ហៅថាទូរស័ព្ទ ។ គ្រាន់តែហៅទូរសព្ទដើម្បីនិយាយ និងធ្វើការប្រាស្រ័យទាក់ទង ។ អនុញ្ញាតឲ្យពួកគេឮសំឡេង » ។

កិច្ចប្រឹងប្រែងតូចៗដើម្បីឈោងទៅជួយអ្នកដទៃអាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងខ្លាំង ធ្វើឲ្យថ្ងៃរបស់នរណាម្នាក់ភ្លឺថ្លាដែលយើងប្រហែលជាមិនអាចដឹងបាន ។ អែលឌើរ យុក បានមានប្រសាសន៍ថា « ការងារបម្រើរបស់យើងគឺចាំបាច់ណាស់ជាមួយមនុស្សដែលនៅឯកោ » ។



*កិច្ចប្រឹងប្រែងតូចៗដើម្បីឈោងទៅជួយអ្នកដទៃអាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងខ្លាំង ធ្វើឲ្យថ្ងៃរបស់នរណាម្នាក់ក្លាយជាថ្ងៃដែលយើងប្រហែលជាមិនអាចដឹងបាន ។ « ការងារបម្រើរបស់យើងគឺចាំបាច់ណាស់ជាមួយមនុស្សដែលនៅឯកោ » ។*
*—ឃ្វិនចិន អិល យុក*

អែលឌើរ ហូឡិន បានណែនាំថា « យើងគួរតែលះបង់ចំណែកណាមួយនៅក្នុងមួយថ្ងៃរបស់យើងដើម្បីប្រាស្រ័យទាក់ទងជាមួយមនុស្សដែលត្រូវការការជំរុញ ។ ជាការពិតណាស់ យើងទទួលបានការជំរុញពីការធ្វើដូច្នោះ មនុស្សគ្រប់រូបត្រូវបាន ‹ លើកឡើង › ( នីហ្វៃទី៣ ២៧:១៤, ១៥ ) ដូចដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់ត្រូវបានបញ្ជូនមកផែនដីឲ្យធ្វើ » ។

វិធីមួយទៀតដែលយើងអាចលើកខ្លួនឯង និងអ្នកដទៃទៀតគឺត្រូវត្រៀមសម្រាប់ថ្ងៃដែលព្រះវិហារបរិសុទ្ធបើកឡើងវិញ ។ អែលឌើរ បែដណា បានមានប្រសាសន៍ថា ការបិទព្រះវិហារបរិសុទ្ធ—មិនថាសម្រាប់ការរាតត្បាត ការកែលំអរ ឬការសម្អាត—« ផ្ដល់នូវឱកាសអស្ចារ្យដើម្បីរៀនបន្ថែមអំពីការស្រាវជ្រាវពង្សប្រវត្តិ ការធ្វើលិបិក្រម និងវិធីដើម្បីរៀបចំឈ្មោះជាច្រើនសម្រាប់ថ្ងៃដែលទ្វារព្រះវិហារបរិសុទ្ធបើកម្ដងទៀត » ។

អែលឌើរ បែដណា បានបន្ថែមថា មិនថាព្រះវិហារបរិសុទ្ធបានបើក ឬបិទនោះទេ ក៏សមាជិកនៃសាសនាចក្រនៅតែព្យាយាមធ្វើឲ្យមានភាពសក្ដិសមនិងមានបណ្ណ័ព្រះវិហារបរិសុទ្ធបច្ចុប្បន្នមួយ ។

**មេរៀនដែលព្រះអម្ចាស់ចង់ឲ្យយើងរៀន**

ដូចអែលឌើរ បែដណា បានចង្អុលបង្ហាញថាខណៈដែលគ្មាននរណាម្នាក់ជ្រើសរើសយកបទពិសោធន៍នៃការរាតត្បាតនៃជំងឺ កូវីដ ១៩ ក៏គ្រោះកាចនៃថ្ងៃចុងក្រោយមានលើយើងដែរ ។

លោកបានមានប្រសាសន៍ថា « ដោយមានទស្សនវិស័យអស់កល្បដែលដំណឹងល្អដែលបានស្ដារឡើងវិញផ្ដល់ឲ្យ និងព្រះគុណដែលបានមកពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ យើងអាចរៀនមេរៀនពីភាពលំបាកនៃជីវិតរមែងស្លាប់ដែលរៀបចំយើងសម្រាប់ពរជ័យនៃភាពអស់កល្បជានិច្ច » ។ « យើងត្រូវធ្វើការអធិស្ឋាន ។ យើងត្រូវតែស្វែងរក ។ យើងត្រូវតែទូលសុំ ។ យើងត្រូវតែមានភ្នែកដែលមើលឃើញ និងត្រចៀកដែលស្ដាប់ឮ ។ ប៉ុន្តែយើងអាចទទួលបានពរជ័យតាមវិធីគួរឲ្យកត់សម្គាល់ ដើម្បីរៀនមេរៀនដែលនឹងផ្ដល់ពរដល់យើងនៅពេលឥឡូវនេះ និងជារៀងរហូត » ។

ប្រធានបាឡឺដ បានមានប្រសាសន៍ថា ដោយមានផលប៉ះពាល់ដ៏ធ្ងន់ធ្ងរទៅលើគ្រួសារនៅលើពិភពលោក កូវីដ ១៩ បានបង្រៀនមនុស្សឲ្យបង្ហាញការយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះអ្នកដទៃ ។

លោកបានមានប្រសាសន៍ថា « យើងនឹងដឹងថាគ្រួសាររបស់យើងមានតម្លៃប៉ុណ្ណា អ្នកជិតខាងរបស់យើងមានតម្លៃប៉ុណ្ណា និងសមាជិកក្រុមជំនុំមានតម្លៃណាស់ » ។ « មានមេរៀនដែលយើងកំពុងរៀននៅពេលនេះដែលនឹងធ្វើឲ្យយើងក្លាយទៅជាមនុស្សកាន់តែប្រសើរ » ។

ហើយនៅពេលព្យុះនាពេលបច្ចុប្បន្នឆ្លងផុតទៅ តើយើងអាចរំពឹងអ្វីនៅពេលនោះ ? អែលឌើរ អុដ ដូហ្វ បានមានប្រសាសន៍ថា ដូចគ្នាច្រើនទៀត ។ បុត្រាបុត្រីរបស់ព្រះនៅក្នុងសាសនាចក្រ ឬនៅក្រៅសាសនាចក្រនឹងបន្តប្រឈមមុខនឹងឧបសគ្គ ។

លោកបានមានប្រសាសន៍ថា « យើងកំពុងរស់នៅក្នុងគ្រាមួយដែលយើងពិតជាចាំបាច់ត្រូវការការរៀនសូត្រ » ។ ហើយមេរៀនដែលសំខាន់បំផុតដែលយើងអាចរៀននោះគឺថាចម្លើយចំពោះបញ្ហាប្រឈមមុខនាពេលខាងមុខជាចម្លើយចំពោះបញ្ហាប្រឈមមុខបច្ចុប្បន្នដែរ ៖ គឺដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

អែលឌើរ ហូឡិន បានមានប្រសាសន៍ថា ពីព្រោះពួកបរិសុទ្ធថ្ងៃចុងក្រោយមានដំណឹងល្អដែលបានស្ដារឡើងវិញ ពួកគេអាចរៀនដើម្បីមានភាពវិជ្ជមាននិងមានសុទិដ្ឋិនិយម ធ្វើឲ្យអស់ពីសមត្ថភាព និងទទួលយកព្រះអម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់នៅពេលទ្រង់បានមានបន្ទូលថា « ចូរយើងប្រព្រឹត្តការណ៍ទាំងនេះ ដែលនៅក្នុងអំណាចយើងដោយមានចិត្តរីករាយចុះ ហើយលំដាប់នោះ យើងអាចឈរនៅស្ងៀមដោយជឿជាក់ថានឹងបានឃើញសេចក្ដីសង្គ្រោះពីព្រះ និងបានព្រះពាហុទ្រង់បើកសម្ដែងមកឲ្យឃើញ »( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៣:១៧ ) ។

អែលឌើរ ហូឡិន បានមានប្រសាសន៍ថា « មានអ្វីជាច្រើនដែលត្រូវរីករាយ នៅពេលយើងធ្វើឲ្យប្រសើរឡើងនូវជំនឿរបស់យើង ទុកចិត្តទៅលើព្រះអម្ចាស់និងមើលឃើញអព្ភូតហេតុនៃការរំដោះរបស់ទ្រង់ » ។ ■

កំណត់ចំណាំ

១. សូមមើល *William G. Hartley,* « *The Church Grows in Strength,* » *Ensign*, ខែកញ្ញា ឆ្នាំ១៩៩៩ ទំព័រ ៣៥ ។
២. *Teachings of Presidents of the Church: Heber J. Grant* ( ឆ្នាំ ២០០២ ) ទំព័រ ៤៩, ៤៨ ។
៣. សូមមើល រ័សុល អិម ណិលសុន « អំណរ និងការរស់រានខាងវិញ្ញាណ » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៨២ ។
៤. Bruce R. McConkie, « The Caravan Moves On, » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៤ ទំព័រ ៨៥ ។
៥. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* ៤:៥៤០ ។
៦. រ័សុល អិម ណិលសុន « Hear Him, » *Liahona,* ខែ ឧសភា ឆ្នាំ ២០២០ ទំព័រ ៨៩ ។

រូបថតពី GETTY IMAGES



# ដួងចិត្តត្រូវបានចាក់ទម្លុះដោយរបួសដ៏ជ្រៅ ៖ ការយល់ដឹងពីការរំលោភបំពាននៅក្នុងគ្រួសារ

*លំនាំមិនល្អអាចកើតឡើងក្នុងគ្រប់ចំណងទាក់ទង ។ ការស្គាល់ពីលំនាំទាំងនោះអាចលាតត្រដាងពីការរំលោភបំពាន ឬបញ្ឈប់វាមុនពេលវាចាប់ផ្ដើម ។*

**ដោយបណ្ឌិត ជេសិន ប៊ី វ៉ៃធិង**
*សាកលវិទ្យាល័យព្រិកហាំ យ៉ង់ សាលានៃ ជីវិតគ្រួសារ*

ថ្មីៗនេះខ្ញុំបានទូរសព្ទទៅឪពុកដែលខូចចិត្តម្នាក់ ។ កូនស្រីគាត់ ជេនណា ( ឈ្មោះត្រូវបានប្ដូរ ) រៀននៅឆ្ងាយនៅឯមហាវិទ្យាល័យ មានចំណងទាក់ទងថ្មីមួយ ហើយវាឈានទៅមុខយ៉ាងលឿន ។ មិត្តប្រុសរបស់នាង ជេក បង្ខំការរៀបការ ហើយដាក់កំណត់លើទំនាក់ទំនងរបស់ជេនណាជាមួយឪពុកម្ដាយនាង ។ ជេនណាបានសូមអភ័យទោសដល់ពួកគាត់ ដោយពន្យល់ថា វាជាសេចក្ដីស្រឡាញ់ដ៏ខ្លាំងរបស់ជេក និងបំណងប្រាថ្នារបស់គាត់ដើម្បីចំណាយពេលជាមួយគ្នាជាស្វាមីភរិយា ។

គ្រួសាររបស់ជេនណាព្រួយបារម្ភ នៅពេលដែលបានដឹងថា ជេកមានអតីតភរិយា និងកូនម្នាក់ដែលគាត់ពុំបានប្រាប់ដល់ជេនណា ។ ពួកគេបានទូរសព្ទទៅអតីតភរិយាជេក ហើយនាងបានប្រាប់ថា ជេកជាមនុស្សឆេវឆាវមិនអាចគ្រប់គ្រងអារម្មណ៍ ហើយប្រចណ្ឌច្រើន ។ ពេលជេកបានដឹងរឿងនោះ គាត់ខឹងខ្លាំងណាស់ ។ គាត់បាននិយាយថា ឪពុកម្ដាយជេនណា « ត្រួតត្រា » ហើយបានរំឭកពីពេលមួយដែលពួកគាត់មិនយល់ស្របនឹងការនិយាយកំប្លែងលេងរបស់ជេកដែលចំអន់អំពីប្រាជ្ញារបស់ជេនណា ។ ជេកបានទាមទារដោយឡកឡឺយថា ជេនណាត្រូវតែធ្វើការសម្រេចចិត្តដោយខ្លួនឯងដោយកាត់ផ្ដាច់ទំនាក់ទំនងឪពុកម្ដាយនាងចោល ។ ឪពុកម្ដាយរបស់ជេនណាអស់សង្ឃឹមយ៉ាងខ្លាំង កាលដែលពុំមានការឆ្លើយតបចំពោះទូរសព្ទ និងសាររបស់ពួកគាត់ ។

គ្រប់គ្នាចង់បានគ្រួសារដ៏រីករាយមួយ ប៉ុន្តែសូម្បីតែពេលដែលមនុស្សព្យាយាមរស់នៅតាមដំណឹងល្អក្ដី ក៏ចំណងទាក់ទងអាចមាននូវការឈឺចាប់ ។ ឧបសគ្គមួយចំនួនជាលទ្ធផលនៃការយល់ច្រឡំ និងជម្លោះខ្វែងគំនិត ដែលជាការទូទៅចំពោះគ្រួសារទាំងឡាយ ។ ទោះជាយ៉ាងណា នៅក្នុងគ្រួសារដែលមានចំណងទាក់ទងល្អ មនុស្សសូមអភ័យទោសចំពោះឥរិយាបទមិនល្អ និងកែប្រែចំណងទាក់ទងដែលមិនល្អ ខណៈដែលស្ថានភាពមិនល្អមាននូវលំនាំកាចសាហាវ ឬការធ្វើបាបជាបន្តបន្ទាប់ ដែលក្លាយជាការរំលោភបំពាន ។

## ការរំលោភបំពានក្នុងគ្រួសារ និងដំណឹងល្អ

« *អ្នកបានធ្វើឲ្យភរិយាដ៏ទន់ភ្លន់របស់អ្នកខូចចិត្ត ហើយធ្វើឲ្យកូនចៅអ្នកគ្មានសេចក្ដីទុកចិត្ត* » ( *យ៉ាកុប ២:៣៥* ) ។

ការរំលោភបំពានរួមមាននូវសកម្មភាពទាំងឡាយដែលមានចេតនាធ្វើឲ្យឈឺចាប់ ឬមានចេតនាត្រួតត្រា ។ វាមាននូវឥរិយាបថទាំងឡាយដែលអាចរួមមាន ការមិនយកចិត្តទុកដាក់ ការគ្រប់គ្រងដោយឧបាយកល ការរិះគន់ដោយពាក្យសម្ដី និងអំពើហឹង្សាខាងរាងកាយ និងផ្លូវភេទ ។[១] ជាអកុសល ឥរិយាបទរំលោភបំពានគឺកើតឡើងជាទូទៅ ដែលមានអ្នកប្រាជ្ញមួយចំនួនប៉ាន់ប្រមាណថា ប្រហែលជាមួយភាគបួននៃកុមារនៅទូទាំងពិភពលោកត្រូវបានគេធ្វើបាបខាងរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ។[២] មជ្ឈិមវ័យក៏មានអាត្រាខ្ពស់ក្នុងការរងគ្រោះផងដែរ ដោយប្រមាណជា ១នាក់នៅក្នុងស្ត្រី៤នាក់ និង ១នាក់នៅក្នុងបុរស១០នាក់ ដែលរងនូវអំពើហឹង្សាខាងរាងកាយពីស្វាមី ឬភរិយា ។

រូបថតទាំងឡាយត្រូវបានប្រើសម្រាប់គោលបំណងជាការបង្ហាញតែប៉ុណ្ណោះ



« សំឡេងដែលថ្លែងទីបន្ទាល់បានយ៉ាងល្អ ការអធិស្ឋានដ៏ក្លៀវក្លា និងការច្រៀងទំនុកតម្កើងនៃស៊ីយ៉ូន អាចជាសំឡេងតែមួយដែលស្ដីបន្ទោសហើយរិះគន់ ធ្វើឲ្យអាម៉ាស់ ហើយបន្ទាបបន្ថោក ធ្វើឲ្យមានការឈឺចាប់ និងការបំផ្លិចបំផ្លាញវិញ្ញាណរបស់ខ្លួនឯង និងមនុស្សដទៃទៀតនៅក្នុងដំណើរការនេះ ។ យ៉ាកុបថ្លែងទាំងកើតទុក្ខថា ‹ មានទាំងពាក្យសរសើរ និងពាក្យប្រទេចផ្ដាសា ចេញមកពីមាត់តែ១នោះឯង ‹ បងប្អូន [ ប្រុសស្រី ] អើយ មិនគួរគប្បីឲ្យមានដូច្នោះឡើយ › [ យ៉ាកុប ៣:១០ ] » ។

**អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « The Tongue of Angels » *Liahona,* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១៦ ។**

ការរំលោភបំពានអាចកើតឡើងនៅក្នុងចំណងទាក់ទង ហើយទាំងបុរស និងស្ត្រីអាចជាជនល្មើស ។ ទោះជាយ៉ាងណា បុរសទំនងជាត្រួតត្រា និងប្រព្រឹត្តអំពើហិង្សាធ្ងន់ធ្ងរខាងរាងកាយ និងផ្លូវភេទជាង ហើយស្ត្រីទំនងជាត្រូវបានធ្វើឲ្យភិតភ័យ ត្រួតត្រា ឬធ្វើឲ្យឈឺចាប់យ៉ាងខ្លាំងដោយស្វាមី ។[៣]

ការរំលោភបំពានធ្វើឲ្យគ្រោះថ្នាក់ដល់ព្រលឹងរបស់អ្នកប្រព្រឹត្តបទល្មើសផង និងរបស់ជនរងគ្រោះផង ហើយវាផ្ទុយពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ។ ពួកព្យាការីសម័យទំនើបបានថ្លែងថា ពួកអ្នក « ដែលបានធ្វើបាបភរិយា ឬកូនចៅ . . . គង់តែថ្ងៃណាមួយនឹងទទួលខុសត្រូវនៅចំពោះព្រះ » ។[៤] ជាញឹកញាប់ អ្នកប្រព្រឹត្តការរំលោភបំពានព្រងើយកន្តើយ ឬប្រើប្រាស់គោលការណ៍នៃដំណឹងល្អសម្រាប់គោលបំណងផ្ទាល់ខ្លួនវិញ ។ ឧទាហរណ៍ ខ្ញុំបានប្រឹក្សាស្វាមីភរិយាមួយគូ ដែលស្វាមីផិតក្បត់លួចទាក់ទងនឹងស្ត្រីផ្សេងទៀត ហើយបានយកប្រាក់សន្សំរបស់ពួកគេទៅលេងល្បែង ប៉ុន្តែជំនួសឲ្យការសូមទោស គាត់បែរជាដាក់សម្ពាធឲ្យភរិយាគាត់អភ័យទោសឲ្យគាត់ ហើយបាននិយាយថា នាងមាន « អំពើបាបធ្ងន់ធ្ងរជាង » បើនាងមិនអភ័យទោសដល់គាត់ទេ ។ គាត់មិនខ្វល់ពីការឈឺចាប់របស់នាងទេ ហើយបានប្រកាសថា រឿងទាំងនេះត្រឹមត្រូវចំពោះព្រះ បើមិនអញ្ចឹងគាត់មិនមែនជាអ្នកធ្វើការក្នុងព្រះវិហារបរិសុទ្ធនោះទេ ។ ពេលភរិយាគាត់បាននិយាយទៅកាន់ថ្នាក់ដឹកនាំសាសនាចក្រ គាត់បាននិយាយធ្វើឲ្យគេគិតថា ការផិតក្បត់របស់គាត់មិនធ្ងន់ធ្ងរ ហើយបានបំផ្លើសពីកង្វល់របស់នាង ដោយនិយាយថានាងមានជំងឺធ្លាក់ទឹកចិត្ត ។ ស្វាមីនោះបានបដិសេធ « គោលការណ៍នៃ . . . ការគោរពគ្នា សេចក្ដីស្រឡាញ់ [ និង ] សេចក្ដីមេត្តាករុណា »[៥] ហើយកំពុងធ្វើបាបភរិយារបស់គាត់ ។ ការប្រឹងប្រែងរបស់នាងដើម្បីរស់នៅតាមគោលការណ៍នៃដំណឹងល្អ ពុំអាចជួសជុលបញ្ហាដែលគាត់បង្កើតឡើងបានទេ ។ យើងម្នាក់ៗអាចធ្លាក់ខ្លួនចូលទៅក្នុងឥរិយាបទដែលមិនល្អ ។ មានលក្ខណៈជាក់លាក់ទាំងឡាយដែលទូទៅចំពោះការរំលោភបំពានគ្រប់ប្រភេទ ហើយការមានលក្ខណៈទាំងនេះកាន់តែធ្ងន់ធ្ងរ និងកាន់តែញឹកញាប់ប៉ុណ្ណា នោះចំណងទាក់ទងនោះកាន់តែមិនល្អប៉ុណ្ណោះដែរ ។ នេះជាលំនាំទូទៅប្រាំនៃការរំលោភបំពានទាំងនេះ ដែលអាចជួយបងប្អូនឲ្យស្គាល់ពីឥរិយាបទមិនល្អនៅក្នុងខ្លួនបងប្អូនផ្ទាល់ និងអ្នកដទៃទៀត ។

***១. ភាពឃោរឃៅ***

« *គេប្រើអណ្ដាតគេសម្រាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេ មានសុទ្ធតែពិសពស់ហនុមាន . . . មាត់ [ របស់គេ ] មានពេញដោយសេចក្ដីបណ្ដាសា និងសេចក្ដីជូរចត់* » *( រ៉ូម ៣:១៣–១៤ ) ។*

បុរសម្នាក់បានមកជួបខ្ញុំដើម្បីបានការព្យាបាល ជំទាស់នឹងបំណងរបស់ភរិយាគាត់ ដែលបានចំអកឲ្យគាត់ព្រោះគាត់ « ត្រូវការជំនួយ » ។ នៅព្រះវិហារនាងរាក់ទាក់ ហើយមានជំនឿណាស់ ប៉ុន្តែនៅផ្ទះការមានឫកធំដ៏សាហាវរបស់នាង ឈឺដូចវាយនឹងរំពាត់អញ្ចឹង ។ នាងបានរិះគន់ពីប្រាក់ចំណូលរបស់គាត់ ហើយបានហៅអាជីពបង្រៀនរបស់គាត់ថាជា « ការងារស្រី » ។ នាងប្រាប់កូនប្រុសនាងថា « ម៉ាក់សង្ឃឹមថា កូនមិនក្លាយជាមនុស្សទន់ខ្សោយដូចជាប៉ាកូនទេ » ហើយបានចំណាយពេលលើទូរសព្ទរាល់ថ្ងៃ



## ស្វែងរកបន្ថែមទៀត

**ថ្នាក់ដឹកនាំអាចរកជំនួយបានដើម្បីដោះស្រាយនឹងការរំលោភបំពាន នៅក្នុងផ្នែក ធនធានសម្រាប់ថ្នាក់ដឹកនាំ និងស្មៀន នៅគេហទំព័រ ChurchofJesusChrist.org ។ ថ្នាក់ដឹកនាំ និងគ្រូបង្រៀនកុមារ និងយុវវ័យទាំងអស់ គម្បីបញ្ចប់ការហ្វឹកហ្វឺន « ការការពារកុមារ និងយុវវ័យ » ក្នុងរយៈពេលមួយខែក្រោយពីត្រូវបានហៅឲ្យបម្រើ ។ ការហ្វឹកហ្វឺននោះអាចរកបាននៅគេហទំព័រ ChurchofJesusChrist.org/callings/church-safety-and-health ។**



និយាយជាមួយម្ដាយនាង ដែលពួកគេនាំគ្នាបង្អាប់ស្វាមីរបស់ពួកគេ ។ មនុស្សដែលរកតែកំហុសពេញចិត្តក្នុងការបង្កការឈឺចាប់ ហើយ « ចូលចិត្តធ្វើឲ្យអ្នកផ្សេងរងទុក្ខ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:១៣ ) ។ សមាជិកគ្រួសារទាំងនេះបំពានបទបញ្ញត្តិរបស់ព្រះយេស៊ូវដែល « កុំឲ្យថ្កោលទោស » និង « កុំឲ្យនិន្ទា » ( លូកា ៦:៣៧ ) ពេលដែលពួកគេមើលងាយ បង្ហាញការស្អប់ខ្ពើម ឬហៅមនុស្សតាមឈ្មោះមិនល្អ ។

***២. ការបោកបញ្ឆោត***

*« អ្នកត្រូវវិញ្ញាណភូតកុហកចូលក្នុងខ្លួនអ្នក ហើយអ្នកបានច្រានចោលព្រះវិញ្ញាណនៃព្រះ » ( អាលម៉ា ៣០:៤២ ) ។*

ការបោកបញ្ឆោតជ្រួតជ្រាបនៅក្នុងការរំលោភបំពាន កាលដែលជនល្មើសបង្រួមសកម្មភាពរបស់ពួកគេ បន្ទោសអ្នកដទៃ ហើយបង្កាច់បង្ខូច ។ ការណ៍នេះធ្វើឲ្យជនរងគ្រោះភាន់ច្រឡំ ដូចជាអ្នកចូលរួមក្នុងការស្រាវជ្រាវរបស់ខ្ញុំម្នាក់បានពិពណ៌នា ៖ « [ ស្វាមីខ្ញុំនឹង ] ស្លន់ស្លោ ហើយធ្វើការសូមទោស ហើយបន្ទាប់មកនិយាយថា ‹ យ៉ាងណាក៏ដោយ វាជាកំហុសរបស់អូន › . . . ហើយ បន្តនិយាយទាល់តែខ្ញុំចាប់ផ្ដើមជឿនូវអ្វីដែលគាត់និយាយ » ។[៦] ការបដិសេធការពិតរបស់មនុស្សម្នាក់ទៀតនេះ ហៅថា ការបញ្ឆេះភ្លើង ហើយវាធ្វើឲ្យជនរងគ្រោះភាន់ច្រឡំ ហើយមិនប្រាកដអំពីការចងចាំ និងគំនិតរបស់ពួកគេ ។ ដូចជាការបោកបញ្ឆោតផ្សេងទៀតដែរ ការបញ្ឆេះភ្លើងត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងដោយឧបាយកលទៅលើការសន្ទនា និងសម្ដែងឲ្យជឿ ។

ពួកអ្នកដែលរំលោភបំពានយ៉ាងខ្លាំងទៅលើអ្នកផ្សេងទៀត មិនព្រមទទួលស្គាល់ថាការរំលោភបំពានទាំងនោះគឺគួរឲ្យឈឺចាប់នោះទេ ហើយជាញឹកញាប់ថែមទាំងប្រកាសថាខ្លួនជាជនរងគ្រោះទៀតផង ។ នៅពេលជេនណាបានបង្ហាញពីការខ្វល់ខ្វាយអំពីការរិះគន់របស់ជេកចំពោះឪពុកម្ដាយនាង គាត់ខឹង ហើយនិយាយដដែលៗថា នាង « ប្រមាថ » គាត់ ។ ជេកគឺនៅក្នុងចំណោម « អស់អ្នកណាដែលស្រែកប្រាប់ពីអំពើរំលង . . . ហើយជាកូនចៅនៃការមិនគោរពប្រតិបត្តិតាមខ្លួនឯងនោះហើយ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:១៧ ) ។ គាត់មិនត្រឹមតែគាំទ្ររឿងក្លែងក្លាយរបស់គាត់ទេ ប៉ុន្តែថែមទាំងមិនសប្បាយចិត្តនឹងសេចក្ដីពិតទៀតផង ។[៧]

***៣. ការដោះសារ***

*« ទទួលស្គាល់កំហុសរបស់ខ្លួន និងការខុសឆ្គង ដែលកូនបានប្រព្រឹត្តមក » ( អាលម៉ា ៣៩:១៣ ) ។*

មនុស្សដ៏រាបទាបម្នាក់មានអារម្មណ៍សោកស្ដាយដែលធ្វើឲ្យអ្នកដទៃទៀតឈឺចាប់ ហើយប្រែចិត្ត និងធ្វើខ្លួនឲ្យប្រសើរឡើង ។ មនុស្សម្នាក់ដែលរំលោភបំពានមិនព្រមស្ដាប់តាមការដាស់តឿនរបស់មនសិការដោយការដោះសារនានា ។ ពេលដែលអ្នកចូលរួមការស្រាវជ្រាវរបស់ខ្ញុំម្នាក់បានរំឭកថា « ខ្ញុំមានអារម្មណ៍រន្ធត់ចំពោះការរំលោភបំពានលើរាងកាយ ហើយក្រោយមកខ្ញុំគិតថា វាអាចនឹងមិនបានកើតឡើងទេ បើនាងគ្រាន់តែបិទមាត់នោះ » ។ « សេចក្ដីទុក្ខសោក [ របស់គាត់ ] ពុំនាំទៅរកសេចក្ដីប្រែចិត្ត » ( មរមន ២:១៣ ) ប៉ុន្តែផ្ទុយទៅវិញត្រូវបានរុញទៅម្ខាងជាមួយនឹងកំហឹង និងការបន្ទោសដ៏ជូរចត់ ។

នៅក្នុងការព្យាបាល មានម្ដងនោះខ្ញុំបានប្រាប់ភរិយាម្នាក់ថា ខ្ញុំពុំដែលបានឃើញនាងបង្ហាញទុក្ខព្រួយបែបដែលគាប់ព្រះហឫទ័យដល់ព្រះទេ រយៈពេលជាច្រើនឆ្នាំមកនេះគឺឃើញតែការរិះគន់ស្វាមីរបស់នាងប៉ុណ្ណោះ ។ ការឆ្លើយតបរបស់នាងគឺមិនមែនជាការសោកស្ដាយទេ ប៉ុន្តែការខឹង ៖ « ល្អ នេះជារឿងមួយទៀតដែលខ្ញុំនឹងមិនធ្វើទេ ! » មនុស្សដែលរំលោភបំពានបដិសេធការទទួលខុសត្រូវ ចិត្តស្រាល ហើយការពារខ្លួន ។ ពួកគេងាយនឹងអន់ចិត្តដោយសាររឿងតូចតាច ។

### *៤. អំនួត*

*« ចូររាប់អានគេឲ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ » ( ភីលីព ២:៣ ) ។*

អំនួតរួមមានការផ្ដល់សិទ្ធិ និងការផ្ដោតលើខ្លួនឯង ។ បុរសម្នាក់បញ្ចេញកំហឹងដាក់ភរិយា និងកូនៗគាត់ រាល់ពេលដែលគាត់គិតថា ពួកគេ « មិនគោរព » គាត់ ។ បើគំនិតរបស់ពួកគេមិនត្រូវនឹងគំនិតគាត់ទេ នោះពួកគេ « បន្ទាបបន្ថោក » គាត់ ឬ « មិនគោរពប្រតិបត្តិ » ។ អំនួតគឺមានការប្រកួតប្រជែង ហើយផ្ដោតលើអំណាច និងការយកឈ្នះ ។ ផ្ទុយទៅវិញ គ្រួសារដែលមានចំណងទាក់ទងល្អគឺមានការសហការគ្នា ដែលជាកន្លែងដែលមានតុល្យភាពនៃភាពយុត្តិធម៌ ហើយសមាជិកគ្រួសារ « មានការទាក់ទងគ្នាយ៉ាងត្រឹមត្រូវ » ( នីហ្វៃទី៤ ១:២ ) ។ ស្វាមីភរិយាគួរតែជាដៃគូស្មើភាពគ្នា[៩] ដែលម្នាក់ៗអាចផ្ដល់យោបល់ ហើយគំនិតទាំងអស់ត្រូវបានផ្ដល់តម្លៃឲ្យ ។

### *៥. ការត្រួតត្រា*

*« នៅពេលយើង . . . អនុវត្តការត្រួតត្រា ឬការគ្រប់គ្រង ឬការបង្ខិតបង្ខំទៅលើព្រលឹងនៃកូនចៅមនុស្ស . . . ស្ថានសួគ៌ដកខ្លួនចេញ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:៣៧ ) ។*

ទោះបីជាយើងឲ្យតម្លៃដល់សិទ្ធិជ្រើសរើស តែវាគួរឲ្យភ្ញាក់ផ្អើល ដែលជាញឹកញាប់ណាស់ សមាជិកគ្រួសារប្រាប់គ្នាទៅវិញទៅមកពីរបៀបដើម្បីគិត មានអារម្មណ៍ និងប្រព្រឹត្ត ។ អ្នកខ្លះថែមទាំងត្រួតត្រាតាមរយៈការបំភិតបំភ័យធ្វើឲ្យខ្មាស់ ដកសេចក្ដីស្រឡាញ់ ឬគំរាមកំហែង ។ ស្វាមីម្នាក់មានការរំពឹងដ៏តឹងរឹងពីភរិយាគាត់ ដោយថានាងគប្បីរៀបចំអាហារពេលព្រឹកជារៀងរាល់ថ្ងៃ នៅពេលជាក់លាក់មួយ បំពេញតាមការស្នើសុំភាពស្អិតស្អាលជាក់លាក់ ហើយស្ដាប់គាត់ចំពោះ « កង្វល់ » របស់គាត់ ដែលជាធម្មតារួមបញ្ចូលនូវរបៀបដែលនាងអាចធ្វើខ្លួនឲ្យប្រសើរឡើង ។ គាត់បានត្រួតពិនិត្យលើការចំណាយរបស់នាង ហើយខឹងសម្បាបើនាងមិនឆ្លើយតបទៅនឹងសាររបស់គាត់ឆាប់ៗ ។

ម្ដាយម្នាក់ទៀតបានបង្ហាញពីការខកចិត្តជារឿយៗចំពោះកូនស្រីជំទង់របស់គាត់ ពេលណាដែលកូនស្រីនោះបង្ហាញពីភាពសោកសៅ ឬមិនបានរស់នៅតាមស្តង់ដាររបស់ម្ដាយនោះទេ ។ ប្រសិនបើការរំពឹងទុកមិនត្រូវបានបំពេញ ឬបើស្វាមីរបស់គាត់បង្ហាញពីកង្វល់នានា នោះគាត់មិននិយាយស្ដីធ្វើព្រងើយ ។

## សេចក្ដីសង្ឃឹម និងការព្យាបាល

*« អញបានឮពាក្យអធិស្ឋានរបស់ឯង ក៏បានឃើញទឹកភ្នែកឯងហើយ មើលអញនឹងប្រោសឲ្យឯងបានជា » ( ពង្សាវតារក្សត្រ ទី២ ២០:៥ ) ។*

ទោះបីការរំលោភបំពានធ្វើឲ្យមានការឈឺចាប់ក្នុងចិត្ត ក៏ការផ្លាស់ប្ដូរអាចកើតមានឡើងបានជានិច្ច ។ ជនរងគ្រោះអាចស្វែងរកធនធានខាងវិញ្ញាណ និងអ្នកជំនាញ និងស្វែងរកព្រះចេស្ដាពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ដើម្បីព្យាបាលរបួសរបស់ពួកគេ ។ ដើម្បីស្វែងរកជំនួយ សូមចូលទៅកាន់គេហទំព័រ **abuse.ChurchofJesusChrist.org** ។



ពួកអ្នកដែលបានប្រព្រឹត្តការរំលោភបំពាន ត្រូវតែប្រែចិត្ត ហើយស្វែងរកជំនួយ ។ ការណ៍នេះតម្រូវឲ្យមានការ « ចុះទៅក្នុងជម្រៅនៃភាពទន់ទាប » ( នីហ្វៃទី៣ ១២:២ ) ហើយទទួលយកការទទួលខុសត្រូវពេញលេញសម្រាប់សកម្មភាពរបស់ពួកគេ ។ ការផ្លាស់ប្តូរត្រូវការលើសពីការសន្យារយៈពេលខ្លី និងការប្រឹងប្រែងតែខាងក្រៅ ។ ការឈឺចាប់នៃការប្រែចិត្តដ៏ជ្រាលជ្រៅ គឺការឈឺចាប់ក្នុងព្រលឹង ហើយមនុស្សខ្លះមិនមានឆន្ទៈនឹងធ្វើវាទេ ដែលធ្វើឲ្យជនរងគ្រោះមានការសម្រេចចិត្តដ៏លំបាកទៅលើវិធីដើម្បីការពារខ្លួនពួកគេ ។[៩]

ព្រះវរបិតាសួគ៌មានព្រះទ័យព្រួយបារម្ភពីយើង គឺដូចជាឪពុកដ៏ព្រួយបារម្ភ ដែលបានទូរសព្ទមកខ្ញុំអំពីកូនស្រីរបស់គាត់ដែរ ។ សេចក្តីស្រឡាញ់របស់ព្រះគឺ « រីកទូលំទូលាយដូចជាភាពដ៏អស់កល្បជានិច្ច » ( ម៉ូសេ ៧:៤១ ) ហើយទ្រង់មានការឈឺចាប់យ៉ាងខ្លាំង ពេលបុត្ររបស់ទ្រង់ធ្វើបាបគ្នាទៅវិញទៅមក ។ នៅក្នុងការសន្ទនាដ៏ទន់ភ្លន់ជាមួយហេណុក ទ្រង់បានព្រះកន្សែង ។ « នេះគឺជាពួកបងប្អូនរបស់អ្នក ពួកគេជាផលនៃដៃយើងផ្ទាល់ . . . ហើយទាំង [ បាន ] ប្រទានបញ្ញត្តិមួយថា ពួកគេត្រូវស្រឡាញ់គ្នាទៅវិញទៅមក . . . ប៉ុន្តែមើលចុះ ពួកគេគ្មានសេចក្តីស្រឡាញ់ទេ ហើយពួកគេស្អប់ឈាមខ្លួនឯងទៅវិញ » ( ម៉ូសេ ៧:៣២–៣៣ ) ។ មានការយំនៅស្ថានសួគ៌ និងនៅផែនដី ពេលដែលរាងកាយ និងព្រលឹងត្រូវរងរបួស ។ ប៉ុន្តែ ជាមួយនឹងការបន្ទាបខ្លួន ព្រះចេស្ដារបស់ព្រះ និងជំនួយពីអ្នកជំនាញ នៅពេលដែលចាំបាច់ នោះវាអាចបញ្ឈប់នូវសកម្មភាពដ៏បំផ្លិចបំផ្លាញ ហើយបង្កើតគេហដ្ឋានមួយដែលមានសេចក្តីថ្លៃថ្នូរ សុវត្ថិភាព និងសេចក្តីស្រឡាញ់បាន ។ ■

កំណត់ចំណាំ

១. សម្រាប់ព័ត៌មានបន្ថែមស្ដីអំពីអំពើហឹង្សាលើរាងកាយ សូមមើលនៅគេហទំព័រ abuse.ChurchofJesusChrist.org ។ សម្រាប់ព័ត៌មានបន្ថែមអំពីការរំលោភបំពានផ្លូវភេទ សូមមើល Benjamin M. Ogles, "Agency, Accountability, and the Atonement of Jesus Christ: Application to Sexual Assault" ( ការប្រជុំធម្មនិដ្ឋាននៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨ ) speeches.byu.edu និង Chieko N. Okazaki, "Healing from Sexual Abuse" ( សន្និសីទនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០២ ) ។
២. សូមមើល Maryam Ajilian Abbasi, Masumeh Saeidi, Gholamreza Khademi, Bibi Leila Hoseini, Zahra Emami Moghadam, "Child Maltreatment in the World: A Review Article," *International Journal of Pediatrics,* វ៉ុល ៣ លេខ ១ ( ឆ្នាំ ២០១៤ ) ទំព័រ ៣៥៣–៦៥ ។
៣. សូមមើល Hamby, S., "Current controversies: Are women really as violent as men? The 'gender symmetry' controversy," in Claire M. Renzetti, Jeffrey L. Edleson, and Raquel Kennedy Bergen, *Sourcebook on Violence Against Women,* កំណែទី៣ ( ឆ្នាំ ២០១៨ ) ទំព័រ ៧៨–៨២ ។
៤. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ១៤៥ សូមមើលផងដែរ abuse.ChurchofJesusChrist.org ។
៥. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។
៦. Jason B. Whiting, Megan Oka, and Stephen T. Fife, "Appraisal distortions and intimate partner violence: Gender, power, and interaction," *Journal of Marital and Family Therapy* (2012), suppl: 1:113–49 ។
៧. សម្រាប់គំរូនៃការមិនសប្បាយចិត្តនឹងសេចក្ដីពិតពីព្រះគម្ពីរផ្សេងទៀត សូមមើល យ៉ូហាន ៣:១៩–២១; កិច្ចការ ៧:៥៤; នីហ្វៃទី២ ១:២៥–២៦ និង នីហ្វៃទី២ ៤:១៣ ។
៨. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » សូមមើលផងដែរ H. Burke Peterson, "Unrighteous Dominion," *Ensign,* ខែ កក្កដា ឆ្នាំ ១៩៨៩ ទំព័រ ៦–១១ សម្រាប់ព័ត៌មានបន្ថែមទៀតអំពីគោលលទ្ធិនៃសមភាព និងសំណួរនានាដើម្បីពិចារណា ទាក់ទងទៅនឹងចំណងទាក់ទងក្នុងសេចក្ដីសញ្ញា ។
៩. អ្នកដែលនៅក្នុងស្ថានភាពរំលោភបំពាន ជាញឹកញាប់ប្រឈមមុខនឹងជម្រើសអំពីវិធីដើម្បីការពារសុវត្ថិភាពរបស់ខ្លួនពួកគេផ្ទាល់ ឬរបស់អ្នកផ្សេងទៀត ក៏ដូចជាថាតើពួកគេត្រូវដាក់កម្រិតព្រំដែន ឬកម្រិតការប្រាស្រ័យទាក់ទងរបស់ពួកគេជាមួយនឹងពួកមនុស្សដែលគ្មានមេត្តាទាំងនោះ ។ ប្រធាន ជេមស៍ អ៊ី ហ្វោស្ត ( ១៩២០–២០០៧ ) បានពិភាក្សាពីស្ថានភាពដ៏លំបាកនៅពេលនរណាម្នាក់ជាប់នៅក្នុង « ចំណងទាក់ទងដែលយូរអង្វែង និងមិនអាចកែកុនបាន ដែលបំផ្លាញដល់ភាពថ្លៃថ្នូររបស់មនុស្សក្នុងនាមជាមនុស្សលោកម្នាក់ » ( « Enriching Your Marriage » *Liahona,* ខែ មេសា ឆ្នាំ ២០០៧ ទំព័រ ៣ ) សូមមើលផងដែរនៅផ្នែក « Help for Victims » នៅគេហទំព័រការការពារការរំលោភបំពានរបស់ព្រះវិហារដើម្បីបានព័ត៌មាន និងជម្រើសបន្ថែមទៀត ។



## ស្វែងរកបន្ថែមទៀត

**ដើម្បីស្វែងរកព័ត៌មានបន្ថែមទៀត ឬដើម្បីទាក់ទងទៅអ្នកជំនាញ និងធនធានដ៏មានប្រយោជន៍ផ្សេងៗទៀត សូមចូលទៅកាន់គេហទំព័រការរំលោភបំពានរបស់សាសនាចក្រ abuse.ChurchofJesusChrist.org ។**

**ដើម្បីរៀនបន្ថែមទៀតអំពីវិធីជួយជនរងគ្រោះ សូមអានរបារចំហៀង « តើខ្ញុំអាចជួយដោយរបៀបណា ? សម្រាប់មិត្តភក្តិ និងថ្នាក់ដឹកនាំ » នៅក្នុងកំណែឌីជីថលនៃអត្ថបទនេះនៅលើគេហទំព័រ liahona.ChurchofJesusChrist.org ឬនៅក្នុងកម្មវិធី Gospel Library ( បណ្ណាល័យដំណឹងល្អ ) ។**

## ធនធានសម្រាប់ថ្នាក់ដឹកនាំ

**ថ្នាក់ដឹកនាំដែលដឹងពីការរំលោភបំពាន ដែលមានអនីតិជនចូលរួមជាជនរងគ្រោះ ឬជាសាក្សី គប្បីទាក់ទងទៅខ្សែទូរសព្ទជំនួយដែលមាននៅ counselingresources.ChurchofJesusChrist.org ។**





រចនារូបភាពដោយ ម៉ៃឃល ហ្វីខាន



**ដោយ អែលឌើរ លូវ៉ែន អ៊ី ខូប្រ៊ីតហ្គ**

អតីតសមាជិកនៃពួកចិតសិបនាក់

# ឈរលើ សិលានៃវិវរណៈ

*ដោយការចាក់គ្រឹះនៅលើសិលានៃវិវរណៈ នោះយើងអាចរកឃើញចម្លើយចំពោះសំណួរដែលសំខាន់បំផុតនានា ។*

ជាផ្នែកមួយនៃការចាត់តាំងដែលខ្ញុំបានមាន ក្នុងនាមជាអ្នកមានសិទ្ធិអំណាចទូទៅម្នាក់ កាលពីពីរបីឆ្នាំមុន ខ្ញុំបានអានជាច្រើននូវឯកសារដែលប្រឆាំងនឹងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ព្យាការី យ៉ូសែប ស៊្មីធ ព្រះគម្ពីរមរមន និងព្រឹត្តិការណ៍នានានៃការស្តារឡើងវិញ ។ ដោយសារការចាត់តាំងនោះបានផ្លាស់ប្តូរ ខ្ញុំពុំបានត្រឡប់ទៅននៀលក្នុងភក់នោះទៀតទេ ។

ការអានឯកសារនោះតែងតែបន្សល់ទុកនូវអារម្មណ៍ស្រពាប់ស្រពោនដល់ខ្ញុំ ហើយថ្ងៃមួយអារម្មណ៍នៃភាពងងឹតនោះបានបំផុសខ្ញុំឲ្យសរសេរការឆ្លើយតបខ្លះទៅកាន់ការអះអាងដែលប្រឆាំងទាំងនោះ ។ ខ្ញុំសូមចែកចាយគំនិតមួយចំនួន ដែលខ្ញុំបានកត់ត្រានៅថ្ងៃនោះ ហើយទោះបីអ្វីដែលខ្ញុំបានសរសេរនោះសម្រាប់ជាប្រយោជន៍ដល់ខ្លួនខ្ញុំមែន ខ្ញុំក៏បានសង្ឃឹមថា វានឹងជួយដល់បងប្អូនផងដែរ ។

### តើយើងនឹងស្ថិតស្ថេររហូតឬ ?

ព្យាការីដានីយ៉ែលបាននិយាយថា នៅក្នុងថ្ងៃចុងក្រោយ « ព្រះនៃស្ថានសួគ៌ទ្រង់នឹងតាំងនគរ១ឡើង ដែលមិនត្រូវបំផ្លាញឡើយ ហើយអំណាចហ្លួងក៏មិនត្រូវផ្ទេរដល់សាសន៍ដទៃណាដែរ គឺនឹងបំបាក់បំបែក ហើយលេបបំបាត់នគរទាំងនោះវិញ នគរនោះនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច » ( ដានីយ៉ែល ២:៤៤ ) ។

នគរនៃព្រះនោះគឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ វានឹង « ស្ថិតស្ថេរនៅអស់កល្បជានិច្ច » ។ សំណួរនោះគឺថា តើបងប្អូន និងខ្ញុំស្ថិតស្ថេរ ឬ « [ យើង ] ថយទៅដែរឬ ? »( យ៉ូហាន ៦:៦៧ ) ។ ហើយបើយើងដកខ្លួនចេញ តើយើងនឹងទៅណា ?



**ការបោកបញ្ឆោតគឺជាទីសម្គាល់មួយនៃជំនាន់របស់យើង**

ពេលព្រះអម្ចាស់ពិពណ៌នាអំពីទីសម្គាល់ទាំងឡាយនៃការយាងមករបស់ទ្រង់ និងចុងបញ្ចប់នៃផែនដីនេះ ទ្រង់បានមានព្រះបន្ទូលពីរឿងជាច្រើន រួមទាំងចំបាំង និងដំណឹងពីចំបាំងទាំងឡាយ ជាតិសាសន៍ក្រោកឡើងប្រឆាំងនឹងជាតិសាសន៍ អំណត់អត់ឃ្លានរាតត្បាត រញ្ជួយ ផែនដី និងទីសម្គាល់ផ្សេងៗទៀតជាច្រើន រួមទាំងមួយនេះផងដែរ ៖ « ត្បិតនៅគ្រានោះ [ ជំនាន់នេះ ] នឹងមានព្រះគ្រីស្ទក្លែងក្លាយ ហើយព្យាការីក្លែងក្លាយកើតឡើង ហើយនឹងបង្ហាញទីសម្គាល់យ៉ាងធំ និងការអស្ចារ្យ ដរាបដល់ពួកគេអាចបញ្ឆោតទាំងពួករើសតាំង ដែលជាពួករើសតាំង ស្របតាមសេចក្ដីសញ្ញា បើសិនជាធ្វើទៅបាន » ( យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:២២ សូមមើលផងដែរ ម៉ាថាយ ២៤:២៤ ) ។

ខ្ញុំមិនប្រាកដទេអំពីគុណសម្បត្តិទាំងអស់ដែលត្រូវបានបរិយាយនោះ « ពួកគេអាចបញ្ឆោតទាំងពួករើសតាំង . . . បើសិនជាធ្វើទៅបាន » ប៉ុន្តែខ្ញុំគិតថា វាមានន័យថា យ៉ាងហោចណាស់មនុស្សគ្រប់គ្នានឹងប្រឈមនឹងការបោកបញ្ឆោតនោះនៅក្នុងជំនាន់របស់យើង ។

មានមនុស្សជាច្រើនដែលបោកបញ្ឆោត ហើយវិសាលគមនៃការបោកបញ្ឆោតគឺទូលំទូលាយណាស់ ។ វិសាលគមមួយដែលយើងជួប ជាពួកអ្នកដែលវាយប្រហារលើការស្ដារឡើងវិញ ព្យាការី យ៉ូសែប ស្ម៊ីធ និងព្រះគម្ពីរមរមន ។ មួយប្រភេទទៀត យើងឃើញពួកអ្នកដែលជឿលើការស្ដារឡើងវិញ ប៉ុន្តែអះអាងថា សាសនាចក្រនៅខ្វះចន្លោះ ហើយក៏បានវង្វេងទៅ ។ អ្នកផ្សេងទៀតអះអាងថាជឿលើការស្ដារឡើងវិញ ប៉ុន្តែស្រងាកចិត្តនឹងគោលលទ្ធិដែលមិនត្រូវនឹងតរិយាបថកំពុងផ្លាស់ប្ដូរនៃជំនាន់របស់យើង ។ មនុស្សខ្លះមិនមានសិទ្ធិអំណាចទេ តែបានអះអាងថាបានឃើញការនិមិត្ត សុបិន និងមានដំណើរទស្សនកិច្ចទៅកាន់សាសនាចក្រដែលពិត ដែលដឹកនាំយើងទៅកាន់ផ្លូវដែលកាន់តែខ្ពង់ខ្ពស់ ឬរៀបចំសាសនាចក្រសម្រាប់ទីបញ្ចប់នៃលោកិយនេះ ។ មនុស្សផ្សេងទៀតត្រូវបានបោកបញ្ឆោតដោយវិញ្ញាណក្លែងក្លាយ ។

នៅវិសាលគមផ្សេងទៀត យើងមកដល់សកលលោកទាំងមូលដែលពោរពេញដោយការរំខាន ។ មិនដែលមានពេលណាដែលយើងមានព័ត៌មានច្រើនយ៉ាងនេះទេ ទាំងព័ត៌មានមិនពិត និងការផ្សព្វផ្សាយព័ត៌មានមិនពិត ទំនិញ គ្រឿងកម្សាន្ត និងល្បែងកាន់តែច្រើន ហើយកាន់តែមានជម្រើសច្រើន កន្លែងកាន់តែច្រើនដើម្បីទៅ ព្រមទាំងអ្វីៗដើម្បីទស្សនា និងធ្វើកាន់តែច្រើន ដើម្បីប្រើពេលវេលា និងទាញការយកចិត្តទុកដាក់ពីអ្វីដែលសំខាន់បំផុត ។ អ្វីៗទាំងអស់នោះ និងជាច្រើនទៀត ត្រូវបានផ្សព្វផ្សាយយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក តាមប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច ។ នេះគឺជាជំនាន់នៃការបោកបញ្ឆោត ។

**ការចេះដឹងគឺចាំបាច់ណាស់**

សេចក្ដីពិតធ្វើឲ្យយើងឃើញកាន់តែច្បាស់ ដោយសារវាគឺជា « ការចេះដឹងអំពីការណ៍ទាំងឡាយដែលមាននៅពេលនេះ និងការណ៍ទាំងឡាយដែលមានមកហើយ ហើយនិងការណ៍ទាំងឡាយដែលនឹងមាននៅខាងមុខ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៤ ) ។ ការចេះដឹងគឺចាំបាច់ណាស់ ដើម្បីចៀសវាងពីការបោកបញ្ឆោត ដើម្បីញែកចេញរវាងសេចក្ដីពិត និងកំហុស និងដើម្បីមើលឃើញកាន់តែច្បាស់ ហើយរកឃើញវិធីដើម្បីចៀសវាងពីគ្រោះថ្នាក់នានានៅក្នុងជំនាន់របស់យើង ។

ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា ៖ « ការចេះដឹងគឺចាំបាច់ដល់ជីវិត និងការគោរពព្រះ ។ . . . ការចេះដឹងគឺជាវិវរណៈ ។ សូមស្ដាប់តាម . . . គន្លឹះដ៏មហិមានេះ ៖ ការចេះដឹងគឺជាអំណាចនៃព្រះឈានទៅរកសេចក្ដីសង្គ្រោះ » ។[១]

មនុស្សនិយាយថា « អ្នកគួរតែស្មោះត្រង់ចំពោះជំនឿរបស់អ្នក » ។ ខណៈដែលវាជាការពិត បងប្អូនពុំអាចបានប្រសើរជាងអ្វីដែលបងប្អូនបានដឹងនោះទេ ។ ពួកយើងភាគច្រើនបំផុត ធ្វើសកម្មភាពដោយផ្អែកទៅលើជំនឿរបស់យើង ជាពិសេសអ្វីដែលយើងជឿថាជាប្រយោជន៍ផ្ទាល់ខ្លួន ។ បញ្ហានោះគឺថា ពេលខ្លះយើងខុស ។

មនុស្សខ្លះអាចនឹងជឿលើព្រះ ហើយថារឿងអាគ្រាមគឺខុសឆ្គង ប៉ុន្តែនៅតែចុចលើគេហទំព័រអាគ្រាមដោយជឿទាំងខុសថា ពួកគេនឹងរីករាយជាងបើពួកគេធ្វើដូច្នោះ ឬថាពួកគេមិនអាចទប់បានទេ ឬថាពួកគេមិនបានធ្វើឲ្យនរណាផ្សេងទៀតឈឺចាប់នោះឡើយ ។ ពួកគេខុសហើយ ។

មនុស្សផ្សេងទៀតអាចនឹងជឿថា វាខុសក្នុងការកុហក ប៉ុន្តែនៅតែកុហកនៅពេលខ្លះ ដោយជឿទាំងខុសថា ពួកគេនឹងមិនអីទេបើមិនមាននរណាដឹងការពិតទេនោះ ។ ពួកគេខុសហើយ ។

មនុស្សម្នាក់អាចនឹងជឿ ហើយថែមទាំងដឹងថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយនៅតែបដិសេធទ្រង់មិនត្រឹមតែម្ដងទេ តែដល់ទៅបីដង ដោយសារតែជំនឿខុសឆ្គងថា ការបំពេញតាមចិត្តរបស់ក្រុមមនុស្សនោះគឺប្រសើរជាង ។ ពេត្រុសមិនមែនអាក្រក់ទេ ។ ខ្ញុំមិនប្រាកដទេថា គាត់ទន់ខ្សោយនោះ ។ គាត់ពិតជាខុសហើយ ។ ( សូមមើល ម៉ាថាយ ២៦:៣៤, ៦៩–៧៥ ) ។

ពេលយើងប្រព្រឹត្តមិនល្អ យើងអាចនឹងគិតថាយើងអាក្រក់ ពេលដែលការពិតទៅ យើងគ្រាន់តែខុស ។ ឧបសគ្គនោះគឺមិនមែនជាការបិទគម្លាតរវាងសកម្មភាពរបស់យើង និងជំនឿរបស់យើងនោះទេ ប៉ុន្តែ ឧបសគ្គនោះគឺការបិទគម្លាតរវាងជំនឿរបស់យើង និងសេចក្ដីពិត ។



តើយើងអាចបិទគម្លាតនោះយ៉ាងដូចម្ដេច ? តើយើងចៀសវាងពីការបោកបញ្ឆោតយ៉ាងដូចម្ដេច ?

**សំណួរចម្បង និងសំណួរបន្ទាប់បន្សំ**

មានសំណួរចម្បង និងមានសំណួរបន្ទាប់បន្សំ ។ សូមចាប់ផ្ដើមដោយការឆ្លើយដល់សំណួរចម្បងជាមុន ។ សំណួរចម្បងគឺសំខាន់បំផុត ។ មានសំណួរចម្បងតែមួយចំនួនប៉ុណ្ណោះ ។ ខ្ញុំសូមលើកឡើងបួនសំណួរ ៖

១. តើមានព្រះមួយអង្គជាព្រះវរបិតារបស់យើងឬ ?
២. តើព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះនៃពិភពលោកឬ ?
៣. តើយ៉ូសែបស្ម៊ីធជាព្យាការីម្នាក់ឬ ?
៤. តើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជានគរព្រះនៅលើផែនដីនេះឬ ?

ផ្ទុយទៅវិញ សំណួរបន្ទាប់បន្សំគឺមិនមានទីបញ្ចប់ទេ ។ សំណួរទាំងនោះរួមមានសំណួរអំពី ប្រវត្តិសាស្ត្រសាសនាចក្រ, ពហុអាពាហ៍ពិពាហ៍, ប្រជាជនដើមកំណើតអាហ្វ្រិក និងបព្វជិតភាព, ស្ត្រី និងបព្វជិតភាព, ការបកប្រែនៃព្រះគម្ពីរមរមន, មុក្ដាដ៏មានតម្លៃមហិមា, DNA និងព្រះគម្ពីរមរមន, អាពាហ៍ពិពាហ៍ភេទដូចគ្នា, ដំណើររឿងផ្សេងៗគ្នានៃការនិមិត្តដំបូង ។ល។ និង ។ល។

ប្រសិនបើបងប្អូនឆ្លើយសំណួរចម្បង នោះសំណួរបន្ទាប់បន្សំនឹងត្រូវបានឆ្លើយផងដែរ ឬវាហាក់មិនសូវសំខាន់ពេកនោះទេ ។ ចូរឆ្លើយសំណួរចម្បងទាំងឡាយ នោះបងប្អូនអាចដោះស្រាយនឹងរឿងដែលបងប្អូនយល់ និងរឿងដែលបងប្អូនមិនយល់ ក៏ដូចជារឿងដែលបងប្អូនយល់ស្រប និងរឿងដែលបងប្អូនមិនយល់ស្រប ដោយមិនបាច់ចាកចេញពីសាសនាចក្រ ។

**វិធីសាស្ត្រដ៏ទេវភាពនៃការរៀនសូត្រ**

មានវិធីសាស្ត្រនៃការរៀនសូត្រខុសៗគ្នា រួមមាន វិធីសាស្ត្រខាងវិទ្យាសាស្ត្រ ខាងការវិភាគ ខាងសិក្សាមុខវិជ្ជា និងវិធីសាស្ត្រដ៏ទេវភាព ។ វិធីសាស្ត្រទាំងបួននេះគឺចាំបាច់ដើម្បីដឹងអំពីសេចក្ដីពិត ។ វិធីសាស្ត្រទាំងអស់ចាប់ផ្ដើមតាមរបៀបដូចគ្នា ៖ ជាមួយនឹងសំណួរមួយ ។ សំណួរគឺសំខាន់ជាពិសេសសំណួរចម្បងទាំងឡាយ ។

វិធីសាស្ត្រដ៏ទេវភាពនៃការរៀនសូត្រ រួមបញ្ចូលនូវធាតុទាំងឡាយរបស់វិធីសាស្ត្រផ្សេងៗទៀត ប៉ុន្តែនៅទីបំផុត ឈ្នះលើអ្វីៗផ្សេងទៀតទាំងអស់ ដោយការចូលទៅក្នុងអំណាចនៃស្ថានសួគ៌ ។ នៅទីបំផុត ការណ៍ទាំងឡាយរបស់ព្រះត្រូវបានធ្វើឲ្យយល់ដឹងដោយព្រះវិញ្ញាណនៃព្រះ ដែលជាធម្មតាជាសំឡេងតូចរហៀង ។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា « ព្រះទ្រង់នឹងប្រទានតម្រិះដល់អ្នកដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ មែនហើយ ដោយអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដែលពុំអាចប្រាប់បាន » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:២៦ ) ។

សាវកប៉ុលបានបង្រៀនថា យើងមិនអាចដឹងពីការណ៍ទាំងឡាយរបស់ព្រះឡើយ លើកលែងតែតាមរយៈព្រះវិញ្ញាណនៃព្រះប៉ុណ្ណោះ ( សូមមើល កូរិនថូស ទី១ ២:៩–១១ សូមមើលផងដែរ ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ កូរិនថូស ទី១ ២:១១ ) ។ លោកបាននិយាយថា « មនុស្សខាងសាច់ឈាមគេមិនទទួលសេចក្ដីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ » ។ យើងឃើញការណ៍នោះជារៀងរាល់ថ្ងៃ ។ ប៉ុលបានបន្តទៀតថា « ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្ដីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ » ( កូរិនថូស ទី១ ២:១៤ ) ។

ក្នុងចំណោមបញ្ហាទាំងអស់ដែលបងប្អូនជួបប្រទះក្នុងជីវិត មានមួយសំខាន់ជាងគេទាំងអស់ ហើយជាអ្វីដែលបានយល់តិចបំផុត ។ ស្ថានភាពដ៏អាក្រក់បំផុតនៃមនុស្សលោកទាំងអស់ គឺមិនមែន





ភាពក្រីក្រ ការឈឺ ភាពឯកោ ការរំលោភបំពាន ឬសង្គ្រាមនោះទេ—ថ្វីបើស្ថានភាពទាំងនោះវាគួរឱ្យខ្លាចយ៉ាងណាក្ដី ។ ស្ថានភាពដ៏អាក្រក់បំផុតនៃមនុស្សលោកទាំងអស់ គឺសាមញ្ញបំផុត ៖ វាគឺជាការស្លាប់ខាងវិញ្ញាណ ។ វាគឺការត្រូវបំបែកចេញពីវត្តមានរបស់ព្រះ ហើយនៅក្នុងជីវិតនេះ វត្តមានរបស់ទ្រង់គឺជាព្រះវិញ្ញាណ និងព្រះចេស្ដារបស់ទ្រង់នោះឯង ។

ផ្ទុយទៅវិញ ស្ថានភាពដ៏ល្អបំផុតនៃមនុស្សលោកទាំងអស់ គឺមិនមែន ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ កិត្យានុភាព សុខភាពល្អ កិត្តិយសរបស់មនុស្ស តើមានអ្វីផ្សេងទៀតដែលព្រះអង្គសង្គ្រោះ និងពួកព្យាការីនិងពួកសាវកនៃ ពួកបរិសុទ្ធថ្ងៃចុងក្រោយ បានបង្រៀនអំពីការអេធិស្ឋាន ឬ សន្តិសុខ នោះ ស្ថានភាពដ៏ល្អបំផុតនៃមនុស្សលោកទាំងអស់ គឺការបានទទួលអំណោយពិសិដ្ឋពីអំណាចនៃស្ថានសួគ៌ ។ វាគឺជាការបានកើតម្ដងទៀត បានទទួលអំណោយ និងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ដែលជាប្រភពនៃការចេះដឹង វិវរណៈ កម្លាំង ភាពច្បាស់លាស់ សេចក្ដីស្រឡាញ់ អំណរ ភាពសុខសាន្ត ក្ដីសង្ឃឹម ទំនុកចិត្ត សេចក្ដីជំនឿ និងស្ទើរតែគ្រប់អស់អ្វីៗដែលល្អ ។

ព្រះយេស៊ូវបានមានព្រះបន្ទូល ៖ « ព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ . . . នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់ » ( យ៉ូហាន ១៤:២៦ ) ។ វាគឺជាអំណាចដែលឲ្យយើង « អាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ » ( ម៉ូរ៉ូណៃ ១០:៥ ) ។ « ព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញ . . . ដល់ [ យើង] នូវគ្រប់អ្វីទាំងអស់ ដែល [ យើង ] ត្រូវធ្វើ » ( នីហ្វៃទី២ ៣២:៥ ) ។ វាគឺជាប្រភពនៃ « ទឹករស់ » ដែលលាស់ទៅកាន់ជីវិតដ៏អស់កល្បជានិច្ច ( យ៉ូហាន ៧:៣៨ សូមមើល ខ ៣៧ ផងដែរ ) ។

បង់ថ្លៃអ្វីក៏ដោយដែលបងប្អូនត្រូវបង់ ទទួលបន្ទុកអ្វីក៏ដោយដែលបងប្អូនត្រូវទទួល ហើយធ្វើការលះបង់អ្វីក៏ដោយដែលបងប្អូនត្រូវលះបង់ ដើម្បីទទួល និងរក្សាវិញ្ញាណ និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់បងប្អូន ។ គ្រប់ការណ៍ល្អទាំងអស់ពឹងផ្អែកទៅលើការទទួល និងការរក្សាព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធក្នុងជីវិតរបស់បងប្អូន ។

### « អ្វីដែលពុំបានស្អាងឡើង »

ដូច្នេះ តើអ្វីទៅដែលជាភាពស្រពាប់ស្រពោនដែលខ្ញុំបានមានអារម្មណ៍ កាលពីប៉ុន្មានឆ្នាំមុន ខណៈពេលអានឯកសារប្រឆាំងទាំងនោះ ? អ្នកខ្លះអាចនឹងនិយាយថា ភាពស្រពាប់ស្រពោននោះគឺជាផលនៃភាពលំអៀងខាងជំនឿ ដែលជាទំនោរក្នុងការជ្រើសរើសតែការណ៍ទាំងឡាយដែលស្របទៅនឹងការសន្មត់ និងជំនឿរបស់យើង ។ គំនិតដែលថា អ្វីៗគ្រប់យ៉ាងដែលមនុស្សម្នាក់បានជឿ និងត្រូវបានបង្រៀន អាចជាការខុសឆ្គង ជាពិសេសពេលគ្មានអ្វីដែលល្អប្រសើរជាង គឺពិតជាគំនិតដ៏ស្រពាប់ស្រពោន និងដែលគួរឲ្យបារម្ភ ។

ប៉ុន្តែភាពស្រពាប់ស្រពោនដែលខ្ញុំបានដកពិសោធ ពេលដែលខ្ញុំបានស្ដាប់ដល់សំឡេងនៃក្រុមចម្រៀងដ៏ងងឹតងងុលដែលស្រែកទាស់នឹងព្យាការី យ៉ូសែប ស៊្មីធ និងការស្ដារឡើងវិញនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ គឺខុសពីនោះ ។ ភាពស្រពាប់ស្រពោននោះមិនមែនជាការលំអៀងខាងជំនឿទេ ហើយវាមិនមែនការភ័យខ្លាចថាខុសនោះទេ ។ វាគឺជាអវត្តមាននៃព្រះវិញ្ញាណរបស់ព្រះ ។ វាគឺជាស្ថានភាពរបស់មនុស្ស ពេលដែល « គេនៅតែម្នាក់ឯង » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២១:៣៨ ) ។ វាគឺជាភាពស្រពាប់ស្រពោននៃភាពងងឹត និង « អាប់គំនិត » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩:៩ សូមមើល ខ ៨ ផងដែរ ) ។

ព្រះអម្ចាស់បានមានព្រះបន្ទូលដូចនេះ ៖

« ហើយអ្វីដែលពុំបានស្អាងឡើង នោះពុំមែនមកពីព្រះទេ តែមកពីសេចក្ដីងងឹតវិញ ។

« អ្វីដែលមកពីព្រះ ជាពន្លឺ ហើយអ្នកណាដែលទទួលពន្លឺ ហើយនៅជាប់ក្នុងព្រះ នោះទទួលពន្លឺថែមទៀត ហើយពន្លឺនោះភ្លឺកាន់តែខ្លាំងឡើងៗ រហូតដល់ថ្ងៃបានល្អឥតខ្ចោះ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៥០:២៣–២៤ ) ។

វិវរណៈពីព្រះវិញ្ញាណនៃព្រះជំនួសឲ្យការលំអៀងខាងជំនឿ ដោយសារវាមិនសំអាងតែទៅលើភស្តុតាងប៉ុណ្ណោះទេ ។ ខ្ញុំបានចំណាយពេលអស់មួយជីវិតក្នុងការព្យាយាមដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយរៀនស្គាល់ និងធ្វើតាមព្រះវិញ្ញាណនៃព្រះ ។ វិញ្ញាណដែលទាក់ទងនឹងសំឡេងងងឹតដែលវាយប្រហារព្យាការី យ៉ូសែប ស៊្មីធ ព្រះគម្ពីរមរមន និងការស្ដារឡើងវិញ ពុំមែនជាវិញ្ញាណនៃពន្លឺ ប្រាជ្ញា និងសេចក្ដីពិតទេ ។ ខ្ញុំមិនដឹងអ្វីច្រើនទេ ប៉ុន្តែខ្ញុំស្គាល់ព្រះសូរសៀងរបស់ព្រះអម្ចាស់ និងព្រះសូរសៀងរបស់ទ្រង់ពុំនៅក្នុងក្រុមចម្រៀងងងឹតងងុលនោះទេ ។

ផ្ទុយស្រឡះនឹងភាពស្រពាប់ស្រពោន និងការអាប់គំនិតដ៏គួរឲ្យរំខាន ដែលធ្វើឲ្យជ្រួតជ្រាបនូវល្បាប់នៃការសង្ស័យ នោះគឺវិញ្ញាណនៃពន្លឺ ប្រាជ្ញា ភាពសុខសាន្ត និងសេចក្ដីពិត ដែលមានវត្តមាននៅក្នុងព្រឹត្តិការណ៍នានា និងគោលលទ្ធិដ៏រុងរឿងនៃការស្ដារឡើងវិញ ជាពិសេសព្រះគម្ពីរទាំងឡាយដែលបានបើកសម្ដែងដល់ពិភពលោកតាមរយៈព្យាការី យ៉ូសែប ស៊្មីធ ។ សូមអានវា ហើយសួរខ្លួនឯង និងព្រះ ថាបើវាជាពាក្យកុហក បោកបញ្ឆោត និងការបំភាន់ ឬថាបើវាគឺជាសេចក្ដីពិត ។

**បងប្អូនពុំអាចរៀនពីសេចក្តីពិតដោយការលប់បំបាត់នោះទេ**

មនុស្សខ្លះដែលភ័យខ្លាចថា សាសនាចក្រអាចជាមិនពិត ចំណាយពេល និងការយកចិត្តទុកដាក់របស់ពួកគេក្នុងការពុះពារឥតឈប់ឈរឆ្លងកាត់ល្បាប់នៃសំណួរបន្ទាប់បន្សំ ។ ពួកគេព្យាយាមទាំងខុសឆ្គង ដើម្បីរៀនសេចក្តីពិតតាមរយៈដំណើរការនៃការលប់បំបាត់ ដោយការព្យាយាមលប់បំបាត់គ្រប់ការសង្ស័យ ។ នោះតែងតែជាគំនិតដ៏អាក្រក់មួយ ។ វានឹងមិនដែលបានសម្រេចឡើយ ។

មាននូវការអះអាង និងគំនិតរាប់មិនអស់ ដែលប្រឆាំងនឹងសេចក្តីពិត ។ រាល់ពេលដែលបងប្អូនរកឃើញចម្លើយចំពោះការអះអាងដែលប្រឆាំងមួយ នោះបងប្អូនក៏ជួបនឹងការអះអាងប្រឆាំងមួយទៀត ។ ខ្ញុំមិនមែននិយាយថា បងប្អូនគួរតែកប់ក្បាលរបស់បងប្អូនទៅក្នុងខ្សាច់នោះទេ ប៉ុន្តែខ្ញុំមានន័យថា បងប្អូនអាចចំណាយពេលអស់មួយជីវិតប្រឹងប្រែងយ៉ាងខ្លាំងស្វែងរកចម្លើយចំពោះគ្រប់ការអះអាងដែលប្រឆាំងនឹងសាសនាចក្រ ប៉ុន្តែមិនដែលបានមកដល់ការចេះដឹងមួយអំពីសេចក្តីពិតដ៏សំខាន់បំផុតនោះទេ ។

ចម្លើយចំពោះសំណួរចម្បងទាំងឡាយ ពុំបានមកដោយការឆ្លើយនឹងសំណួរបន្ទាប់បន្សំទាំងនោះទេ ។ មានចម្លើយនានាចំពោះសំណួរបន្ទាប់បន្សំទាំងនោះ ប៉ុន្តែបងប្អូនពុំអាចចង្អុលបង្ហាញពីភាពវិជ្ជមានមួយ ដោយការបង្ហាញថាគ្រប់ការអវិជ្ជមានទាំងអស់ខុសនោះទេ ។ បងប្អូនមិនអាចបង្ហាញថា សាសនាចក្រពិត ដោយការចង្អុលបង្ហាញថាគ្រប់ការអះអាងទាំងអស់ដែលជំទាស់នឹងសាសនាចក្រ គឺខុសនោះទេ ។ វាជាយុទ្ធសាស្ត្រដែលមានកំហុស ។ នៅទីបំផុត ត្រូវតែមានភស្តុតាងបញ្ជាក់ ហើយជាមួយនឹងការណ៍ទាំងឡាយរបស់ព្រះនោះនៅទីបំផុត និងដោយប្រាកដ ភស្តុតាងពិតជាបានមកដោយវិវរណៈតាមរយៈវិញ្ញាណ និងព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

ព្រះយេស៊ូវបានសួរដល់ពួកសិស្សទ្រង់ ៖

« តើថាខ្ញុំជានរណា ?

« ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ។

« រួចព្រះយេស៊ូវមានព្រះបន្ទូលតបថា អ្នកស៊ីម៉ូន កូនយ៉ូណាសអើយ អ្នកមានពរ ដ្បិតមិនមែនជាសាច់ឈាម ដែលបានសម្តែងឲ្យអ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ ។

« . . . អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ » ( ម៉ាថាយ ១៦:១៥–១៨ សូមមើល ខ ១៣–១៤ ផងដែរ ) ។

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានចាក់គ្រឹះនៅលើសិលានៃវិវរណៈ ហើយក្លោងទ្វារនៃស្ថាននរកនឹងមិនឈ្នះវាឡើយ ។ បងប្អូន និងខ្ញុំគឺជាសាសនាចក្រ ។ យើងត្រូវតែចាក់គ្រឹះនៅលើសិលានៃវិវរណៈ ហើយទោះបីយើងអាចនឹងមិនដឹងពីចម្លើយចំពោះគ្រប់សំណួរ តែយើងត្រូវតែដឹងពីចម្លើយចំពោះសំណួរចម្បងទាំងឡាយ ។ បើយើងដឹង នោះក្លោងទ្វារនៃស្ថាននរកនឹងមិនឈ្នះយើងឡើយ ហើយយើងនឹងស្ថិតស្ថេរជារៀងរហូត ។



**ឈរលើសិលានៃវិវរណៈ**

មានព្រះមួយអង្គដែលគង់នៅស្ថានសួគ៌ ដែលជាព្រះវរបិតាដ៏អស់កល្បរបស់យើង ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ យ៉ូសែប ស្ម៊ីធ ជាព្យាការីរបស់ព្រះ ដែលបានចាក់គ្រឹះសម្រាប់ការស្តារឡើងវិញនៃនគររបស់ព្រះ ។ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជានគរព្រះនៅលើផែនដីនេះ ។ ខ្ញុំដឹងការណ៍ទាំងនេះដោយបទពិសោធន៍របស់ខ្ញុំ—បទពិសោធន៍ទាំងអស់ ។ ខ្ញុំដឹងការណ៍ទាំងនេះដោយភស្តុតាង ហើយភស្តុតាងគឺលើសលុបណាស់ ។ ខ្ញុំដឹងការណ៍ទាំងនេះដោយការសិក្សា ។ ហើយប្រាកដបំផុតនោះគឺ ខ្ញុំដឹងការណ៍នេះដោយវិញ្ញាណ និងព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

ហើយដោយហេតុដូច្នោះ ខ្ញុំដឹងនូវអ្វីៗគ្រប់យ៉ាង ដែលខ្ញុំត្រូវការដឹង ដើម្បីស្ថិតស្ថេរជារៀងរហូត ។ ចូរឲ្យយើងឈរនៅលើសិលានៃវិវរណៈ ជាពិសេសទាក់ទងនឹងសំណួរចម្បងទាំងឡាយ ។ បើយើងធ្វើដូច្នោះ យើងនឹងស្ថិតស្ថេរជារៀងរហូត ហើយនិងមិនដែលថយទៅដែរ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន* « Stand Forever » *ដែលបានផ្តល់នៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៩ ។*

**កំណត់ចំណាំ**

១. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ ២០០៧ ) ទំព័រ ២៦៥ ។

# នាងនៅតែជាកូនរបស់យើង

វីណែសី ម៉ាខា ណាគៀរ ទីក្រុងឡាអ៊ូតូកា ប្រទេសហ្វីជី

*ស្វាមីខ្ញុំ និងខ្ញុំនឹងត្រូវផ្សារភ្ជាប់គ្នា ប៉ុន្តែពិធីបរិសុទ្ធដ៏ពិសិដ្ឋនេះ គឺធំធេងជាងយើងតែពីរនាក់ទៅទៀត ។*



បន្ទាប់ពីរយៈពេលប្រាំពីរឆ្នាំនៃការសង្ឃឹម និងការរង់ចាំដើម្បីមានកូន ស្វាមីរបស់ខ្ញុំ និងខ្ញុំត្រូវបានប្រទានពរឲ្យមានកូនស្រីមួយ ។ អាលីស៊ីជាពន្លឺនៃជីវិតរបស់យើង ប៉ុន្តែនាងបានរស់នៅតែប្រាំខែប៉ុណ្ណោះ ហើយក៏បានស្លាប់ទៅដោយសារជំងឺរលាកសួត ។

នោះគឺជាបទពិសោធន៍ដ៏ពិបាកបំផុតក្នុងជីវិតខ្ញុំ ។ ខ្ញុំត្រឡប់មកផ្ទះពីកន្លែងធ្វើការវិញ ហើយអង្គុយយំរៀងរាល់ថ្ងៃ ។ ជាញឹកញាប់ សាច់ថ្លៃខ្ញុំបានមកអង្គុយជាមួយខ្ញុំដើម្បីផ្ដល់កម្លាំងដល់ខ្ញុំ ។ ខ្ញុំបានបន្តអធិស្ឋានទូលសូមកូនមួយទៀត ប៉ុន្តែមិនមានទេ ។ ខ្ញុំបានវង្វេងនៅក្នុងភាពទុក្ខព្រួយ ។

សាច់ថ្លៃខ្ញុំបានចាប់ផ្ដើមលើកទឹកចិត្តស្វាមីខ្ញុំ និងខ្ញុំឲ្យធ្វើដំណើរទៅព្រះវិហារបរិសុទ្ធសូវ៉ាហ្វីជី ដើម្បីផ្សារភ្ជាប់ ។ យើងមិនដែលបានទៅព្រះវិហារបរិសុទ្ធទេ ហើយយើងបានសម្រេចចិត្តថា នេះជារបៀបដ៏ល្អបំផុតដើម្បីស្វែងរកសេចក្ដីសង្ឃឹម និងការព្យាបាល ។

គ្មានអ្វីអាចរៀបចំខ្ញុំ សម្រាប់អ្វីដែលខ្ញុំបានទទួលអារម្មណ៍នៅថ្ងៃនោះទេ ! ខ្ញុំបានដឹងថា ស្វាមីខ្ញុំ និងខ្ញុំនឹងត្រូវផ្សារភ្ជាប់ជាមួយគ្នាអស់កល្បជានិច្ច ។ ការចេះដឹងនេះបានធ្វើឲ្យខ្ញុំពោរពេញទៅដោយការដឹងគុណ និងសេចក្ដីស្រឡាញ់ ។ ប៉ុន្តែខ្ញុំពុំបានយល់ទេថា ពិធីបរិសុទ្ធដ៏ពិសិដ្ឋនេះ គឺធំធេងជាងយើងតែពីរនាក់ទៅទៀត ។

នៅឯព្រះវិហារបរិសុទ្ធ ខ្ញុំបានរៀនថា អាលីស៊ីអាចផ្សារភ្ជាប់នឹងយើង ។ ខ្ញុំយំដោយសេចក្ដីអំណរពេលខ្ញុំបានដឹងពីគោលលទ្ធិដ៏ពិសិដ្ឋនេះ ។ កូនស្រីយើងនឹងជារបស់យើងអស់កល្បជានិច្ច ! ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះបានប្រទានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការដើម្បីមានសុភមង្គលនៅក្នុងព្រះរាជដំណាក់ដ៏បរិសុទ្ធរបស់ទ្រង់ ។

តាំងពីពេលនោះមក ស្វាមីខ្ញុំ និងខ្ញុំត្រូវបានប្រទានពរឲ្យមានកូនប្រុសម្នាក់ និងកូនចញ្ចឹមបីនាក់ទៀត ។ តែយើងមិនដែលភ្លេចអាលីស៊ីទេ ។ ដោយសារតែពិធីបរិសុទ្ធទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ កូនស្រីរបស់យើងជាផ្នែកមួយនៃគ្រួសារយើងជារៀងរហូត ។

ពេលខ្ញុំជួបនរណាម្នាក់ដែលបានបាត់បង់កូន ខ្ញុំស្គាល់ពីការឈឺចាប់របស់ពួកគេ ។ ប៉ុន្តែខ្ញុំដឹងផងដែរថា ការឈឺចាប់នេះមិនមែនជាទីបញ្ចប់នោះទេ ។ ដោយការបាត់បង់អាលីស៊ី ក៏ដូចជាដកពិសោធការសាកល្បងផ្សេងៗទៀត ខ្ញុំដឹងថាព្រះគង់នៅទីនោះសម្រាប់ខ្ញុំ ។ ពេលខ្ញុំបាក់ទឹកចិត្ត ឬអ៊ែរទាំអំពីការណ៍ទាំងឡាយ ខ្ញុំដឹងថា ព្រះតែងតែគង់នៅទីនោះ ។

ខ្ញុំដឹងថា ខ្ញុំនឹងជួបអាលីស៊ីម្ដងទៀត ហើយសេចក្ដីពិតនោះបន្តធ្វើឲ្យស្វាមីខ្ញុំ និងខ្ញុំពោរពេញដោយសេចក្ដីអំណរយ៉ាងជ្រាលជ្រៅ ។ ■

រចនារូបភាពដោយ យ៉ូស្វេ ដេននីស



# ទ្រង់បានផ្គុំខ្ញុំឡើងវិញ

អេលៀណា ដាន់ រដ្ឋយូថាហ៍ ស.រ.អា

*មិត្តរបស់ខ្ញុំបានឮថាខ្ញុំឈឺ ហើយបានផ្ញើរូបផ្គុំដែលធ្វើដោយខ្លួនគាត់ផ្ទាល់ជាពិសេសសម្រាប់ខ្ញុំ ។*

ខ្ញុំតែងតែគិតពីខ្លួនឯងថាជាមនុស្សមានសុខភាពល្អ ។ ដូច្នេះខ្ញុំបានតក់ស្លុត ពេលខ្ញុំបានភ្ញាក់ឡើងនៅព្រឹកមួយ ហើយមានអារម្មណ៍ថាតឹងទ្រូងយ៉ាងខ្លាំង ដូចជាវារៀបនឹងផ្ទុះ ។ ខ្ញុំត្រូវបានបញ្ជូនទៅមន្ទីរពេទ្យជាប្រញាប់ ប៉ុន្តែបន្ទាប់ពីការធ្វើតេស្តអស់ជាច្រើនម៉ោង វេជ្ជបណ្ឌិតពុំអាចរកឃើញបញ្ហាទេ ។ ពួកគាត់បានបញ្ជូនខ្ញុំទៅផ្ទះវិញ ទោះបីខ្ញុំនៅតែមានការឈឺចាប់ជាខ្លាំងក្តី ។ ដោយហេតុនោះ មានការចាប់ផ្តើមការណាត់ជួបវេជ្ជបណ្ឌិតដ៏ពិបាករយៈពេលប្រាំពីរខែ ការស្នាក់នៅមន្ទីរពេទ្យ និងការឈឺចាប់ដ៏ខ្លាំងបំផុតដែលខ្ញុំមិនធ្លាប់ជួបក្នុងជីវិតខ្ញុំ ។

ខ្ញុំបានចាប់ផ្តើមធ្លាក់ទឹកចិត្ត ។ ខ្ញុំត្រូវបោះបង់ចោលថ្នាក់មហាវិទ្យាល័យរបស់ខ្ញុំ ហើយប្តូរទៅរស់នៅជាមួយឪពុកម្តាយខ្ញុំវិញ ។ ខ្ញុំមិនអាចចេញទៅក្រៅជាមួយមិត្តភក្តិបានទេ ។ ខ្ញុំឈឺខ្លាំងណាស់រហូតដល់មិនអាចធ្វើអ្វីៗដែលជាចំណូលចិត្តរបស់ខ្ញុំបាន ។ ខ្ញុំបានមានអារម្មណ៍ថា អ្វីគ្រប់យ៉ាងដែលខ្ញុំខ្វាយខ្វល់—សេចក្តីប្រាថ្នារបស់ខ្ញុំ ចំណងទាក់ទងរបស់ខ្ញុំ ទេពកោសល្យរបស់ខ្ញុំ—បានបែកខ្ញាត់ខ្ញាយអស់ ហើយឥឡូវនេះបំណែកទាំងឡាយនៃខ្លួនខ្ញុំពីមុន ហាក់បីដូចជាពុំអាចដាក់ផ្គុំបញ្ចូលគ្នាវិញបានទេ ។ ហើយខ្ញុំបានចាប់ផ្តើមឆ្ងល់ថា តើព្រះវរបិតាសួគ៌អនុញ្ញាតឲ្យការណ៍នេះកើតឡើងចំពោះខ្ញុំយ៉ាងដូចម្តេចទៅ ? តើទ្រង់មិនបានស្រឡាញ់ខ្ញុំទេឬ ?

បន្ទាប់ពីការជួបជាមួយវេជ្ជបណ្ឌិតដ៏ឈឺចាប់ និងខកចិត្តមួយទៀត អ្វីដែលខ្ញុំចង់ធ្វើគឺដេកក្រៀនៗ ហើយយំ ។ ប៉ុន្តែពេលខ្ញុំមកដល់ផ្ទះ ខ្ញុំបានឃើញអ្វីមួយចម្លែកនៅលើរានហាល ៖ ប្រអប់ស្បែកជើងរហែកកញ្ចាស់មួយរុំដោយស្កុត ហើយចារឈ្មោះខ្ញុំ ។

សំបុត្រនៅលើប្រអប់នោះបង្ហាញថា ប្រអប់នោះមកពីមិត្តម្នាក់របស់ខ្ញុំ ។ នាងបានឮថាខ្ញុំឈឺ ហើយចង់លើកទឹកចិត្តខ្ញុំឡើង ។ ពេលខ្ញុំបើកប្រអប់ស្បែកជើងនោះ ខ្ញុំបានឃើញវាមានពេញដោយបំណែកស្នោតូចៗ ។ វាជារូបផ្គុំដែលធ្វើដោយខ្លួនគាត់ផ្ទាល់ជាពិសេសសម្រាប់ខ្ញុំ ។

ពេលខ្ញុំដាក់ផ្គុំរូបនោះ ខ្ញុំបានចាប់ផ្តើមយំ ។ រូបផ្គុំនោះបានបង្កើតជាឈ្មោះខ្ញុំ ហ៊ុំព័ទ្ធដោយសារដ៏ផ្អែមល្ហែមនៃសេចក្តីស្រឡាញ់ និងការលើកទឹកចិត្ត ។ ខ្ញុំបានមានអារម្មណ៍ថា បំណែកនៃខ្លួនខ្ញុំដែលបែកខ្ញាត់ខ្ញាយ ឥឡូវនេះត្រូវបានដាក់ផ្គុំចូលគ្នាវិញ កាលដែលខ្ញុំផ្គុំបំណែកនៃអំណោយរបស់មិត្តខ្ញុំ ។

មួយរយៈខ្លីក្រោយមក ខ្ញុំបានចាប់ផ្តើមប្រើថ្នាំមួយដែលបានកាត់បន្ថយរោគសញ្ញារបស់ខ្ញុំ ហើយបានជួយវេជ្ជបណ្ឌិតធ្វើរោគវិនិច្ឆ័យ ។ ខ្ញុំមានស្ថានភាពដ៏កម្រតែអាចព្យាបាលបាន ហើយដោយមានថ្នាំត្រឹមត្រូវ ខ្ញុំអាចត្រឡប់ទៅកាន់ជីវិតធម្មតារបស់ខ្ញុំវិញបាន ។

សូម្បីតែពេលដែលរាងកាយខ្ញុំបានជា ខ្ញុំបានដឹងថា ខ្ញុំនឹងមិនដែលភ្លេចពីអ្វីដែលខ្ញុំបានរៀនឡើយ ។ ដោយសារតែអំណោយដ៏ផ្អែមល្ហែមរបស់មិត្តខ្ញុំ ខ្ញុំបានដឹងថា ខ្ញុំត្រូវបានស្រឡាញ់ ហើយថា ព្រះវរបិតាសួគ៌ពុំបានភ្លេចខ្ញុំទេ ។ សូមអរគុណដល់ចិត្តសប្បុរសរបស់មិត្តម្នាក់ និងសេចក្តីស្រឡាញ់របស់ព្រះវរបិតារបស់ខ្ញុំដែលគង់នៅស្ថានសួគ៌ ខ្ញុំបានជាសះស្បើយម្តងទៀត បន្ទាប់ពីមានអារម្មណ៍ថាត្រូវបែកខ្ញាត់ខ្ញាយអស់ជាច្រើនខែ ។ ■



រចនារូបភាពដោយ ប៉ុស្សេ ផេននីស

# « តើប្អូនមានគម្ពីរពណ៌ខៀវដែលមានអក្សរពណ៌មាសមួយក្បាលទេ ? »

មែឃើល ចេកុបសុន រដ្ឋ អ៊ូរីហ្គិន ស.រ.អា.

*បន្ទាប់ពីបានបោះគម្ពីរនោះចោលមួយរយៈ ខ្ញុំបានចង់ដឹងថាមានអ្វីនៅក្នុងនោះ ។*

ជាច្រើនឆ្នាំកន្លងមកហើយ ខ្ញុំបានទទួលគម្ពីរពណ៌ខៀវដែលមានអក្សរពណ៌មាសនៅលើក្របសៀវភៅ ពីពួកអ្នកផ្សព្វផ្សាយសាសនាដែលបម្រើនៅក្នុងបន្ទាយទាហាន ដែលខ្ញុំកំពុងទទួលការហ្វឹកហ្វឺនសម្រាប់ការងារខ្ញុំនៅក្នុងកងទ័ពជើងទឹកសហរដ្ឋ ។

កាលដែលខ្ញុំបានចាប់ផ្ដើមអានគម្ពីរនោះ មនុស្សម្នាក់បានប្រាប់ខ្ញុំថា វាមិនពិត ដោយសារវាចម្លងចេញពីព្រះគម្ពីរប៊ីប ។ វាបានបណ្ដាលឲ្យខ្ញុំសង្ស័យនឹងភាពពិតរបស់គម្ពីរនោះ ប៉ុន្តែខ្ញុំបានទុកវា ។ ខ្ញុំបានអានវាបន្តិច បានដាក់វានៅបាតកាបូបទាហានរបស់ខ្ញុំ ហើយបានភ្លេចពីវា ។

ជាងមួយឆ្នាំក្រោយមក ខ្ញុំបានសម្រេចចិត្តសម្អាតកាបូបទាហានរបស់ខ្ញុំ ។ ខ្ញុំបានឃើញគម្ពីរនោះ ប៉ុន្តែពុំមានចំណាប់អារម្មណ៍នឹងវាទៀតទេ ដូច្នេះខ្ញុំបានបោះវាចោល ។ ប៉ុន្តែមួយរយៈក្រោយមក ខ្ញុំមានការចង់ដឹងកាន់តែខ្លាំងឡើង អំពីអ្វីដែលនៅក្នុងគម្ពីរពណ៌ខៀវដែលមានអក្សរពណ៌មាសនោះ ។ ឥឡូវនេះខ្ញុំជឿថា អារម្មណ៍នេះបានមកពីព្រះវិញ្ញាណ « ដែលនាំឲ្យធ្វើល្អ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១១:១២ ) ។

នៅក្នុងឆ្នាំ ២០០៥ មិត្តថ្មីម្នាក់បានអញ្ជើញខ្ញុំឲ្យស្ដាប់ពួកអ្នកផ្សព្វផ្សាយសាសនា ។ ពីដំបូង ខ្ញុំមានសំណួរ និងការសង្ស័យនានាអំពីអ្វីដែលពួកគេបង្រៀន ប៉ុន្តែពួកអ្នកផ្សព្វផ្សាយសាសនាមានទំនុកចិត្ត ហើយបានផ្ដល់ចម្លើយទាំងឡាយដែលធ្វើឲ្យខ្ញុំយល់ ។



ពេលខ្ញុំបានដឹងថា ពួកអ្នកផ្សព្វផ្សាយទាំងនេះដូចជាពួកអ្នកដែលបានជួបប៉ុន្មានឆ្នាំមុន ខ្ញុំបានសួរពួកគេទាំងអន្ទះសាថា « តើប្អូនៗមានគម្ពីរពណ៌ខៀវដែលមានអក្សរពណ៌មាសមួយក្បាលទេ ? »

អ្នកផ្សព្វផ្សាយម្នាក់បានឆ្លើយថា « បាទ យើងមាន ! » « យើងហៅវាថាព្រះគម្ពីរមរមន ! »

ខ្ញុំរំភើបចិត្តដែលមានព្រះគម្ពីរមរមនម្ដងទៀត ។ តាមពិតទៅ ខ្ញុំរំភើបចិត្តណាស់ រហូតដល់ខ្ញុំអានវាច្រើនដងក្នុងរយៈពេលតិចជាងពីរសប្ដាហ៍ ។ កាលដែលខ្ញុំបានអាន ហើយអធិស្ឋាន ខ្ញុំបានដឹងថា វាគឺជាព្រះបន្ទូលនៃព្រះ ។

អែលឌើរ រូបេន វី អាលីអូឌ នៃពួកចិតសិបនាក់បាននិយាយពីអ្វីមួយនៅក្នុងសន្និសីទទូទៅ ដែលទាក់ទងទៅនឹងបទពិសោធន៍របស់ខ្ញុំជាមួយនឹងព្រះគម្ពីរមរមន ៖ « អ្នកអានណាដែលតាំងចិត្តសិក្សា [ ព្រះគម្ពីរមរមន ] ដោយស្មោះ ដោយស្មារតីនៃការអធិស្ឋាន នោះនឹងពុំគ្រាន់តែរៀនអំពីព្រះគ្រីស្ទប៉ុណ្ណោះទេ ប៉ុន្តែនឹងរៀន*មកពី*ព្រះគ្រីស្ទ—ជាពិសេសបើពួកគេធ្វើការសម្រេចចិត្ត ‹ សាកល្បងគុណតម្លៃនៃពាក្យសម្ដី › [ អាលម៉ា ៣២:៥ ] ហើយមិនបដិសេធវាជានិរន្តរ៍ដោយការមិនជឿទាំងលម្អៀង ដោយអ្វីដែលអ្នកដទៃបាននិយាយអំពីរឿងទាំងឡាយដែលពួកគេមិនដែលបានអាន » ។[១]

ដោយការអានព្រះគម្ពីរមរមន ការអធិស្ឋាន និងការទុកចិត្តលើព្រះវិញ្ញាណ នោះខ្ញុំបានឃើញការណ៍អស្ចារ្យទាំងឡាយកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំ ។ ■

កំណត់ចំណាំ

១. អែលឌើរ រូបេន វី អាលីអូឌ « ត្រូវបានរកឃើញតាមរយៈអនុភាពនៃព្រះគម្ពីរមរមន » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៩ ទំព័រ ៣៧ ។

រចនារូបភាពដោយ ក្រេហ្គ ញ៉ូវបូល

# គោលបំណងនៃបុណ្យជ្រមុជទឹករបស់ខ្ញុំ

វុយ ខុង ហុង ទីក្រុងតៃប៉ិថ្មី ប្រទេសតៃវ៉ាន់

*មុនពេលបុណ្យជ្រមុជទឹករបស់ខ្ញុំ ខ្ញុំបានអង្គុយចុះតែម្នាក់ឯង ហើយបាន អធិស្ឋានថា ដោយអព្ភូតហេតុ នោះមិត្តភក្ដិរបស់ខ្ញុំនឹងមក ។*



រចនារូបភាពដោយ ជូលី យែលឡូ

ក្នុងនាមជាក្មេងម្នាក់រស់នៅជាយក្រុងតៃប៉ិ ប្រទេសតៃវ៉ាន់ ខ្ញុំមិនដែលបានស្គាល់អ្នកផ្សព្វផ្សាយសាសនានោះទេ ។ ដូច្នេះនៅពេលខ្ញុំជួបពួកគេដំបូង ខ្ញុំចង់ដឹងចង់ឮពីសារលិខិតរបស់ពួកគេណាស់ ។ វាមិនយូរទេមុនពេលដែលខ្ញុំចង់ធ្វើតាមការបង្រៀនរបស់ពួកគេ ហើយដាក់ដំណឹងល្អទៅក្នុងការអនុវត្តនៅក្នុងជីវិតខ្ញុំនោះ ។ ខ្ញុំបានទទួលអារម្មណ៍ថា នេះជាផ្លូវមួយសម្រាប់ខ្ញុំដើម្បីឃើញថាមានព្រះមួយអង្គឬទេ ។

ក្នុងពេលមួយខែ ខ្ញុំបានរៀនដំណឹងល្អ និងបទបញ្ញត្តិទាំងឡាយដែលត្រូវបង្រៀនមុនពេលបុណ្យជ្រមុជទឹក ។ ខ្ញុំមានភាពសុខសាន្តតាមរយៈការអធិស្ឋាន ខ្ញុំបានទទួលវិវរណៈផ្ទាល់ខ្លួនពីការសិក្សាព្រះគម្ពីរ ហើយខ្ញុំមិនដែលខកខានការប្រជុំសាសនាចក្រ ណាមួយទេ ។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំគួរតែទទួលបុណ្យជ្រមុជទឹក ។

ឧបសគ្គដ៏ធំបំផុតដែលខ្ញុំបានប្រឈមនៅពេលនោះ គឺបញ្ហាដែលចូលក្នុងចំណងទាក់ទងរបស់ខ្ញុំជាមួយនឹងមិត្តភក្ដិមួយចំនួនរបស់ខ្ញុំ ដោយសារតែពួកគេជំទាស់នឹងការចូលរួមរបស់ខ្ញុំក្នុងព្រះវិហារ ។ ខ្ញុំបានអធិស្ឋានយ៉ាងខ្លាំងអំពីបញ្ហាទាំងនេះ ប៉ុន្តែចំណងទាក់ទងរបស់យើងហាក់ដូចជាកាន់តែអាក្រក់ឡើងទៅវិញ ។

ខ្ញុំបានអញ្ជើញមិត្តភក្ដិរបស់ខ្ញុំទៅបុណ្យជ្រមុជទឹករបស់ខ្ញុំ ប៉ុន្តែពួកគេបានបដិសេធការអញ្ជើញរបស់ខ្ញុំទាំងស្រុងតែម្ដង ។ ខ្ញុំពិតជាមិនដឹងថាត្រូវធ្វើអ្វីនោះទេ ។ មុនពេលបុណ្យជ្រមុជទឹករបស់ខ្ញុំ ខ្ញុំបានអង្គុយចុះតែម្នាក់ឯងនៅលើសាឡុងនៅច្រកដើរនៃសាលជំនុំ ដោយអធិស្ឋានថា ដោយអព្ភូតហេតុ នោះមិត្តភក្ដិរបស់ខ្ញុំនឹងមក ដើម្បីខ្ញុំអាចប្រាប់ពួកគេអំពីការផ្លាស់ប្ដូរវិជ្ជមានដែលខ្ញុំបានធ្វើនៅក្នុងជីវិតរបស់ខ្ញុំ ហើយបង្ហាញដល់ពួកគេថា ខ្ញុំបានធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវដោយការទទួលបុណ្យជ្រមុជទឹក ។

មិត្តភក្ដិរបស់ខ្ញុំមិនបានមកទេ ប៉ុន្តែខណៈដែលខ្ញុំបានថ្វាយដួងចិត្តខ្ញុំដល់ព្រះ នោះខ្ញុំបានទទួលការបំផុសគំនិតមួយ ។ នៅគ្រានោះ ខ្ញុំបានទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ដ៏អស្ចារ្យពីព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ខ្ញុំបានដឹងថា ទ្រង់គង់នៅទីនោះ ហើយពិតជាបានស្ដាប់ឮការអធិស្ឋានរបស់ខ្ញុំ ។

ដើមឡើយខ្ញុំចង់ធ្វើបុណ្យជ្រមុជទឹកដោយសារតែការណ៍ដ៏អស្ចារ្យទាំងអស់ដែលកើតឡើងក្នុងជីវិតខ្ញុំ ប៉ុន្តែនៅគ្រានោះ ខ្ញុំបានយល់ពីគោលបំណងនៃបុណ្យជ្រមុជទឹករបស់ខ្ញុំ ។

ការបំផុសគំនិតដែលខ្ញុំបានទទួល គឺដូចជាព្រះសូរសៀងរបស់ព្រះអម្ចាស់កំពុងមានព្រះបន្ទូលដ៏ទន់ភ្លន់ និងដោយផ្ទាល់មកកាន់ខ្ញុំ ដោយ មានបន្ទូលថា « កូនមិនចាំបាច់បង្ហាញភស្ដុតាងដល់នរណាឡើយ ។ កូនគ្រាន់តែត្រូវបង្ហាញដល់យើងប៉ុណ្ណោះថាកូនមានឆន្ទៈដើម្បីមកកាន់យើង ហើយបន្តស្មោះត្រង់ចំពោះដំណឹងល្អរបស់យើងអស់មួយជីវិតកូន » ។ ■

## នីហ្វៃទី៣ ១៧–១៩
( ថ្ងៃទី ២៨ ខែ កញ្ញា–ថ្ងៃទី ១១ ខែ តុលា )

# តើយើងអាចដកពិសោធព្រះចេស្ដានៃការប្រោសឲ្យជារបស់ព្រះគ្រីស្ទដោយរបៀបណា ?

នៅក្នុងការងារបម្រើរបស់ព្រះយេស៊ូវគ្រីស្ទដល់ពួកសាសន៍នីហ្វៃ ទ្រង់បានបង្ហាញសេចក្ដីស្រឡាញ់ដ៏អស្ចារ្យ និងព្រះចេស្ដានៃការប្រោសឲ្យជារបស់ទ្រង់ដល់អស់អ្នកដែលបានមកកាន់ទ្រង់ ។ តើយើងអាចរៀនអ្វីខ្លះចេញពីបទពិសោធន៍របស់ពួកសាសន៍នីហ្វៃជាមួយនឹងព្រះអង្គសង្គ្រោះ ?



### ការពិភាក្សា

- ប្រសិនបើបងប្អូនស្ថិតនៅក្នុងចំណោមពួកសាសន៍នីហ្វៃ តើបងប្អូននឹងទូលសូមព្រះអង្គសង្គ្រោះឲ្យប្រោសឲ្យជាអ្វីដែរ ? តើបងប្អូននឹងទូលប្រាប់ទៅកាន់ទ្រង់ដូចម្ដេច ?
- ដូចជាពួកសាសន៍នីហ្វៃដែរ តើបងប្អូនអាចមកកាន់ព្រះគ្រីស្ទ ហើយដកពិសោធនូវសេចក្ដីស្រឡាញ់ និងព្រះចេស្ដានៃការប្រោសឲ្យជារបស់ទ្រង់ដោយរបៀបណានៅក្នុងជីវិតរបស់បងប្អូន ?
- តើនៅពេលណាដែលបងប្អូនមានអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ? តើបងប្អូនមានអារម្មណ៍នោះដោយរបៀបណាដែរ ?

### ការសាកល្បងរបស់ពួកសាសន៍នីហ្វៃ

ជាច្រើនទសវត្សរ៍មុនការយាងមករបស់ព្រះយេស៊ូវគឺមានភាពច្របូកច្របល់ ។ ពួកសាសន៍នីហ្វៃបានស៊ូទ្រាំនឹង ៖

- ការធ្វើទុក្ខបុកម្នេញខាងសាសនា ( សូមមើល នីហ្វៃទី៣ ១:៩ ) ។
- ភាពទុច្ចរិត និងអំពើគួរខ្ពើមឆ្អើម ( សូមមើល នីហ្វៃទី៣ ២:៣; ៧:៧ ) ។
- សង្គ្រាម ( សូមមើល នីហ្វៃទី៣ ២:១៧ ) ។
- ការប្រកាន់វណ្ណៈ ( សូមមើល នីហ្វៃទី៣ ៦:១០–១៤ ) ។
- ភាពវឹកវរខាងស៊ីវិល ( សូមមើល នីហ្វៃទី៣ ៧:១–៤ ) ។
- គ្រោះធម្មជាតិ អំឡុងពេលភាពងងឹតបីថ្ងៃ ( សូមមើល នីហ្វៃទី៣ ៨ ) ។



### ការងារបម្រើរបស់ព្រះគ្រីស្ទទៅកាន់ពួកសាសន៍នីហ្វៃ

ពេលព្រះអង្គសង្គ្រោះបានយាងមកជួបពួកសាសន៍នីហ្វៃ ទ្រង់បានអញ្ជើញពួកគេទាំងអស់គ្នាដែល « រងទុក្ខដោយហេតុណា » ( នីហ្វៃទី៣ ១៧:៧ ) ឲ្យមក ហើយបានការប្រោសឲ្យជា ។ ការអញ្ជើញរបស់ទ្រង់គឺលើសពីការសាកល្បងបច្ចុប្បន្នរបស់ពួកសាសន៍នីហ្វៃទៅទៀត ។ វាអនុវត្តចំពោះរបួសដែលមើលឃើញ និងមើលមិនឃើញ ដែលពួកសាសន៍នីហ្វៃអាចមានអស់ពេញមួយជីវិតរបស់ពួកគេ ។ ព្រះយេស៊ូវគ្រីស្ទបានប្រោសឲ្យ « គ្រប់ៗគ្នា » បានជាសះស្បើយ ( នីហ្វៃទី៣ ១៧:៩ ) ហើយបានផ្ដល់ការងារបម្រើដល់ពួកគេ « ម្ដងម្នាក់ៗ » ( នីហ្វៃទី៣ ១៧:២១ ) ។

ការប្រោសឲ្យជា ដោយ ជេ ឃើក រីឆាដ

## នីហ្វៃទី៣ ១៧–១៩
( ថ្ងៃទី ២៨ ខែ កញ្ញា–ថ្ងៃទី ១១ ខែ តុលា )

ពេលព្រះគ្រីស្ទបាន យាងទៅជួបពួក សាសន៍នីហ្វៃ ទ្រង់ បានអធិស្ឋានជាមួយពួកគេ ១១ដង ។ តាមរយៈព្រះបន្ទូល និងគំរូ ទ្រង់បាន បង្រៀនពួកគេពីរបៀបដែលពួកគេគួរ អធិស្ឋាន ។ ពួកព្យាការីថ្ងៃចុងក្រោយ អ្នកមើលឆុត និង អ្នកទទួលវិវរណៈបន្ត បង្រៀននូវអ្វីដែលព្រះអង្គសង្គ្រោះបាន បង្រៀនអំពីការអធិស្ឋាន ។ នេះគឺជា ឧទាហរណ៍មួយចំនួន ៖

### ការពិភាក្សា
តើមានអ្វីផ្សេងទៀតដែលព្រះអង្គ សង្គ្រោះ និងពួកព្យាការីនិងពួកសាវក នៃ ពួកបរិសុទ្ធថ្ងៃចុងក្រោយ បាន បង្រៀនអំពីការអធិស្ឋាន ? តើការ បង្រៀនទាំងនេះជួយឲ្យការអធិស្ឋាន របស់បងប្អូនកាន់តែមានអត្ថន័យចំពោះ បងប្អូនយ៉ាងដូចម្តេច ?

# តើខ្ញុំអាចអធិស្ឋានដូចជាព្រះអង្គសង្គ្រោះ បានបង្រៀនយ៉ាងដូចម្តេច ?




| អ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀន | អ្វីដែលពួកព្យាការីថ្ងៃចុងក្រោយបង្រៀន អ្នកមើលឆុត និង អ្នកទទួលវិវរណៈ |
|---|---|
| អធិស្ឋានសម្រាប់មនុស្សផ្សេងទៀត ( សូមមើល នីហ្វៃទី៣ ១៧:១៤, ១៧, ២១ សូមមើល ផងដែរ នីហ្វៃទី៣ ១៨:២៣ ) ។ | « ការអធិស្ឋានសម្រាប់អ្នកដទៃដោយអស់ពីកម្លាំងនៃ ព្រលឹងរបស់យើង បង្កើនសមត្ថភាពរបស់យើងដើម្បី ស្តាប់ និងគោរពតាមសំឡេងនៃព្រះអម្ចាស់ » ។[1] |
| « ត្រូវចាំយាម ហើយអធិស្ឋាន ជានិច្ច » ( នីហ្វៃទី៣ ១៨:១៥ ) | « វាគឺតាមរយៈការអធិស្ឋានដ៏ស្មោះត្រង់ និង អស់ពីចិត្ត ដែលយើងអាចទទួលបានពរជ័យ ដែលត្រូវការ និងការគាំទ្រដែលតម្រូវឲ្យមាន ដើម្បីធ្វើដំណើរនៅក្នុងដំណើរដែលជួនកាល ពិបាក និងមានឧបសគ្គនេះ ដែលយើង ហៅថា ជីវិតរមែងស្លាប់ » ។[2] |
| « អធិស្ឋាននៅក្នុង ក្រុមគ្រួសារអ្នក » ( សូមមើល នីហ្វៃ ទី៣ ១៨:២១ សូម មើលផងដែរ នីហ្វៃ ទី៣ ១៧:៣ ) | « ប្រសិនបើបងប្អូននឹង . . . [ ចូលរួម ] នៅក្នុងការអធិស្ឋាន ជាក្រុមគ្រួសារជារៀងរាល់ ថ្ងៃ . . . នោះបងប្អូន នឹងទទួលពរជ័យដែល បានសន្យាពីព្រះអម្ចាស់ នៅក្នុងការចិញ្ចឹមបីបាច់ កូនចៅដ៏សុចរិត » ។[3] |
| កុំប្រើពាក្យផ្ទួនៗច្រើន ដង ( សូមមើល នីហ្វៃ ទី៣ ១៩:២៤ សូមមើលផង ដែរ នីហ្វៃទី៣ ១៣:៧ ) | « ការអធិស្ឋានរបស់យើងគួរតែ សាមញ្ញ ចំៗ និងស្មោះសរ » ។[4] |
| « ចូរបន្តការអធិស្ឋាន ចុះ » ( សូមមើល នីហ្វៃទី៣ ១៩:២៦ ) | « ចូរអធិស្ឋានជាញឹកញាប់ ។ អធិស្ឋាននៅក្នុងគំនិត នៅក្នុងចិត្ត របស់បងប្អូន ។ អធិស្ឋានដោយ លុតជង្គង់ ។ ការអធិស្ឋានជា កូនសោផ្ទាល់ខ្លួនរបស់បងប្អូនដើម្បី ទៅកាន់ស្ថានសួគ៌ ។ មេសោគឺនៅ ខាងរាំងននរបស់បងប្អូន » ។[5] |



**កំណត់ចំណាំ**
1. ដេវីឌ អេ បែដណា « *Pray Always* » Liahona ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤៣ ។
2. ថូម៉ាស អេស ម៉នសុន « Three Goals to Guide You » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ១២០ ។
3. *Teachings of Presidents of the Church: Howard W. Hunter* ( ឆ្នាំ ២០១៥ ) ទំព័រ ២២៩ ។
4. ដាល្លិន អេក អូក « The Language of Prayer » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៣ ទំព័រ ១៧ ។
5. ប៊ិយដ៏ ឃេ ផាកកឺ « Prayer and Promptings » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤៦ ។

រចនាក្រាហ្វិកដោយ ជូ ប៊ើត ប៊ិបស៊ុន

នីហ្វៃទី៣ ២០–២៦
( ថ្ងៃទី ១២–១៨ ខែ តុលា )

# តើយើងចូលរួមនៅក្នុង « កិច្ចការដ៏អស្ចារ្យ » របស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

នៅក្នុងចំណោមកិច្ចការជាច្រើនដែលព្រះអង្គសង្គ្រោះបានបង្រៀនពួកសាសន៍នីហ្វៃ ទ្រង់បានបង្រៀនពួកគេអំពីការប្រមូលផ្ដុំវង្សអ៊ីស្រាអែល ហើយបានបញ្ជាពួកគេឲ្យសិក្សាព្រះគម្ពីរ និងរក្សាបញ្ជីផ្ទាល់របស់ពួកគេ ។ តើយើងអាចធ្វើតាមការបង្រៀនទាំងនេះ នៅសព្វថ្ងៃនេះយ៉ាងដូចម្ដេច ?



**ចូរពិចារណាមើលសេចក្ដីព្យាករណ៍នៃពួកព្យាការី**

ព្រះអង្គសង្គ្រោះបានបញ្ជាពួកសាសន៍នីហ្វៃឲ្យ « ពិចារណាមើលសេចក្ដីព្យាករណ៍នៃពួកព្យាការី » ( នីហ្វៃទី៣ ២៣:៥ ) ។ យើងមានឱកាសដើម្បីស្ដាប់ពួព្យាការីដែលនៅរស់ និងថ្នាក់ដឹកនាំសាសនាចក្រផ្សេងៗទៀតនៅក្នុងសន្និសីទទូទៅ ។

- តើបងប្អូនអាចធ្វើអ្វីខ្លះដើម្បីទទួលបានកាន់តែច្រើនឡើងចេញពីសន្និសីទទូទៅ ?
- តើការ « ពិចារណាមើលសេចក្ដីព្យាករណ៍ នៃពួកព្យាការី » ជួយយើងនៅក្នុងការប្រមូលផ្ដុំវង្សអ៊ីស្រាអែលយ៉ាងដូចម្ដេច ?



**ចូលរួមនឹងកិច្ចការនេះ**

ព្រះយេស៊ូវគ្រីស្ទបានព្យាករអំពី « កិច្ចការដ៏អស្ចារ្យ » មួយនៅក្នុងថ្ងៃចុងក្រោយ ( សូមមើល នីហ្វៃទី៣ ២១:៩ ) ។ កិច្ចការនោះគឺជាការប្រមូលផ្ដុំវង្សអ៊ីស្រាអែល ។ ប្រធាន រ័សុល អិម ណិលសុន បានហៅការណ៍នេះថាជា « កិច្ចការដ៏សំខាន់បំផុតនៅលើផែនដីសព្វថ្ងៃនេះ » ហើយបានមានប្រសាសន៍ថា « បើប្អូនៗជ្រើសរើស បើប្អូនៗចង់ធ្វើ ប្អូនៗអាចធ្វើជាចំណែកដ៏សំខាន់ក្នុងកិច្ចការនេះ » ។[1]

- តើបងប្អូន និងគ្រួសារបងប្អូនអាចរៀនបន្ថែមទៀត និងចូលរួមក្នុងការប្រមូលផ្ដុំអ៊ីស្រាអែលយ៉ាងដូចម្ដេច ?

**ការរក្សាបញ្ជីមួយ**

ព្រះយេស៊ូវបានបញ្ជាពួកសិស្សសាសន៍នីហ្វៃរបស់ទ្រង់ ឲ្យរក្សាបញ្ជីមួយអំពីការបង្រៀនរបស់ទ្រង់ និងការព្យាកររបស់សាំយ៉ូអែលជាសាសន៍លេមិន ( សូមមើល នីហ្វៃទី៣ ២៣:៤, ៦–១៣ ) ។ ស្រដៀងគ្នានោះដែរ យើងអាចរក្សាបញ្ជីនៃបទពិសោធន៍ជីវិតរបស់យើង ដើម្បីជួយយើង និងដើម្បីបង្រៀនដល់មនុស្សផ្សេងទៀត ។

- តើមានបទពិសោធន៍ខាងវិញ្ញាណពីអតីតកាលអ្វីខ្លះ ដែលបងប្អូនពុំបានកត់ត្រាទុក ?
- តើបងប្អូនអាចកត់ត្រាការណ៍ទាំងឡាយដែលព្រះកំពុងបង្រៀនបងប្អូនយ៉ាងដូចម្ដេច ?

កំណត់ចំណាំ

១. រ័សុល អិម ណិលសុន « សង្ឃឹមអ៊ីស្រាអែល » ( ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ) ទំព័រ ៨ គេហទំព័រ HopeofIsrael.ChurchofJesusChrist.org ។

រូបថតពាងសៀវភៅមកពី GETTY IMAGES

# នីហ្វៃទី៣ ២៧–នីហ្វៃទី ៤

( ថ្ងៃទី ១៩–២៥ ខែ តុលា )

# តើការប្រែចិត្តជឿដ៏ពិតមានន័យយ៉ាងដូចម្ដេច ?

បន្ទាប់ពីការយាងមករបស់ព្រះអង្គសង្គ្រោះដល់ពួកសាសន៍នីហ្វៃ ពួកគេបានដកពិសោធនូវភាពសាមគ្គី និងភាពសុខសាន្តអស់ជិត ២០០ ឆ្នាំ ដោយសារតែពួកគេបាន « បានប្រែចិត្តជឿដល់ព្រះអម្ចាស់ » ( នីហ្វៃទី៤ ១:២ ) ។

តើមានគំរូណាផ្សេងទៀតអំពីសកម្មភាពសុចរិតរបស់ពួកសាសន៍នីហ្វៃ ? បងប្អូនអាចអាន នីហ្វៃទី៤ ១:២–១៥ ហើយបំពេញនៅក្នុងចន្លោះទាំងឡាយ ជាមួយនឹងគំរូបន្ថែមទៀតដែលបងប្អូនរកឃើញ ៖

- ______________________
  ______________________
  ______________________
- ______________________
  ______________________
  ______________________

## ការពិភាក្សា

- សូមប្រៀបធៀបសុភមង្គលរបស់ពួកសាសន៍នីហ្វៃដែលសុចរិតទៅនឹងទុក្ខព្រួយនៅពេលដែលពួកគេមិនសុចរិត ។ សូមពិចារណាពីភាពខុសគ្នា ហើយស្វែងរករបៀបទាំងឡាយដែលបងប្អូនអាចក្លាយកាន់តែប្រែចិត្តជឿចំពោះព្រះអម្ចាស់ ។
- តើបងប្អូនអាចជ្រើសរើសការណ៍មួយដែលបងប្អូនអាចអភិវឌ្ឍនៅក្នុងជីវិតរបស់បងប្អូនបានទេ ?
- តើការណ៍ទាំងនេះអាចនាំឲ្យបងប្អូនកាន់តែជិតស្និទ្ធនឹងមិត្តភក្តិ គ្រួសារ និងព្រះអម្ចាស់បានយ៉ាងដូចម្ដេច ?



### សុភមង្គល និងសាមគ្គីភាព

ពួកសាសន៍នីហ្វៃបានរីករាយ និងបានបង្រួបបង្រួមគ្នាតាមរយៈសកម្មភាពដ៏សុចរិតរបស់ពួកគេ ( សូមមើល នីហ្វៃទី៤ ១:២–១៥ ) ។

- ពួកគេជាមនុស្សដ៏ស្រស់ស្អាត និងចិត្តល្អចំពោះគ្នាទៅវិញទៅមក ។
- ពួកគេបានធ្វើតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះគ្រីស្ទ ។
- ពួកគេមានចិត្តរាបទាបនៅក្នុងការតមអាហារ និងការអធិស្ឋាន ។



### ទុក្ខព្រួយ និងការបែកបាក់

ជាអកុសល ឆ្នាំនៃសាមគ្គីភាព និងសុភមង្គលទាំងនោះពុំបានស្ថិតស្ថេរជារៀងរហូតទេ ។ នៅទីបំផុត ពួកសាសន៍នីហ្វៃបានឈប់គោរពតាមព្រះបញ្ញត្តិរបស់ព្រះ ( សូមមើល នីហ្វៃទី៤ ១:២៤–៣១ ) ។ ក្នុងការធ្វើដូច្នោះ ៖

- ពួកគេបានក្លាយជាអាត្មានិយម និងឆ្មើងឆ្មៃ ។
- ពួកគេបានស្ថាបនាព្រះវិហាររបស់ពួកគេផ្ទាល់ដើម្បីទទួលបានប្រយោជន៍ខាងហិរញ្ញវត្ថុ ។
- ពួកគេបានបដិសេធសាសនាចក្ររបស់ព្រះគ្រីស្ទ ។

រចនារូបភាពដោយ ចស ប្លេក







**ដោយប៊ីស្សព**
**ឌីន អិម ដេវីស**
ទីប្រឹក្សាទីមួយក្នុងគណៈ
ប៊ីស្សពជាអធិបតី

# សាលជំនុំ—កន្លែងនៃគារវភាព និងការថ្វាយបង្គំ

*ព្រះវិញ្ញាណនៃព្រះអម្ចាស់គង់នៅក្នុងសាលជំនុំរបស់យើង ហើយនឹងបំផុសគំនិតយើង ពេលយើងប្រតិបត្តិដោយគារវភាពនៅចំពោះទ្រង់ ។*

មានម្ដងនោះ មិត្តរួមការងារដ៏មានចិត្តស្មោះម្នាក់បានចែកចាយជាមួយខ្ញុំនូវបទពិសោធន៍មួយ ដែលគាត់បានមាន នៅពេលបំពេញការចាត់តាំងមួយឲ្យរៀបកៅអីទុក និងសម្អាតមណ្ឌលស្តេកក្រោយពីសន្និសីទស្តេកមួយ ។ បន្ទាប់ពីធ្វើកិច្ចការទាំងនេះអស់រយៈពេល ៣០នាទី គាត់បានដឹងថា គាត់ជាមនុស្សចុងក្រោយគេនៅក្នុងអគារនោះ ។ ទោះជាយ៉ាងណា ជំនួសឲ្យការមានអារម្មណ៍ឯកោ ហើយប្រញាប់ប្រញាល់ដើម្បីចាកចេញ គាត់បានកត់សម្គាល់ថា អារម្មណ៍ដ៏ផ្អែមល្ហែមនៃភាពសុខសាន្តដែលគាត់បានទទួលអំឡុងសន្និសីទ បន្តនៅជាមួយគាត់ ហើយថែមទាំងកើនឡើងទៀតផង ។

ពេលគាត់បានបញ្ចប់កិច្ចការដែលបានចាត់តាំងនោះ ហើយចាកចេញពីសាលជំនុំ គាត់បានជួបនឹងសមាជិកម្នាក់ទៀត ដែលហាក់ដូចជាបានសម្លឹងមើលគាត់ដោយចេតនា ។ ដោយការដឹងពីអ្វីដែលមិត្តរបស់ខ្ញុំបានធ្វើ សមាជិកនេះបានទាញដៃគាត់ ហើយបាននិយាយថា « បងប្រុស ព្រះអម្ចាស់ទតឃើញកិច្ចការដ៏តូចតាចទាំងនេះ ដែលបងធ្វើសម្រាប់ទ្រង់ ហើយទ្រង់ទតមើលមកក្រោម ហើយញញឹមចំពោះកិច្ចការទាំងនោះ » ។

ប៉ុន្មានឆ្នាំក្រោយមក ខណៈបម្រើជាប៊ីស្សពម្នាក់ មិត្តដដែលនេះបានឃើញថាខ្លួនគាត់នៅម្នាក់ឯងម្ដងទៀតនៅក្នុងសាលជំនុំវួដរបស់គាត់ ។ បន្ទាប់ពីបិទភ្លើងនៅក្នុងសាលជំនុំហើយ គាត់បាននៅបង្អែរបង្អង់មួយសន្ទុះ កាលដែលពន្លឺព្រះច័ន្ទបានចាំងពន្លឺចូលមកតាមបង្អួចទៅលើវេទិកា ។

អារម្មណ៍នៃភាពសុខសាន្តស្រដៀងគ្នានោះបានគ្របដណ្ដប់មកលើគាត់ម្ដងទៀត ហើយគាត់បានអង្គុយចុះនៅខាងមុខនៃសាលជំនុំ ហើយបានសញ្ជឹងគិតពីគ្រាដ៏ពិសិដ្ឋជាច្រើនអនេកប្បការ ដែលគាត់បានដកពិសោធនៅក្នុងស្ថានភាពបែបនោះ—ជាច្រើនដង គាត់បានសង្កេតពួសង្ឃហែកនំប៉័ងនៅឯតុសាក្រាម៉ង់ ឱកាសទាំងឡាយដែលគាត់បានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធដែលបាននៅជាគ្នានឹងគាត់ ពេលគាត់ថ្លែងសារលិខិតសន្និសីទវួដ ពិធីបុណ្យជ្រមុជទឹកដែលគាត់បានដឹកនាំ ចម្រៀងពិសេសពីក្រុមចម្រៀងដែលគាត់បានឮ និងទីបន្ទាល់រាប់មិនអស់ពីសមាជិកវួដដែលបានរំជួលចិត្តគាត់យ៉ាងជ្រាលជ្រៅ ។ ដោយបានអង្គុយចុះតែម្នាក់ឯងនៅក្នុងសាលជំនុំដ៏ងងឹត នោះគាត់បានទទួលអារម្មណ៍គ្របដណ្ដប់ដោយឥទ្ធិពលរួមគ្នាមកពី



បទពិសោធន៍ទាំងនេះទៅលើជីវិតរបស់គាត់ និងជីវិតសមាជិកក្នុងវួដរបស់គាត់ ហើយគាត់បានឱនក្បាលចុះដោយការដឹងគុណដ៏ជ្រាលជ្រៅ ។

មិត្តរបស់ខ្ញុំត្រូវបានបង្រៀនដោយឆ្លាតវៃ និងត្រឹមត្រូវថា ទីកន្លែងដ៏ពិសិដ្ឋបំផុតនៅលើផែនដី គឺព្រះវិហារបរិសុទ្ធ និងគេហដ្ឋាន ប៉ុន្តែតាមរយៈបទពិសោធន៍ទាំងពីរខាងលើនេះ គាត់ក៏បានយល់ផងដែរពីធម្មជាតិដ៏ពិសិដ្ឋនៃសាលជំនុំរបស់យើង ។ ដោយសារតែសាលជំនុំទាំងនោះត្រូវបានឧទ្ទិសឆ្លងដោយសិទ្ធិអំណាចបព្វជិតភាព នោះអគារទាំងនេះក្លាយជាកន្លែងដែលព្រះអម្ចាស់ចាក់វិវរណៈមកលើរាស្ត្ររបស់ទ្រង់ និងជាកន្លែងដែល « អំណាចនៃព្រះត្រូវបានសម្ដែងឲ្យឃើញ » តាមរយៈពិធីបរិសុទ្ធទាំងឡាយដែលធ្វើឡើងនៅទីនោះ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៤:២០ ) ។

សាលជំនុំរួមគ្នាជាមួយនឹងគេហដ្ឋាន ដើម្បីនាំមកនូវសេចក្ដីអំណរដែលបានសន្យាដែលពួកបរិសុទ្ធដ៏ស្មោះត្រង់អាចដកពិសោធនៅថ្ងៃឈប់សម្រាក ។ វាក្លាយទៅជាកន្លែងមួយដែលការថ្វាយបង្គំរួមគ្នារបស់សមាជិកបណ្ដាលឲ្យដួងចិត្តរបស់ពួកគេក្លាយទៅជា « មានចិត្តចងក្រងរួមគ្នាដោយសាមគ្គី ហើយស្រឡាញ់គ្នាទៅវិញទៅមក » ( ម៉ូសាយ ១៨:២១ ) និងចំពោះព្រះអង្គសង្គ្រោះ ។ សម្រាប់យើង ដើម្បីបង្ហាញពីការដឹងគុណ និងការគោរពដ៏ត្រឹមត្រូវសម្រាប់ការចាក់ស្រោចនូវពរជ័យខាងវិញ្ញាណមកលើយើង តាមរយៈសាលជំនុំរបស់យើង នោះយើងគួរតែចូលទៅក្នុងកន្លែងថ្វាយបង្គំទាំងនេះដោយឥរិយាបថនៃគារវភាពដ៏ជ្រាលជ្រៅ និងស្មោះសរ ។

**អត្ថន័យនៃគារវភាព**

នៅក្នុងវប្បធម៌សាសនាចក្រសម័យទំនើបរបស់យើង ពាក្យ *គារវភាព* បានក្លាយជាសទិសន័យជាមួយនឹងពាក្យ *ស្ងៀមស្ងាត់* ។ ខណៈដែលសំឡេងទន់ភ្លន់គឺពិតជាសមរម្យសម្រាប់រោងជំនុំរបស់យើង ក៏ទស្សនៈដ៏មានដែនកំណត់អំពីគារវភាពនេះ មិនបានចាប់យកអត្ថន័យពេញលេញនៃពាក្យនេះទេ ។ *គារវភាព* (*Reverence*) អាចប្រទាក់ទៅនឹងកិរិយាសព្ទឡាតាំង *revereri* ដែលមានន័យថា « ឈរស្ញើចសរសើរដល់ » ។[១] តើយើងអាចរកពាក្យមួយដែលពិពណ៌នាឲ្យកាន់តែល្អប្រសើរជាងនេះអំពីអារម្មណ៍នៃព្រលឹងយើង នៅពេលយើងពិតជាសញ្ជឹងគិតពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់យើងម្នាក់ៗដែរឬទេ ?

ខ្ញុំត្រូវបានរំឭកអំពីពាក្យពេចន៍ទាំងឡាយនៅក្នុងទំនុកតម្កើងដ៏ពីរោះ ដែលយើងច្រៀងនៅក្នុងរោងជំនុំរបស់យើង ៖ « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យនូវក្តីស្នេហ៍ព្រះគ្រីស្ទឱ្យដល់ខ្ញុំ » ។[២] អារម្មណ៍នៃការដឹងគុណ ការសរសើរតម្កើង និងការអស្ចារ្យដ៏ជ្រាលជ្រៅនោះ គឺជាខ្លឹមសារនៃគារវភាព ហើយវាជំរុញយើងឲ្យចៀសវាងពីភាសា ឬឥរិយាបទណាក៏ដោយ ដែលអាចកាត់បន្ថយនូវអារម្មណ៍ទាំងនោះដែលមានក្នុងយើង ឬអ្នកដទៃផ្សេងទៀត ។



## សាលជំនុំ និងថ្ងៃឈប់សម្រាក

ចេញមកពីវិវរណៈសម័យទំនើប យើងដឹងថា ផ្នែកដ៏សំខាន់នៃការថ្វាយបង្គំថ្ងៃឈប់សម្រាក គឺដើម្បី « ទៅដំណាក់នៃការអធិស្ឋាន ហើយថ្វាយសាក្រាម៉ង់ [ របស់យើង ] ឡើងនៅថ្ងៃបរិសុទ្ធ [ របស់ព្រះអម្ចាស់ ] » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៩:៩ ) ។ « ដំណាក់នៃការអធិស្ឋាន » ដែលយើងប្រមូលផ្ដុំគ្នានៅថ្ងៃឈប់សម្រាក គឺជាសាលជំនុំដ៏ពិសិដ្ឋរបស់យើង ។

ប្រធាន រ័សុល អិម ណិលសុន បានជួយយើងឲ្យយល់កាន់តែច្បាស់ពីទំនាក់ទំនងយ៉ាងជិតស្និតរវាងគារវភាពរបស់យើងចំពោះព្រះអង្គសង្គ្រោះ និងអារម្មណ៍របស់យើងចំពោះថ្ងៃឈប់សម្រាក ។ នៅក្នុងការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកអំពីការគោរពថ្ងៃឈប់សម្រាក ប្រធានណិលសុនបានដំណាលថា « ខ្ញុំបានរៀនចេញពីព្រះគម្ពីរថា ទង្វើ និងឥរិយាបថរបស់ខ្ញុំនៅថ្ងៃឈប់សម្រាក គឺជា*ទីសម្គាល់*មួយរវាងខ្ញុំ និងព្រះវរបិតាសួគ៌របស់ខ្ញុំ » ។[៣]

គឺដូចជាទង្វើ និងឥរិយាបថរបស់យើងនៅថ្ងៃឈប់សម្រាកគឺជាទីសម្គាល់នៃភក្ដីភាពរបស់យើងចំពោះព្រះអម្ចាស់ដែរ នោះទង្វើរបស់យើង ឥរិយាបថរបស់យើង ហើយសូម្បីតែរបៀបនៃការស្លៀកពាក់របស់យើង ខណៈនៅក្នុងដំណាក់នៃការអធិស្ឋានរបស់ទ្រង់ អាចចង្អុលបង្ហាញដូចគ្នាដែរ អំពីកម្រិតនៃគារវភាព ដែលយើងមានចំពោះព្រះអង្គសង្គ្រោះ ។

## សាលជំនុំ និងពិធិបរិសុទ្ធ

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពង្រីកការយល់ដឹងរបស់យើងអំពីគំនិតនេះ ដោយថ្លែងថា ៖

« ក្រៅពីការបង្កើតពេលដើម្បីបង្រៀនដំណឹងល្អនៅតាមផ្ទះ នោះការកែសម្រួលការបម្រើរបស់យើងនៅថ្ងៃអាទិត្យ . . . គួសបញ្ជាក់យ៉ាងត្រឹមត្រូវថា ពិធីសាក្រាម៉ង់នៃអាហារពេលយប់របស់ព្រះអម្ចាស់ថាពិសិដ្ឋ ជាការទទួលស្គាល់ផ្ដោតទៅលើបទពិសោធន៍ការថ្វាយបង្គំប្រចាំសប្ដាហ៍របស់យើង ។ យើងត្រូវចងចាំក្នុងរបៀបផ្ទាល់ខ្លួនមួយតាមដែលអាចធ្វើទៅបានថា ព្រះគ្រីស្ទបានសុគតដោយដួងចិត្តខ្ទេចខ្ទាំ ដោយការរ៉ែកអំពើបាប និងភាពសោកសៅទាំងអស់របស់គ្រួសារមនុស្សលោកទាំងមូលតែអង្គឯង ។

« ក្នុងគ្រាដូច្នោះវាតម្រូវឲ្យមានការគោរពរបស់យើង ជាការតបស្នងចំពោះបន្ទុកដែលចៀសមិនរួចនោះ » ។[៤]



វាសំខាន់ដើម្បីចងចាំថា ទីកន្លែងដែលបានតែងតាំងសម្រាប់គ្រានៃការគោរពដ៏ខ្ពង់ខ្ពស់បំផុតនេះចំពោះព្រះអង្គសង្គ្រោះ គឺជារោងជំនុំនៃសាលជំនុំ ។ ក្រៅពីគារវភាពដែលយើងទទួលអារម្មណ៍ អំឡុងពេលនៃពិធីបរិសុទ្ធសាក្រាម៉ង់ប្រចាំសប្ដាហ៍ អារម្មណ៍នៃគារវភាព និងការគោរពរបស់យើងត្រូវបានពង្រីក ពេលដែលយើងពិចារណាពីពិធីបរិសុទ្ធនៃបព្វជិតភាព និងពរជ័យទាំងឡាយផ្សេងៗទៀតដែលធ្វើឡើងនៅក្នុងសាលជំនុំ រួមមានទាំងការដាក់ឈ្មោះ និងការប្រសិទ្ធិពរកុមារ ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ការតែងតាំងបព្វជិតភាព និងការញែកចេញសម្រាប់ការហៅបម្រើទាំងឡាយ ។ ពិធីបរិសុទ្ធនីមួយៗ និងពរជ័យទាំងឡាយទាំងនេះអាចនាំមកនូវការចាក់ស្រោចនៃព្រះវិញ្ញាណបរិសុទ្ធ ប្រសិនបើពួកអ្នកដែលធ្វើពិធី និងអ្នកចូលរួមមកដោយមានឥរិយាបថគារវភាព ។

រូបថតស្ត្រីនៅលើវេទិកានិយាយ ដោយ ធីហ្វានី ម៉ាយឡូន តុង

**សាលជំនុំ និងការថ្វាយបង្គំ**

ថ្ងៃឈប់សម្រាកផ្ដល់ដល់យើងនូវឱកាសដើម្បីថ្វាយបង្គំព្រះអម្ចាស់ នៅអំឡុងពេលនៃការសិក្សានៅផ្ទះរបស់យើង និងជាក្រុមជំនុំមួយអំឡុងពេលការប្រជុំសាក្រាម៉ង់ និងការប្រជុំផ្សេងៗទៀត ។ តាំងពីជំនាន់ដំបូងបំផុតរបស់សាសនាចក្រ ពួកបរិសុទ្ធបានរីករាយនឹងការមកជួបជុំគ្នា ដើម្បីទាក់ទងគ្នា និងបង្កើតចំណងនៃភាពជាបងប្អូនប្រុសស្រី ។ សាលជំនុំរបស់យើងថែមទាំងបានរចនាជាមួយនឹងកន្លែងទាំងឡាយដើម្បីធ្វើសកម្មភាពទាំងឡាយដូច្នោះនៅអំឡុងថ្ងៃនានាក្នុងសប្ដាហ៍ផងដែរ ។ ទោះជាយ៉ាងណា យើងមិនត្រូវភ្លេចពីគោលបំណងចម្បងនៃអគារទាំងនេះឡើយ គឺដើម្បីផ្ដល់កន្លែងមួយសម្រាប់ការថ្វាយបង្គំ ។

ការថ្វាយបង្គំ និងគារវភាពទាក់ទងគ្នាយ៉ាងជិតស្និត ។ « ពេលយើងថ្វាយបង្គំព្រះ យើងទៅរកទ្រង់ដោយសេចក្ដីស្រឡាញ់ដ៏គារវភាព ចិត្តរាបសា និងភាពអស្ចារ្យ ។ យើងទទួលស្គាល់ ហើយទទួលយកទ្រង់ជាស្ដេច ជាព្រះបង្កបង្កើតសកលលោក ជាព្រះវរបិតាជាទីស្រឡាញ់ និងអស់កល្បជានិច្ចរបស់យើង » ។[៥]

ហេតុដូច្នោះហើយ គោលបំណងដ៏សំខាន់នៃការថ្វាយបង្គំនេះគួរតែជះឥទ្ធិពលលើទង្វើរបស់យើងនៅក្នុងសាលជំនុំ សូម្បីតែពេលយើងចូលរួមក្នុងសកម្មភាពសង្គម ឬកម្សាន្តក៏ដោយ ។ គប្បីមានការថែទាំយ៉ាងអស្ចារ្យ ដើម្បីកាត់បន្ថយការគ្មានរបៀបរៀបរយ កំទេចកំទី ឬការខូចខាតឲ្យតិចបំផុតដល់ផ្នែកណាក៏ដោយនៃអគារដែលបណ្ដាលមកពីសកម្មភាពសាសនាចក្រ ហើយត្រូវធ្វើការសម្អាតភ្លាមៗ ឬជួសជុលវាភ្លាមៗប្រសិនបើការខូចខាតបែបនោះកើតឡើង ។

កុមារ និងយុវវ័យអាចត្រូវបានបង្រៀនថា គារវភាព និងការថែរក្សាសាលជំនុំគឺត្រូវធ្វើឡើងលើសពីការប្រជុំថ្ងៃអាទិត្យទៅទៀត ។ ការចូលរួមរបស់សមាជិកនៅក្នុងការសម្អាតសាលជំនុំ—ជាពិសេសការចូលរួមជាមួយគ្នារបស់ឪពុកម្ដាយ និងកូនៗ—គឺជាមធ្យោបាយដ៏ល្អប្រសើរក្នុងការបង្កើតនូវអារម្មណ៍នៃគារវភាពសម្រាប់អគារដ៏ពិសិដ្ឋរបស់យើង ។ ដូចត្រូវបានបង្ហាញយ៉ាងជាក់ស្ដែងនៅក្នុងបទពិសោធន៍របស់មិត្តខ្ញុំ ក្នុងការរៀបចំមណ្ឌលស្ដេករបស់គាត់បន្ទាប់ពីសន្និសីទស្ដេក ទង្វើនៃការថែទាំសាលជំនុំដូចនោះ ជាមធ្យោបាយមួយនៃការថ្វាយបង្គំ និងអញ្ជើញព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ។



ថតរូបដោយ ជេមស៍ អ៊ីលីហ្វ ជេហ្វ្រី

រូបថតសមាជិកពយខាងក្រៅ ដោយ ម៉ាសស៊ីមូ ក្រិសបឃុន

រូបថតស្ត្រីសម្អាតទ្វារ ដោយ ដេវីឌ ហិនរី មេអេនេតហ៍

*ការថែទាំសាលជំនុំរបស់យើង គឺជាមធ្យោបាយមួយនៃការថ្វាយបង្គំ និងអញ្ជើញព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ។*





រូបថតមនុស្សចាកចេញពីអគារ ដោយ ម៉ាសស៊ីមូ គ្រីសយូន

**សាលជំនុំ និងព្រះអង្គសង្គ្រោះ**

នៅក្រោមការដឹកនាំនៃការព្យាករបស់ប្រធានណិលសុន កិច្ចខិតខំដ៏សំខាន់ៗត្រូវបានធ្វើឡើង ដើម្បីធ្វើឲ្យប្រាកដថា ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទមិនត្រូវបានគេដកចេញឡើយ នៅពេលយើងនិយាយដល់សាសនាចក្ររបស់ទ្រង់ ។ ក្នុងរបៀបស្រដៀងគ្នានេះដែរ យើងមិនត្រូវអនុញ្ញាតឲ្យព្រះអង្គសង្គ្រោះត្រូវប្ដូរទីតាំងពីមូលដ្ឋាននៃការថ្វាយបង្គំរបស់យើងឡើយ—រួមទាំងទីកន្លែងនៃការថ្វាយបង្គំរបស់យើងផងដែរ ។

យើងមានទម្លាប់ហៅព្រះវិហារបរិសុទ្ធថាជាដំណាក់នៃព្រះអម្ចាស់ ដែលចាត់ទុកថាជាការត្រឹមត្រូវ និងសំខាន់ ។ ទោះជាយ៉ាងណា យើងអាចនឹងងាយភ្លេចថា សាលជំនុំនីមួយៗរបស់យើងត្រូវបានឧទ្ទិសដោយសិទ្ធិអំណាចបព្វជិតភាពទុកជាកន្លែងមួយដែលព្រះវិញ្ញាណនៃព្រះអម្ចាស់អាចគង់នៅ និងជាកន្លែងដែលបុត្រាបុត្រីរបស់ព្រះ—ទាំងអ្នកនៅក្នុង និងនៅក្រៅសាសនាចក្រ—អាចមក « ស្គាល់ព្រះដ៏ប្រោសលោះរបស់ខ្លួន » ( ម៉ូសាយ ១៨:៣០ ) ។

ការផ្តួចផ្តើមដែលទើបតែប្រកាសថ្មីៗឲ្យតែងលម្អសាលជំនុំរបស់យើងជាមួយនឹងគំនូរដែលពិពណ៌នាដោយគោរពដល់ព្រះអង្គសង្គ្រោះ និងព្រឹត្តិការណ៍ដ៏ទេវភាពនៃព្រះជន្មរមែងស្លាប់ និងក្រោយជីវិតរមែងស្លាប់របស់ទ្រង់ ត្រូវបានរចនាដើម្បីទាក់ទាញភ្នែក គំនិត និងដួងចិត្តរបស់យើងឲ្យខិតកាន់តែជិតទ្រង់ ។ កាលដែលបងប្អូនចូលក្នុងដំណាក់នៃការអធិស្ឋានទាំងនេះសម្រាប់ការប្រជុំ និងសកម្មភាពនានា យើងសូមអញ្ជើញបងប្អូនដោយក្ដីស្រឡាញ់ឲ្យឈប់ សង្កេតមើល ហើយសញ្ជឹងគិតគំនូរដ៏ពិសិដ្ឋទាំងនេះ ដើម្បីមើលវាជាមួយកូនៗរបស់បងប្អូន ហើយអនុញ្ញាតឲ្យគំនូរទាំងនេះបង្កើនអារម្មណ៍នៃការថ្វាយបង្គំ និងគារវភាពរបស់បងប្អូនចំពោះព្រះ ។

ព្យាការីព្រះគម្ពីរសញ្ញាចាស់ ហាបាគុកបានប្រកាសថា « ឯព្រះយេហូវ៉ា ទ្រង់គង់នៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់វិញ ចូរឲ្យផែនដីទាំងមូលស្ងៀមនៅចំពោះទ្រង់ចុះ » ( ហាបាគុក ២:២០ ) ។ ចូរឲ្យយើងចងចាំដូចគ្នានោះដែរថា ព្រះវិញ្ញាណនៃព្រះអម្ចាស់គង់នៅក្នុងសាលជំនុំរបស់យើង ហើយនឹងជ្រាបចូលក្នុងដួងចិត្តយើងម្នាក់ៗ ដល់កម្រិតមួយដែលយើងប្រតិបត្តដោយគារវភាពចំពោះទ្រង់ ។ ■

**កំណត់ចំណាំ**

១. « Revereri » Lexico Powered by Oxford, lexico.com ។
២. « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » *ទំនុកតម្កើង* លេខ ១១៥ ។
៣. រ័សុល អិម ណិលសុន « ថ្ងៃឈប់សម្រាកជាថ្ងៃមួយដ៏សប្បាយ » *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៣០ ។
៤. ជែហ្វ្រី អ័រ ហូឡិន « នុំះន័ កូនចៀមនៃព្រះ » *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ៤៥ ។
៥. ឌីន អិម ដេវីស « ពរជ័យនៃការថ្វាយបង្គំ » *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៩៤ ។

# យុវមជ្ឈិមវ័យ

## នៅក្នុងវគ្គនេះ


៤៤ **តើការញៀនដូចគ្នានឹងការបះបោរដែរឬទេ ?**
ដោយ ដេស្ទីនី យ៉ាប្រូ

៤៨ **គន្លឹះ ៧ ចំណុចសម្រាប់ការយកឈ្នះលើការប្រើប្រាស់ការណ៍អាសគ្រាម**
ដោយ រីឆាត អសប្លឺរ


## មានតែឌីជីថលប៉ុណ្ណោះ


**ការគាំទ្រម្ដាយខ្ញុំនៅលើផ្លូវទៅកាន់ការបញ្ឈប់គ្រឿងស្រវឹងរបស់គាត់**
ដោយ អនណាសថាហ្សា ខូល


ស្វែងរកអត្ថបទទាំងនេះ និងអ្វីៗបន្ថែមទៀត ៖

- នៅគេហទំព័រ **liahona.ChurchofJesusChrist.org**
- នៅក្នុង **យុវមជ្ឈិមវ័យប្រចាំសប្ដាហ៍** ( ខាងក្រោមវគ្គ យុវមជ្ឈិមវ័យ នៅក្នុងកម្មវិធី បណ្ណាល័យដំណឹងល្អ )

## ចែកចាយរឿងរបស់បងប្អូន

តើបងប្អូនមានរឿងដ៏អស្ចារ្យដើម្បីចែកចាយឬទេ ? ឬតើបងប្អូនចង់ឃើញអត្ថបទអ្វីខ្លះអំពីប្រធានបទជាក់លាក់នានា ? បើដូច្នេះ យើងចង់ឮពីបងប្អូន ! បងប្អូនអាចផ្ញើអត្ថបទ ឬមតិកែលម្អរបស់បងប្អូនតាមគេហទំព័រ **liahona.ChurchofJesusChrist.org** ។

# បងប្អូនអាចរកឃើញសេរីភាព

តើបងប្អូន ឬនរណាម្នាក់ដែលបងប្អូនស្រឡាញ់នៅក្នុងវដ្តនៃការធ្វើខុស ការប្រែចិត្ត ការតាំងចិត្តជាថ្មី និងការធ្វើខុសម្ដងទៀតដែរឬទេ ? យុវមជ្ឈិមវ័យដ៏ប្រពៃជាច្រើនដែលខ្ញុំបានធ្វើការជាមួយ ខណៈបម្រើជាប៊ីស្សពនៅវួដយុវជម្ឈិមវ័យនៅលីវ ត្រូវជាប់នៅក្នុងវដ្តដដែលៗ ។ **ប៉ុន្តែ ពួកគេជាច្រើនក៏បានរកឃើញសេរីភាពផងដែរ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។** សារលិខិតអំពីការញៀននៅក្នុងវគ្គខែនេះ ផ្ដល់នូវការយល់ដឹងដ៏មានប្រយោជន៍ដើម្បីស្វែងរកសេរីភាព—សម្រាប់បងប្អូនផ្ទាល់ និងអ្នកដទៃទៀត ។

អ្វីដែលសំខាន់បំផុតដែលយើងគប្បីចងចាំទុក គឺថា **យើងទាំងអស់គ្នាគឺជាបុត្រជាទីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ។** អែលឌើរ ឌៀថើរ អេស្វ អុជដូហ្វ បានបង្រៀនថា « [ ព្រះ ] មិនបានរង់ចាំដើម្បីស្រឡាញ់បងប្អូន ដរាបណាបងប្អូនបានយកឈ្នះលើភាពទន់ខ្សោយ និងទម្លាប់អាក្រក់របស់ខ្លួននោះទេ ។ ទ្រង់ស្រឡាញ់បងប្អូននៅថ្ងៃនេះ ដោយបានជ្រាបគ្រប់យ៉ាងពីឧបសគ្គរបស់បងប្អូន ។ . . . ទ្រង់ជ្រាបពីវិប្បដិសារីរបស់បងប្អូនចំពោះគ្រាដែលបងប្អូនមានកំហុស ឬបរាជ័យ ។ **ហើយទ្រង់នៅតែស្រឡាញ់បងប្អូន** » ( « ការរស់នៅតាមដំណឹងល្អដោយក្ដីអំណរ » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ១២៣ ការសង្កត់ន័យត្រូវបានបន្ថែម ) ។

ផ្ទុយទៅវិញ សាតាំងនឹងព្យាយាមធ្វើឲ្យបងប្អូនជឿថា បងប្អូនទៅជ្រុលហួសពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និងពីព្រះចេស្ដារបស់ព្រះអង្គសង្គ្រោះដើម្បីផ្លាស់ប្រែ និងសម្អាតបងប្អូន ។ សាតាំងនឹងព្យាយាមធ្វើឲ្យបងប្អូនជាប់នៅក្នុងទឹកគួចនៃភាពអាម៉ាស់ និងការស្អប់ខ្ពើមខ្លួនឯង ប៉ុន្តែសូមកុំជឿការកុហករបស់វាឡើយ ។

តែសូមងាកទៅកាន់ព្រះវរបិតាសួគ៌វិញ ។ **សូមកុំខ្លាច**នឹងបើកដួងចិត្តនិយាយទៅកាន់ប៊ីស្សព ឬប្រធានសាខារបស់បងប្អូន និងអ្នកផ្សេងទៀតដែលស្រឡាញ់បងប្អូន ។ កាលដែលបងប្អូនអានរឿងរ៉ាវទាំងឡាយនៃសេចក្ដីសង្ឃឹមពីយុវមជ្ឈិមវ័យផ្សេងទៀត ដែលបានរងការប៉ះពាល់ដោយការញៀន នោះសូមប្រព្រឹត្តិទៅតាមការបំផុសគំនិតដែលបងប្អូនបានទទួល ។ **សូមអត់ធ្មត់ជាមួយខ្លួនឯង សូមចងចាំពីធម្មជាតិដ៏ទេវភាពរបស់បងប្អូន ធ្វើមួយថ្ងៃម្ដងៗ ហើយសូមជឿទៅលើព្រះចេស្ដានៃការប្រោសឲ្យជារបស់ព្រះយេស៊ូវគ្រីស្ទ ។** ទ្រង់ ព្រមជាមួយនឹងធនធានជាច្រើន នឹងជួយបងប្អូននៅក្នុងការស្វែងរកសេរីភាពដែលយើងប្រាថ្នាចង់បាន ។ សូមកុំបោះបង់ឡើយ ។

មិត្តរបស់បងប្អូន
រីឆាត អសប្លឺរ



# តើការញៀនដូចគ្នានឹងការបះបោរដែរឬទេ ?

## ការយល់ដឹងប្រសើរមួយអំពីការញៀន អាចជួយយើងឲ្យទុកចិត្តថាថ្ងៃមួយ ព្រះអម្ចាស់នឹងរំដោះយើងឲ្យរួចពីសេវកភាព ។

**ដោយ ដេស្នីនី យ៉ាប្រូ**

នៅក្នុងពិភពលោកដ៏ធ្លាក់ចុះរបស់យើង ការញៀនគឺជាភាពពិតដ៏ថប់អារម្មណ៍ និងផ្លាស់ប្ដូរជីវិតសម្រាប់មនុស្សមួយចំនួនន ។ ពេលយើងប្រើប្រាស់អ្វីមួយដោយហួសកម្រិត ដើម្បីគេចពី ជីវិត ដូចជា អាហារ ថ្នាំត្រូវមានវេជ្ជបញ្ជា បណ្ដាញសង្គម ការនិយាយដើមគេ ការណ៍អាសគ្រាម ការកុហក់ ល្បែងស៊ីសង ឬសូម្បីតែជាការហាត់ប្រាកម្រិ យើងអាចងាយ នឹងឃើញថា ខ្លួនយើងជាប់នៅក្នុងវដ្ដនៃការញៀនមួយ ។

កាលដែលខ្ញុំមើលឃើញមនុស្សដ៏ប្រពៃ ពេញដោយក្ដីស្រឡាញ់ ស្រទន់នៅជុំវិញខ្ញុំ ជួបការលំបាកនឹងការញៀន មិនត្រឹមតែចុះចាញ់នឹងជម្រើសខុសប៉ុណ្ណោះទេ ខ្ញុំបានងាកទៅរកព្រះគម្ពីរ និងការស្រាវជ្រាវថ្មីៗអំពីការញៀន ដើម្បីយល់ឲ្យកាន់តែប្រសើរឡើងពីកម្លាំងចរន្តចិត្តនៃសរសៃប្រសាទ និងចំណង់ដែលពិបាកនឹងទប់ទាំងនេះ ។

### ស្មៅនៃការញៀន

ការគ្រប់គ្រងការញៀនអាចប្រដូចទៅនឹងការថែសួន ។ យើងមិនមែនដកស្មៅចេញតែម្ដង ហើយរំពឹងថារួចហើយនោះទេ ។ យើងដឹងថាស្មៅនឹងដុះឡើងទៀត ដូច្នេះយើងដកស្មៅចេញដោយប្រុងប្រយ័ត្ន និងជាទៀងទាត់ដើម្បីការពារដំណាំ ។

ប្រសិនបើយើងកំពុងពុះពារនឹងការញៀន យើងអាចក្លាយជាបាក់ទឹកចិត្តពេលយើងភ្លាត់ម្ដងទៀត សូម្បីតែបន្ទាប់ពីការប្រែចិត្ត និងស្វែងរកជំនួយហើយក៏ដោយ ។ យើងអាចនឹងភ្ញាក់ផ្អើល ហើយថប់អារម្មណ៍ ដែលការល្បួងទាំងនេះខ្លាំងឡើង ជាពិសេសបន្ទាប់ពីគ្រាដ៏រីករាយខ្លាំង ឬសោកសៅខ្លាំងនៅក្នុងជីវិតរបស់យើង ។ ( ដូចជាស្មៅដែលទំនងជានឹងលូតលាស់ថែមទៀតបន្ទាប់ពីភ្លៀងធ្លាក់ដ៏ស្រស់ស្រាយ ឬព្យុះដ៏ខ្លាំងរួចមក ) ។

### ការញៀន ទល់នឹង ការបះបោរដោយចេតនា

ខ្ញុំបានឃើញថា សាតាំងប្រើប្រាស់ការញៀនជា « ភស្ដុតាង » ថាយើងមានបំណងប្រាថ្នាជាប់ទាក់ទងនឹងការអាក្រក់ ថាយើងត្រូវវិនាសតាំងពីដំបូង ឬថាព្រះអម្ចាស់បានបោះបង់យើងចោលហើយ ។ អារក្សប្រើប្រាស់ភាពអាម៉ាស់ ដើម្បីបំបាក់ទឹកចិត្តយើង ដោយចង្អុលបង្ហាញថា មិនថាយើងប្រែចិត្តប៉ុន្មានដងទេ ការល្បួងនៅតែបន្តកើតឡើង ។

មានហេតុផលជាច្រើន ដែលមនុស្សងាយនឹងញៀន ប៉ុន្តែជាញឹកញាប់ការញៀនច្រើនចាប់ផ្ដើមដោយការប៉ុនប៉ងដើម្បីធ្វើឲ្យស្កប់ស្កល់ដល់ « តម្រូវការស៊ីជម្រៅ និងមិនពេញលេញ » ។[១] ដូច្នេះ ខណៈដែលការបះបោរ*អាច*នាំទៅកាន់ការញៀន ហើយការញៀន*អាច*បណ្ដាលឲ្យមានបាប នោះជាញឹកញាប់ ពួកវាត្រូវបានសាបព្រោះ ឬពង្រីកភាពទន់ខ្សោយជាជាងឲ្យការបះបោរដោយចេតនា ។[២]

សូមអរគុណ ដែលយើងដឹងថា ភាពទន់ខ្សោយអាចផ្ដល់ឲ្យយើងនូវឱកាសដើម្បីរៀនអំពីព្រះគុណ ហើយអភិវឌ្ឍសេចក្ដីជំនឿដ៏ជ្រាលជ្រៅលើព្រះចេស្ដានៃការប្រោសឲ្យជារបស់ព្រះយេស៊ូវគ្រីស្ទ ។[៣]

## ទម្រាំដល់ការរំដោះឲ្យរួចពីសេវកភាព

យើងរកឃើញការយល់ដឹងក្នុងការគ្រប់គ្រង និងដោះខ្លួនចេញពីអន្ទាក់នៃការញៀន ពីមនុស្សពីរក្រុមនៅក្នុងព្រះគម្ពីរមរមន ៖ ប្រជាជនរបស់លិមហៃ និងប្រជាជនរបស់អាលម៉ា ។

ក្រុមទាំងពីរបាននៅក្នុងសេវកភាពអស់ពេលយ៉ាងយូរ ។ ទាំងពីរក្រុមបានដឹងថា « គ្មានផ្លូវណា ដែលគេអាចដោះខ្លួនឲ្យរួច » ពីការជាប់ឃុំឃាំងនោះឡើយ ( ម៉ូសាយ ២១:៥ ) ។ ជាមួយនឹងពេលវេលា ទាំងពីរក្រុមបានងាកទៅរកព្រះអម្ចាស់ដើម្បីបានជំនួយ ។

ប្រជាជនរបស់លិមហៃបាននៅក្នុងសេវកភាព ដោយសារមូលហេតុនៃអំពើរំលងទាំងឡាយ ។ ដោយមិនបានស្វែងរកជំនួយរបស់ព្រះអម្ចាស់ ពួកគេបានតយុទ្ធនឹងអ្នកជិះជាន់ពួកគេទាំង « ខឹង » ចំនួនបីដង ។ ពួកគេបានចាញ់រាល់ដង ។ ពេលពួកគេបានចាប់ផ្ដើមបន្ទាបខ្លួនរបស់ពួកគេ « ព្រះអម្ចាស់ទ្រង់ក្រឰសម្រែករបស់ពួកគេ . . . [ ប៉ុន្តែទ្រង់ ] *គង់តែ . . . បាន*ឮសម្រែករបស់គេដែរ ហើយបានចាប់ផ្ដើមបន្ទន់ចិត្តពួកលេមិន ដើម្បីពួកគេបានចាប់ផ្ដើមសម្រាលបន្ទុកឲ្យគេ » ( ម៉ូសាយ ២១:១៥ ការសង្កត់ន័យត្រូវបានបន្ថែម ) ។ ពួកគេត្រូវបានប្រទានពរចំពោះការបង្កើនការបន្ទាបខ្លួនរបស់ពួកគេ ប៉ុន្តែ « ព្រះអម្ចាស់ទ្រង់មិនបានទតឃើញថាល្អមនឹងដោះពួកគេឲ្យផុតពីសេវកភាពនៅឡើយទេ » រហូតដល់ពេលក្រោយយូរទៀត ។

ប្រជាជនរបស់អាលម៉ាបាននៅក្នុងសេវកភាព ថ្វីបើពួកគេសុចរិតក្ដី ប៉ុន្តែពួកគេ « បានថ្វាយដួងចិត្តគេដល់ [ ព្រះ ] » ។ សូម្បីតែបានត្រាស់ដឹងពីបំណងប្រាថ្នាដ៏សុចរិតរបស់ពួកគេក្ដី ក៏ព្រះបានអនុញ្ញាតឲ្យមានពេលវេលាងការជាប់ឃុំឃាំង និងការរំដោះឲ្យរួចរបស់ពួកគេដែរ ។ កាលដែលពួកគេបន្តពឹងផ្អែកលើទ្រង់ នោះទ្រង់បានសន្យាថាទ្រង់នឹង « សម្រាលបន្ទុកទាំងឡាយដែលដាក់នៅលើស្មាអ្នកផង ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាចចាប់អារម្មណ៍ថា មានបន្ទុកទាំងនោះនៅលើខ្នងអ្នកឡើយ ទោះនៅពេលអ្នកជាប់នៅក្នុងសេវកភាព [ នៅឡើយ ] ក្ដី » ។ ជាការតបស្នង ពួកគេ « បានធ្វើតាមអស់ទាំងព្រះហឫទ័យនៃព្រះអម្ចាស់ ដោយការរីករាយ និងដោយការអត់ធន់ » ( ម៉ូសាយ ២៤:១២, ១៤, ១៥ ) ។

នៅទីបំផុតមនុស្សទាំងពីរក្រុមនោះត្រូវបានរំដោះឲ្យរួច ។ យើងក៏ត្រូវបានសន្យាផងដែរថា ប្រសិនបើយើងងាកទៅរកព្រះអម្ចាស់នៅក្នុងសេវកភាពរបស់យើង នោះយើង « អាចឈរជាសាក្សីដល់ [ ទ្រង់] ពីអំណឹះតទៅ » ហើយនឹង « ដឹងជាពិតប្រាកដថា . . . ព្រះអម្ចាស់ដ៏ជាព្រះ [ ពិតជា ] មករករាស្ត្រ [ ទ្រង់ ] ក្នុងពេលគេស្ថិតក្នុងសេចក្ដីវេទនា » ( ម៉ូសាយ ២៤:១៤ ) —និងការញៀនរបស់ពួកគេ !

## ចូរក្សាន្តចិត្តចុះ

ប្រសិនបើបងប្អូនកំពុងពុះពារជាមួយនឹងការញៀន សូមចងចាំថា ជាមួយនឹងជំនួយរបស់ព្រះអម្ចាស់ ពេលវេលានេះអាចជាដីដ៏មានជីវជាតិដើម្បីដាំដុះលក្ខណៈដូចព្រះគ្រីស្ទ ។ កាលដែលបងប្អូនបង្កើនការបន្ទាបខ្លួន បងប្អូននឹងអាចរៀនការអត់ធ្មត់ ការអាណិតអាសូរ ការអត់ធន់ និងភាពរាបទាប ។

សូមជួបនឹងថ្នាក់ដឹកនាំបព្វជិតភាពរបស់បងប្អូន និងអ្នកដែលអាចផ្ដល់ការគាំទ្រ ហើយប្រើប្រាស់ឧបករណ៍ដែលព្រះវរបិតាសួគ៌បានប្រទាន ដើម្បីជួយបងប្អូនស្វែងរកសេរីភាព ។ សូមពឹងផ្អែកទៅលើព្រះអម្ចាស់ កាលដែលបងប្អូនធ្វើតាមទ្រង់ដោយឧស្សាហ៍ ព្យាយាម ទ្រង់អាចផ្លាស់ប្រែឧបសគ្គដ៏នឿយណាយ និងថប់អារម្មណ៍នេះ
ទៅជាឱកាសដ៏មានអានុភាពសម្រាប់ការចម្រាញ់ខាងវិញ្ញាណ ។[៤]

ពួកបរិសុទ្ធថ្ងៃចុងក្រោយជនជាតិអូស្ត្រាលីពីជំនាន់មុនម្នាក់ ពេលដែលប្រៀបធៀបពីអតីតកាលរបស់គាត់ជាមួយនឹងបច្ចុប្បន្នកាលរបស់គាត់ បាននិយាយដូចនេះ ៖ « ជីវិតអតីតកាលរបស់ខ្ញុំ [ ជា ] ទីវាលស្មៅឥតបានការ ដែលស្ទើរតែគ្មានផ្កាដុះនៅក្នុងចំណោមនោះទេ ។ [ ប៉ុន្តែ ] ឥឡូវនេះ ស្មៅនោះបានបាត់ទៅ ហើយមានផ្កាដុះឡើងនៅកន្លែងរបស់វា » ។[៥]

កាលដែលបងប្អូន និងខ្ញុំដកស្មៅពីសួនរបស់យើងដោយខ្ជាប់ខ្ជួន ហើយងាកទៅរកព្រះអម្ចាស់នៅក្នុងការសាកល្បងរបស់យើង នោះយើងនឹងទទួលបានការសន្យាដែលបានប្រទានដល់ប្រជាជនរបស់អាលម៉ា ៖ « ចូរក្សាន្តចិត្តចុះ ព្រោះថ្ងៃស្អែក យើងនឹងដោះអ្នកឲ្យរួចផុតពីសេវកភាពហើយ » ( ម៉ូសាយ ២៤:១៦ ) ។

ចូរបន្តដកស្មៅ—ការប្រមូលផលគឺសមនឹងការប្រឹងប្រែងនោះ » ■

*អ្នកនិពន្ធរស់នៅរដ្ឋតិចសាស ស.រ.អា. ។*

**កំណត់ចំណាំ**

១. ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល « Jesus: The Perfect Leader » *Ensign,* ខែ សីហា ឆ្នាំ ១៩៧៩ ទំព័រ ៥ ។
២. សូមមើល កូរិនថូស ទី១ ១៥:៤២–៤៤ ។
៣. សូមមើល កូរិនថូស ទី២ ១២:៩; អេធើរ ១២:២៧ ។
៤. សូមមើល អេសាយ ៥១:៣ ។
៥. ម៉ាសា ម៉ារៀ ហាំប្រ៊ី បានដកស្រង់ពី ម៉ាចូរី នូតុន *Southern Cross Saints: The Mormons in Australia* ( ១៩៩១ ) ទំព័រ ១៥៨ ។



# គន្លឹះ ៧ ចំណុចសម្រាប់ការយកឈ្នះលើការប្រើប្រាស់ការណ៍អាសគ្រាម



ក្នុងការធ្វើការជាមួយយុវមជ្ឈិមវ័យនៅលីវ ព្យាយាមដើម្បីយកឈ្នះលើការប្រើប្រាស់ការណ៍អាសគ្រាមដែលពិបាកនឹងទប់បាន ខ្ញុំបានរកឃើញគន្លឹះមួយចំនួនដែលបងប្អូនអាចឃើញថាមានប្រយោជន៍ផងដែរ ។



ដោយ រីឆាត អសថ្លែរ

ពេលខ្ញុំត្រូវបានញែកចេញជាប៊ីស្សពថ្មីម្នាក់នៃវួដយុវមជ្ឈិមវ័យនៅលីវ មានយុវមជ្ឈិមវ័យនៅលីវតម្រង់ជួរមួយជួរខាងក្រៅទ្វារការិយាល័យរបស់ខ្ញុំរង់ចាំជួបនឹងខ្ញុំ ។ សូមទាយទៅមើលថា យើងបានពិភាក្សាពីអ្វីនៅក្នុងការសម្ភាសលើកទីមួយនោះ ?

ការណ៍អាសគ្រាម ។

ហើយរយៈពេលបីឆ្នាំក្រោយមក ការព្យាយាមជួយដល់យុវមជ្ឈិមវ័យយកឈ្នះទម្លាប់ដែលពិបាកនឹងទប់បានមួយ គឺជាចំណុចសំខាន់នៃការហៅបម្រើរបស់ខ្ញុំ ដូច្នេះខ្ញុំបានដឹងថា ខ្ញុំត្រូវរៀនឲ្យបានច្រើនបំផុតតាមដែលខ្ញុំអាចធ្វើទៅបាន ។ ខ្ញុំបានតមអាហារ អធិស្ឋាន ទៅព្រះវិហារបរិសុទ្ធ ប្រឹក្សានឹងថ្នាក់ដឹកនាំផ្សេងៗទៀត បានពិនិត្យមើលធនធានទាំងអស់ដែលមាន បានចូលរួមថ្នាក់កម្មវិធីព្យាបាលការញៀន និងបានរៀនពីពួកអ្នកដែលខិតខំរកការព្យាបាល ។ ខ្ញុំចង់ចែកចាយគំនិតដ៏មានសង្ឃឹមមួយចំនួនអំពីអ្វីដែលខ្ញុំបានរៀន ។

### ១. សូមដឹងថាបងប្អូនជាបុត្រម្នាក់របស់ព្រះបិតាព្រះមាតាសួគ៌ដែលស្រឡាញ់បងប្អូន

ប្រសិនបើបងប្អូនកំពុងខិតខំយកឈ្នះលើការប្រើប្រាស់ការណ៍អាសគ្រាមដែលពិបាកនឹងទប់បាន បងប្អូនអាចនឹងមានអារម្មណ៍ដូចជា ការទាញចេញពីព្រះវរបិតាសួគ៌ ដោយសារបងប្អូនគិតថា បងប្អូនមិនសក្តិសមនឹងសេចក្តីស្រឡាញ់ ឬជំនួយ ទាល់តែបងប្អូនដោះស្រាយបញ្ហានោះសិន ។ នេះគឺពិតជាអ្វីដែលសាតាំងចង់បាន—គឺដើម្បីបំបែកបងប្អូនចេញពីគេឯងគ្រប់គ្នាដែលស្រឡាញ់បងប្អូន ដោយផ្តល់គំនិតថា បងប្អូនអាចយកឈ្នះការណ៍អាសគ្រាមដោយខ្លួនឯងបាន ហើយថា ទាល់តែដល់ពេលនោះទើបបងប្អូននឹងសក្តិសមនឹងទទួលសេចក្តីស្រឡាញ់ ។

ដោយសារតែធម្មជាតិដ៏ទេវភាពរបស់បងប្អូន បងប្អូនតែងតែសក្តិសមដើម្បីទទួលសេចក្តីសង្ឃឹមការបំផុសគំនិត និងវិវរណៈផ្ទាល់ខ្លួនពីព្រះវរបិតាសួគ៌ និងព្រះចេស្តានៃការប្រោសឲ្យជារបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីយកឈ្នះការណ៍អាសគ្រាមបាន ។[1] សូមកុំចេញឆ្ងាយពីពួកទ្រង់ ឬពីមនុស្សដែលស្រឡាញ់បងប្អូន ។

រូបភាពខ្សែបន្ទាត់ពី GETTY IMAGES



## ២. ដកភាពអាម៉ាស់ចេញ

ខ្ញុំបានរៀនថា ការដកភាពអាម៉ាស់ចេញ គឺចាំបាច់ណាស់ចំពោះការយកឈ្នះលើការណ៍អាសគ្រាម ។ ភាពអាម៉ាស់គឺជាអារម្មណ៍ដូចជាបងប្អូនជាមនុស្សបាក់បែកខូចខាត ឬជាមនុស្សអាក្រក់ ។ ការជឿតាមគំនិតដ៏ខូចខាតទាំងនេះអំពីខ្លួនឯងតាមពិតទៅអាចធ្វើឲ្យបងប្អូនជាប់អន្ទាក់ក្នុងវដ្តនៃការញៀន ។ ការមានវិប្បដិសារីចំពោះអ្វីដែលបងប្អូនបានធ្វើ គឺជាផ្នែកនៃដំណើរការប្រែចិត្ត ហើយអាចជួយបងប្អូនផ្លាស់ប្តូរឥរិយាបទរបស់បងប្អូនបាន ។ ប៉ុន្តែភាពអាម៉ាស់ធ្វើឲ្យបងប្អូនមានអារម្មណ៍ថា លក្ខណៈសម្បត្តិទាំងស្រុងរបស់បងប្អូនគឺអាក្រក់ ហើយថាបងប្អូនមិនសមទទួលជំនួយពីព្រះអង្គសង្គ្រោះឡើយ ។[២]

ព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យបងប្អូនមានក្តីសង្ឃឹមពេញលេញលើព្រះយេស៊ូវគ្រីស្ទ និងពរជ័យនៃដង្វាយធួនរបស់ទ្រង់ ។ ភាពអាម៉ាស់ធ្វើឲ្យយើងគិតតែពីអតីតកាល ធ្វើឲ្យបងប្អូនជាប់នៅក្នុងគំនួចនៃការកុហក់ និងការស្អប់ខ្ពើមខ្លួនឯង ។ សូមនៅឲ្យឆ្ងាយពីផ្លូវនៃភាពអាម៉ាស់ ។

## ៣. កុំប្រញាប់ប្រើស្លាកនៃ « ការញៀន »

មនុស្សជាច្រើនដាក់ស្លាកខ្លួនឯងថា « ញៀន » នឹងការណ៍អាសគ្រាម ។ ខ្ញុំសូមឲ្យបងប្អូនប្រុងប្រយ័ត្ន ដើម្បីកុំឲ្យយកស្លាកនោះមកដាក់លើខ្លួនដោយមិនត្រឹមត្រូវឡើយ ។ មនុស្សវ័យក្មេងភាគច្រើនបំផុត ដែលប្រឈមមុខនឹងការណ៍អាសគ្រាមតាមពិតទៅមិនញៀននោះទេ ។[៣] ហើយការប្រើប្រាស់ស្លាកនេះដោយមិនត្រឹមត្រូវអាចធ្វើឲ្យវាកាន់តែពិបាកដើម្បីបញ្ឈប់ការប្រើប្រាស់ការណ៍អាសគ្រាម ដោយសារតែភាពអាម៉ាស់ ក្តីសង្ឃឹមធ្លាក់ចុះ និងការស្អប់ខ្ពើមខ្លួនឯង ដែលមកពីភាពអាម៉ាស់នោះឯង ។

## ៤. បង្កើតផែនការការពារសរសេរដោយផ្ទាល់ខ្លួនមួយ

ផែនការការពារផ្ទាល់ខ្លួនមួយ គឺជាឯកសារបីផ្នែក ដែលអាចជួយបងប្អូនយកឈ្នះលើការណ៍អាសគ្រាមបាន ។

*ផ្នែកទី ១ ៖* សរសេរពាយពីអ្វីដែលបញ្ឆេះឲ្យបងប្អូនធ្វើ ។ ការដែលត្រូវបានបញ្ឆេះឲ្យធ្វើ គឺជាជំហានទីមួយនៅក្នុងវដ្តនោះ ដែលនាំទៅកាន់ការមើលការណ៍អាសគ្រាម ។

មានការបញ្ឆេះច្រើនប្រភេទ ។

- **ស្ថានភាព ៖** បរិយាកាសដែលបង្កើតឲ្យមានការបញ្ឆេះមួយ ដោយសារតែគំនិត ឬឥរិយាបទពីអតីតកាល ( ដូចជានៅក្នុងបន្ទប់ដដែល ឬនៅពេលជាក់លាក់មួយ )
- **ភាពតានតឹង/ការថប់បារម្ភ/ភាពឯកោ/ព្រឹត្តិការណ៍ដែលតក់ស្លុត ៖** អារម្មណ៍ ឬស្ថានភាពដ៏ពិបាកនានា ដែលបញ្ឆេះបងប្អូនឲ្យបែរទៅរកការណ៍អាសគ្រាមទុកជារបៀបមួយដើម្បីគេច និងដោះស្រាយអារម្មណ៍ទាំងនេះ







- **គំហើញ ៖** ការឃើញអ្វីមួយដោយអចេតនាដែលមិនមែនជាការណ៍អាសគ្រាម ប៉ុន្តែធ្វើឲ្យមានការបញ្ឆេះតាមរយៈបណ្ដាញសង្គម ខ្សែភាពយន្ត រូបភាព ។ ល ។

*ផ្នែកទី ២ ៖* ដាក់ផែនការមួយដើម្បីកាត់បន្ថយការបញ្ឆេះទាំងឡាយ ។

ឧទាហរណ៍ ប្រសិនបើបងប្អូនមានស្ថានភាពបញ្ឆេះមួយ ដូចជាការមានអារម្មណ៍ឯកាយរងគ្រោះនៅយប់ជ្រៅ ការបិទទូរសព្ទរបស់បងប្អូន ៣០នាទី មុនពេលចូលគេង ឬការចូលគេងដោយគ្មានទូរសព្ទនៅក្នុងបន្ទប់របស់បងប្អូនអាចជួយបាន ។ ប្រសិនបើការណ៍អាសគ្រាមគឺជារបៀបមួយដែលបងប្អូនដោះស្រាយនឹងអារម្មណ៍ពិបាក សូមស្វែងរករបៀបនានា ដើម្បីដោះស្រាយបានប្រសើរជាងជាមួយនឹងអារម្មណ៍ទាំងនេះ ។ តើការហាត់ប្រាណ ឬថ្នាំ អាចជួយបងប្អូនឲ្យកាត់បន្ថយកម្រិតនៃភាពតានតឹង និងការថប់បារម្ភរបស់បងប្អូនបានដែរឬទេ ? តើការទៅខាងក្រៅជាមួយមិត្តភក្តិ ឬការចុះឈ្មោះចូលរៀនថ្នាក់វិទ្យាស្ថាន អាចកាត់បន្ថយភាពឯកោបានទេ ? សូមពិចារណាអ្វីដែលបងប្អូនកំពុងជួបប្រឈមមុខជាមួយ និងជម្រើសអ្វីខ្លះដែលអាចមានប្រយោជន៍ដល់បងប្អូន ។

ទន្ទឹមនឹងនោះដែរ **សូមកុំមើលស្រាលធនធានខាងវិញ្ញាណ** ។ ការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការបម្រើ និងការចូលរួមនៅព្រះវិហារ ព្រមទាំងព្រះវិហារបរិសុទ្ធ គឺជាធនធានដ៏មានអានុភាពដែលចាំបាច់ណាស់នៅក្នុងការកាត់បន្ថយការបញ្ឆេះនានា ហើយជួយដល់បងប្អូនឲ្យបន្តរឹងមាំ ។

*ផ្នែកទី ៣ ៖* ដាក់ផែនការពីអ្វីដែលបងប្អូននឹងធ្វើ ពេលដែលបងប្អូនត្រូវបានបញ្ឆេះ ។ សូមសរសេរផែនការដែលមានច្រើនជំហានរបស់បងប្អូន សម្រាប់ការបញ្ឆេះនីមួយៗ ។

ឧទាហរណ៍ ពេលបងប្អូនត្រូវបានបញ្ឆេះ បងប្អូនអាចបិទទូរសព្ទរបស់បងប្អូនភ្លាម ផ្ញើសារ ឬទូរសព្ទទៅនរណាម្នាក់ ទៅដើរ ឬហាត់ប្រាណ អានព្រះគម្ពីរមរមន ឬធ្វើអ្វីផ្សេងទៀតណាក៏ដោយដែលអាចជួយបងប្អូនតម្រង់គំនិតរបស់បងប្អូន ។

សូមសរសេរពីជំហានទាំងឡាយដែលជួយដល់បងប្អូន ! ជួនកាលការបញ្ឆេះទាំងឡាយនឹងរំលងផុតទៅ ដោយមិនចាំបាច់ធ្វើជំហានទាំងអស់ក្នុងផែនការការពាររបស់បងប្អូនទេ ។ ប៉ុន្តែជំហានទាំងឡាយរបស់បងប្អូនអាចជួយទាញបងប្អូនចេញពីគ្រានោះបាន ។ ពេលដែលការបញ្ឆេះនោះរំលងផុតទៅ សូមធ្វើបច្ចុប្បន្នភាពដល់ផែនការការពាររបស់បងប្អូនទៅលើអ្វីដែលដំណើរការបានល្អ និងរបៀបដែលវាអាចត្រូវបានកែសម្រួលដើម្បីឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនៅពេលក្រោយ ។ រក្សាវានៅកន្លែងដែលបងប្អូនអាចមើលឃើញវាជារៀងរាល់ថ្ងៃ ។

## ៥. យល់ពីការភ្លាត់ និងការភ្លាត់ទៀត

ការភ្លាត់គឺជាពេលដែលបងប្អូនធ្វើខុស ប៉ុន្តែបងប្អូនកែប្រែភ្លាមៗ ហើយប្រើប្រាស់វាទុកជាបទពិសោធន៍រៀនសូត្រមួយ ដើម្បីកែលម្អផែនការការពាររបស់បងប្អូន ។ ការភ្លាត់ទៀត គឺជាពេលដែលបងប្អូនបោះបង់ចោល បណ្ដោយខ្លួនហួសហេតុ ហើយមិនខ្វល់ខ្វាយ ។

សូមដឹងថា ការភ្លាត់គឺជាផ្នែកនៃការកែលម្អផែនការការពាររបស់បងប្អូន ។ សូមកុំសន្មត់ថា បងប្អូនបានបាត់បង់ការរីកចម្រើនទាំងអស់របស់បងប្អូន ឬការខិតខំទាំងអស់ដែលបងប្អូនបានធ្វើជាការឥតប្រយោជន៍នោះ—ពីព្រោះវាពិតជាមានប្រយោជន៍ ។ សូមមើលឆ្ពោះទៅមុខដោយឥរិយាបថវិជ្ជមាន ហើយសូមដឹងថា បងប្អូនខិតកាន់តែជិតដល់ការព្យាបាលមួយថ្ងៃទៀតហើយ ។

ពេលបងប្អូនមានការភ្លាត់មួយ សូមសួរខ្លួនឯងថា ៖

- តើមានរឿងអ្វីបានកើតឡើង ?
- ហេតុអ្វីការបញ្ឆេះនេះខុសគ្នា ?
- តើបងប្អូនមានភាពតានតឹងខ្លាំងឬមួយរយៈថ្មីៗនេះ ? តើបងប្អូនមានអារម្មណ៍យ៉ាងណាដែរ ?
- តើការមិនបានសិក្សាព្រះគម្ពីរមួយរយៈធ្វើឲ្យបងប្អូនទន់ខ្សោយឬ ?
- តើបងប្អូនមិនបានហាត់ប្រាណច្រើនទេឬថ្មីៗនេះ ?
- តើអ្វីមួយនៅក្នុងផែនការការពាររបស់បងប្អូនមិនបានដំណើរការល្អឬ ?
- តើបងប្អូនអាចធ្វើអ្វីខុសពីនេះនៅពេលក្រោយទៀត ?

សូមសរសេរនូវអ្វីដែលបងប្អូនកំពុងរៀនសូត្រ ហើយបន្តទៅមុខទៀត !



## ៦. ជឿលើព្រះចេស្ដានៃការប្រោសឲ្យជារបស់ព្រះអង្គសង្គ្រោះ

ព្រះយេស៊ូវគ្រីស្ទអាចជួយបងប្អូននៅក្នុងដំណើរដែលកំពុងចម្រើនលូតលាស់នៃការប្រែចិត្តនេះ ហើយទ្រង់មានព្រះចេស្ដាដើម្បីជួយបងប្អូនកាលដែលបងប្អូនពុះពារព្យាយាមយកឈ្នះលើការណ៍អាសគ្រាម ។ ទ្រង់យល់ថាបងប្អូនមានអារម្មណ៍យ៉ាងណា ហើយរង់ចាំយកបន្ទុកនោះចេញពីបងប្អូន ។ សូមកុំគិតថា ការងាកទៅរកទ្រង់បន្ថែមបន្ទុកឲ្យទ្រង់នោះឡើយ ។ ទ្រង់បានបង់ថ្លៃសម្រាប់បងប្អូនរួចហើយ ។ ផ្ទុយទៅវិញ សូមធ្វើឲ្យអស់ពីសមត្ថភាពរបស់បងប្អូន ចូលមកឲ្យកាន់តែជិតព្រះអង្គសង្គ្រោះ ហើយទូលសូមទ្រង់ឲ្យជួយបងប្អូនបានជា ដើម្បីផ្លាស់ប្ដូរបំណងប្រាថ្នារបស់បងប្អូន និងដើម្បីប្រទានដល់បងប្អូននូវកម្លាំងបន្ថែមទៀតដើម្បីបន្តឆ្ពោះទៅមុខ ។

ដូចអែលឌើរ អូលីសេស សូរ៉េស ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖ « កាលយើងបន្តខំយកឈ្នះលើឧបសគ្គរបស់យើង នោះព្រះនឹងប្រទានពរយើងនូវអំណោយនៃសេចក្ដីជំនឿដើម្បីបានសះស្បើយ និងនៃកិច្ចការនៃអព្ភូតហេតុ ។ ទ្រង់បានធ្វើសម្រាប់យើងនូវអ្វីដែលយើងមិនអាចធ្វើសម្រាប់ខ្លួនយើងបាន » ។[៤]

## ៧. កុំធ្វើវាតែម្នាក់ឯងឡើយ

ទំនាក់ទំនង និងមិត្តភាពក៏អាចផ្ដល់ថាមពល និងជំនួយដល់បងប្អូនឲ្យទទួលបានជោគជ័យផងដែរ ។ បងប្អូនគប្បីមាននរណាម្នាក់ដែលអាចជួយបងប្អូនឲ្យរក្សាការទទួលខុសត្រូវលើខ្លួនឯង ហើយនៅជួយបងប្អូនអំឡុងថ្ងៃល្អបំផុត និងអាក្រក់បំផុតរបស់បងប្អូន ។ ពួកគេគប្បីគាំទ្របងប្អូនដោយមិនវិនិច្ឆ័យលើបងប្អូន ។ ហើយបងប្អូនក៏អាចផ្ដល់ការគាំទ្រដូចគ្នានោះសម្រាប់ពួកគេផងដែរ ។ សូមស្វែងរកការប្រឹក្សាពីថ្នាក់ដឹកនាំសាសនាចក្រ ឬពីសមាជិកគ្រួសាររបស់បងប្អូន ។ ហើយប្រសិនបើចាំបាច់ អ្នកព្យាបាល ឬទីប្រឹក្សាផ្នែកជំនាញសុខភាពផ្លូវចិត្ត ក៏អាចជួយបងប្អូនរកឃើញពីមូលហេតុជាក់ស្ដែង ដែលធ្វើឲ្យបងប្អូនអាចនឹងមានការលំបាកជាមួយនឹងការណ៍អាសគ្រាម ។

## សូមចងចាំថា បងប្អូនជាឪពុកម្ដាយ និងថ្នាក់ដឹកនាំនៃថ្ងៃស្អែក

បងប្អូនជាជំនាន់ដំបូង ដែលអាចចូលមើលការណ៍អាគ្រាមបានគ្រប់ពេលទាំងអស់ ។ ខ្ញុំជឿថា ឧបសគ្គនេះមកដល់ចំណុចកំពូលជាមួយនឹងជំនាន់របស់បងប្អូន ដោយសារបងប្អូននឹងមានធនធាន និងប្រាជ្ញាដ៏ល្អប្រសើរ ដើម្បីដឹកនាំអ្នកផ្សេងទៀតចេញពីអន្ទាក់នេះ ពេលដែលបងប្អូនជាឪពុកម្ដាយ និងថ្នាក់ដឹកនាំនៅថ្ងៃមួយ ។ « ព្រះវរបិតាសួគ៌ពុំទុកយើងនៅលើផែនដី ដើម្បីឲ្យបរាជ័យទេ ប៉ុន្តែដើម្បីទទួលជោគជ័យដ៏រុងរឿង » ។[៥]

ថ្វីបើគន្លឹះទាំងនេះអាចជួយដល់កិច្ចប្រឹងប្រែងរបស់បងប្អូនក្នុងការយកឈ្នះការណ៍អាសគ្រាម សូមកុំខ្លាចនឹងងាកទៅរកធនធានផ្សេងៗទៀតផងដែរ ។ ដំណើររបស់មនុស្សគ្រប់គ្នាទៅកាន់ការព្យាបាលគឺខុសៗគ្នា ។ សូមស្វែងរកអ្វីដែលជួយដល់បងប្អូន ។ សូមកុំចុះចាញ់ឡើយ ។ ធ្វើវាមួយថ្ងៃម្ដងៗ ។ បងប្អូនអាចធ្វើវាបាន ។ បងប្អូនពិតជាអាច ( សូមមើល ភីលីព ៤:១៣ ) ។ ហើយបងប្អូននឹងក្លាយជាមនុស្សម្នាក់ដែលបងប្អូនត្រូវប្រែក្លាយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

១. ស៊ីស្ទើរ ចយ ឌី ចូនស៍ បានពន្យល់ពីភាពខុសគ្នារវាងតម្លៃ និងភាពសក្ដិសមនៅក្នុង « តម្លៃហួសពីការអាចវាស់វែងបាន » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១៤ ។

២. សូមមើល វេនឌី អ៊ុលរីឆ « ភាពទន់ខ្សោយមិនមែនជាអំពើបាបនោះទេ » *លីអាហូណា* ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ២៣ ។ « Shame versus Guilt: Help for Discerning God's Voice from Satan's Lies » ( អត្ថបទដែលមានតែឌីជីថលប៉ុណ្ណោះ ) *Ensign,* ខែ មករា ឆ្នាំ ២០២០ ។

៣. សូមមើល ដាល្លិន អេក អូក « ការជាសះស្បើយពីអន្ទាក់នៃការណ៍អាសគ្រាម » *លីអាហូណា* ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ៥២ ។ ប្រធានអូកពិពណ៌នាអំពីភាពខុសគ្នារវាងកម្រិតខុសគ្នានៃការពាក់ព័ន្ធជាមួយការណ៍អាសគ្រាម ៖ « (១) ប្រទះភ្នែកដោយចៃដន្យ (២) មើលម្ដងម្កាល (៣) មានបំណងមើល និង (៤) អន្ទះសាចង់មើល ( ញៀន ) » ។ វាមានប្រយោជន៍ដើម្បីដឹងថា មិនមែនមនុស្សគ្រប់គ្នាដែលប្រើប្រាស់ការណ៍អាសគ្រាមសុទ្ធតែ « ញៀន » នោះទេ ។ មានសេចក្ដីសង្ឃឹមសម្រាប់ការយកឈ្នះការណ៍អាសគ្រាម មិនថាបងប្អូនស្ថិតនៅក្នុងកម្រិតពាក់ព័ន្ធណាមួយនោះទេ ។

៤. អូលីសេស សូរ៉េស « ផ្ទុកឈើឆ្កាងរបស់យើង » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៩ ទំព័រ ១១៤ ។

៥. រីឆាដ ជី ស្កត « Learning to Recognize Answers to Prayer » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ទំព័រ ៣០ ។




DOCTRINAL MASTERY





# ពេលដែលខ្ញុំត្រូវបានញែកចេញ

ដើម្បីបម្រើនៅក្នុងបេសកកម្មកាលីហ្វូញ៉ា សែន បិនណាឌីណូ ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងមួយរូប គ្រួសាររបស់ខ្ញុំបាននៅទីនោះជាមួយខ្ញុំ ។ រូបថតនេះគឺខ្ញុំកំពុងឱបបងប្រុសរបស់ខ្ញុំម្នាក់ បន្ទាប់ពីខ្ញុំត្រូវបានញែកចេញ ។ វាជាការធ្វើដំណើរមួយដើម្បីមកដល់ចំណុចនេះ ប៉ុន្តែខ្ញុំមានអំណរគុណណាស់សម្រាប់ការផ្លាស់ប្តូរដែលខ្ញុំបានឃើញនៅក្នុងខ្លួនខ្ញុំ និងនៅក្នុងគ្រួសាររបស់ខ្ញុំ ។

ពេលខ្ញុំនៅថ្នាក់ទី ១១ នៅវិទ្យាល័យ ខ្ញុំបានជួបនឹងគ្រោះថ្នាក់រថយន្តដ៏ធ្ងន់ធ្ងរមួយ ។ ពីមុននោះ ខ្ញុំមិនបានធ្វើអ្វីៗដែលខ្ញុំគួរតែធ្វើទេ ។ ប៉ុន្តែបន្ទាប់ពីគ្រោះថ្នាក់រថយន្តនោះមក ទស្សនៈរបស់ខ្ញុំពិតជាបានផ្លាស់ប្តូរ ។ ជីវិតរបស់ខ្ញុំអាចត្រូវបាត់បង់នៅពេលនោះ និងនៅទីនោះ ហើយខ្ញុំពុំចង់ឲ្យវាបញ្ចប់យ៉ាងដូច្នោះទេ ។ ប៊ីស្សពរបស់ខ្ញុំបានជួយខ្ញុំឲ្យដើរនៅលើផ្លូវត្រូវវិញ ៖ អានព្រះគម្ពីរមរមនជារៀងរាល់ថ្ងៃ និងរៀបចំដើម្បីបម្រើបេសកកម្មមួយ ។

ការរត់ប្រណាំងជាកីឡារបស់ខ្ញុំ ជាចំណង់ចំណូលត្តរបស់ខ្ញុំ ។ បន្ទាប់ពីគ្រោះថ្នាក់នោះ ខ្ញុំមិនអាចរត់បានទេដោយសារតែវាផុតរដូវកាលរត់ប្រណាំងហើយ ហើយខ្ញុំបានឆ្ងល់ថាតើខ្ញុំនៅសេសសល់អ្វីទៀត ។ ប៉ុន្តែខ្ញុំបានងាកទៅរកព្រះអម្ចាស់ ហើយកាលដែលខ្ញុំបានធ្វើដូច្នោះ ខ្ញុំបានចូលរួមរដូវកាលរត់ប្រណាំងដ៏អស្ចារ្យមួយនៅឆ្នាំបន្ទាប់នោះ ។ នៅតែមានការលំបាក ប៉ុន្តែអ្វីដែលបានផ្លាស់ប្តូរគឺ ជំនួសឲ្យការធ្វើវាសម្រាប់ខ្លួនឯង ខ្ញុំបានធ្វើវាសម្រាប់ព្រះអម្ចាស់ ។

ការឃើញពីរបៀបដែលពរជ័យជាច្រើនអាចបានមកពីភាពពេញលេញនៃដំណឹងល្អ ជាអ្វីដែលបានផ្លាស់ប្តូរខ្ញុំ ។ ដោយទទួលបានសុភមង្គល និងអំណរទាំងអស់នោះ នោះខ្ញុំចង់ចែកចាយវានៅជុំវិញពិភពលោក ។ ខ្ញុំចង់ឲ្យមនុស្សមានអំណរដែលខ្ញុំមានជារៀងរាល់ថ្ងៃដោយសារដំណឹងល្អ ។ នោះហើយជាមូលហេតុដែលខ្ញុំបម្រើបេសកកម្មមួយ ៖ ដើម្បីជួយ « នាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ ១:៣៩ ) ។

**ហ្គែររែត ដាប់បលយូ អាយុ ១៨ ឆ្នាំ** រដ្ឋណសខារ៉ូឡៃណា ស.រ.អា

មាតិកា


៥៨


៥៤ ការបម្រើប្រចាំថ្ងៃរបស់ម៉ាថា
ដោយ សេម លូហ្វហ្គ្រាម

៥៨ របៀបដែលខ្ញុំបានរកឃើញការព្យាបាលពីការរំលោភបំពានផ្លូវភេទ
ឈ្មោះត្រូវបានដកចេញ

៦២ សំណួរ និងចម្លើយ តើដោះស្រាយនឹងភាពឯកោដោយរបៀបណា ? តើខ្ញុំអាចបម្រើបេសកកម្មមួយជាមួយនឹងឧបសគ្គខាងសុខភាពផ្លូវចិត្តបានដែរឬទេ ?

៦៤ ពាក្យចុងក្រោយ សេចក្ដីសង្ឃឹមរបស់យើង ពន្លឺរបស់យើង កម្លាំងរបស់យើង
ដោយអែលឌើ រ៉ូណាល អេ រ៉ាសបាន

៦៥ មនុស្សក្នុងព្រះគម្ពីរមរមន
បងប្រុសយ៉ារេឌ

# ការបម្រើ



# បំរើ របស់ម៉ាថា

*ម្តាយ និងកូននេះខិតខំណាស់ដើម្បីរស់នៅតាមដំណឹងល្អជាមួយគ្នា ។ ម៉ាថាអាចរស់នៅតាមដំណឹងល្អ ដោយការបម្រើដល់ម្តាយនាងក្នុងរបៀបដ៏ពិសេសមួយ ។*









រូបថតដោយ ឡេស្លី និលសុន

**ដោយ សេម លូហ្វហ្គ្រាម**
ទស្សនាវដ្តីសាសនាចក្រ

ម៉ាថាជាយុវនារីអាយុ ១១ ឆ្នាំ មកពីប្រទេសព័រទុយហ្គាល់ ហើយដូចជាក្មេងស្រីជាច្រើនអាយុស្របាលនាងដែរ នាងចូលចិត្តចំណាយពេលជាមួយមិត្តភក្តិ ញ៉ាំអាហារ និងលេងជាមួយកូនតុក្កតា ។ នាងក៏ចូលចិត្តចំណាយពេលជាមួយម្តាយនាងផងដែរ ។ ប៉ុន្តែការរស់នៅជាមួយម្តាយនាង មានន័យថា ម៉ាថារស់នៅខុសគ្នាបន្តិចពីក្មេងដទៃទៀត ។

សូណៃ ម្តាយរបស់ម៉ាថា បានកើតមកជាមួយនឹងភាពទន់ខ្សោយខាងចលនា ដែលធ្វើឲ្យគាត់ពិបាកដើរ ។ គិតមិនមែនពិការទាំងស្រុងនោះទេ ប៉ុន្តែគាត់ពិតជាត្រូវការឧបករណ៍ជំនួយដើម្បីដើរ ។ គាត់មិនអាចស្លៀកពាក់ដោយខ្លួនឯង ងូតទឹកខ្លួនឯង ឬឡើងគ្រែដេកដោយខ្លួនឯងបាននោះទេ ។ ការណ៍នេះធ្វើឲ្យវាពិបាកសម្រាប់គាត់ដើម្បីរស់នៅម្នាក់ឯង ។ ម៉ាថាមានលទ្ធភាពដើម្បីបម្រើសូណៃ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយការជួយគាត់ជាមួយអ្វីៗដែលគាត់ពុំអាចធ្វើដោយខ្លួនឯងបាន ។

ម៉ាថានិយាយថា « ខ្ញុំរក្សាកន្លែងខ្ញុំឲ្យបានស្អាត ដើម្បីម្តាយខ្ញុំអាចទៅមកងាយស្រួល » ។ « ខ្ញុំក៏សម្រាកពីការលេងផងដែរ ដើម្បីខ្ញុំអាចមើលម្តាយខ្ញុំ និងមើលថាបើគាត់ត្រូវការអ្វីដែរឬទេ ។ បើខ្ញុំកំពុងលេង ហើយគាត់ហៅ ខ្ញុំនឹងប្រញាប់ទៅដោយសារវាអាចមានការបន្ទាន់អ្វីមួយ » ។

ប៉ុន្តែសូណៃព្យាយាមធ្វើឲ្យម៉ាថារស់នៅធម្មតាបំផុតតាមដែលគាត់អាចធ្វើទៅបាន ។ ប្រសិនបើសូណៃពុំត្រូវការជំនួយអ្វីទេ គាត់ធ្វើឲ្យប្រាកដថា ម៉ាថាមានពេលលេងជាមួយនឹងមិត្តភក្តិរបស់នាង ។



## ការរស់នៅតាមសេចក្តីជំនឿរបស់ពួកគេ

ម៉ាថាមានឱកាសដើម្បីរស់នៅតាមដំណឹងល្អជារៀងរាល់ថ្ងៃ ដោយការបម្រើម្ដាយនាង ។ នាងយកដាក់មកលើខ្លួននូវការទទួលខុសត្រូវជាច្រើន ដែលជាធម្មតាក្មេងៗដទៃទៀតពុំមាន ។ ឧទាហរណ៍ នាងភ្ញាក់ពីព្រលឹមដើម្បីជួយម្ដាយនាងរៀបចំខ្លួនទៅធ្វើការមុនពេលទៅសាលា ។ បើគ្មានជំនួយពីម៉ាថាទេ សូណៃនឹងមិនអាចទៅណាមកណាឬទៅធ្វើការជារៀងរាល់ថ្ងៃបានឡើយ ។

ម៉ាថា និងសូណៃក៏ទៅព្រះវិហារជាមួយគ្នាផងដែរ ។ សូណៃបានទទួលបុណ្យជ្រមុជទឹកពេលគាត់អាយុប្រាំបីឆ្នាំ ដូច្នេះម៉ាថាធំឡើងនៅក្នុងសាសនាចក្រ ។ សូណៃបង្រៀនម៉ាថាអំពីសារសំខាន់នៃដំណឹងល្អជារៀងរាល់ថ្ងៃ ។ វិធីមួយដែលគាត់ធ្វើការណ៍នេះ គឺដោយការមានរូបភាពរបស់ព្រះយេស៊ូវគ្រីស្ទជាច្រើននៅក្នុងផ្ទះរបស់ពួកគេ ។

សូណៃនិយាយថា « ខ្ញុំដឹងថា ព្រះមានព្រះជន្មរស់ ហើយថាព្រះយេស៊ូវគ្រីស្ទគឺពិត » ។ « ហើយខ្ញុំចង់ឲ្យមនុស្សគ្រប់គ្នាដែលមកផ្ទះខ្ញុំដឹងថា សេចក្តីជំនឿគឺសំខាន់ខ្លាំងណាស់ចំពោះខ្ញុំ ។ វាក៏សំខាន់ផងដែរសម្រាប់ខ្ញុំ ដើម្បីបង្រៀនការណ៍នេះដល់ម៉ាថាដើម្បីឲ្យនាងធំឡើងជាមួយនឹងការចេះដឹងនេះអំពីព្រះយេស៊ូវគ្រីស្ទ » ។

ម៉ាថាបានយកអ្វីដែលម្ដាយនាងបង្រៀននាង ហើយបន្តរៀនបន្ថែមទៀតអំពីដំណឹងល្អដោយខ្លួននាងផ្ទាល់ ។ របៀបមួយដែលនាងចូលចិត្តរៀន គឺដោយការអានព្រះគម្ពីរទាំងឡាយ ដែលជួយនាងឲ្យបង្កើតចំណងទាក់ទងដ៏រឹងមាំមួយជាមួយព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះ ។ នាងនិយាយថា « កាលដែលខ្ញុំអានព្រះគម្ពីរ ខ្ញុំមានអារម្មណ៍ថាព្រះគ្រីស្ទនៅក្បែរខ្ញុំ » ។

## ការស្វែងរកការលួងលោម

ខណៈដែលវាអាចមានការលំបាកក្នុងការមានទំនួលខុសត្រូវជាច្រើន ការទៅព្រះវិហារជារៀងរាល់សប្ដាហ៍ជួយម៉ាថាឲ្យស្វែងរកការលួងលោមដែលនាងត្រូវការ ដើម្បីបន្តជួយម្ដាយរបស់នាង ។ នាងនិយាយថា « ពេលពួកគេអធិស្ឋាននៅពេលចាប់ផ្តើម និងនៅពេលបញ្ចប់នៃការប្រជុំសាក្រាម៉ង់ វាមានភាពសុខសាន្តណាស់ » ។ « ពេលខ្ញុំនៅទីនោះ ជួនកាលខ្ញុំមានអារម្មណ៍ដូចជាព្រះវរបិតាសួគ៌កំពុងប្រាប់ខ្ញុំថា ខ្ញុំជាមនុស្សល្អ ហើយថាខ្ញុំត្រូវតែបន្តធ្វើជាមនុស្សល្អដើម្បីជួយម្ដាយខ្ញុំ » ។









ពេលណានាងមានអារម្មណ៍ដូចនេះ នាងត្រូវបានរំឭកថានាងមានអំណរគុណយ៉ាងខ្លាំងចំពោះម្ដាយនាង ។ នាងមានអារម្មណ៍ថា ព្រះវរបិតាសួគ៌បានបញ្ជូនពួកទេវតាមកគាំទ្រនាង ។ ម៉ាថានិយាយថា « ខ្ញុំគិតថា ទ្រង់ពង្រឹងខ្ញុំឲ្យខ្ញុំភ្ញាក់ឡើង ហើយសប្បាយចិត្ត និងមានមោទនភាពចំពោះម្ដាយដែលខ្ញុំមាន » ។

មេរៀនមួយដែលសូណៃ និងម៉ាថាបានរៀនជាមួយគ្នាគឺថា ជីវិតនេះមិនងាយស្រួលឬឥតខ្ចោះ—សម្រាប់មនុស្សគ្រប់គ្នានោះទេ ។ សូណៃនិយាយថា « ពុំមានការលំបាកណាមួយរបស់ខ្ញុំធ្វើឲ្យខ្ញុំកើតទុក្ខនោះទេ ។ ខ្ញុំដឹងថា ព្រះបានប្រទានដល់ខ្ញុំនូវសាច់ឈាម និងឆ្អឹងនេះតាមរបៀបនេះ ដោយសារខ្ញុំពិសេស ហើយព្រះបានប្រាប់ខ្ញុំថា ខ្ញុំអាចធ្វើវាបាន ។ ខ្ញុំធ្វើវាឲ្យអស់ពីសមត្ថភាព ។ ខ្ញុំអាចធ្វើបន្ថែមទៀត ប៉ុន្តែថ្ងៃនេះ ខ្ញុំមានអារម្មណ៍ធម្មតាចំពោះខ្លួនឯង ។ ខ្ញុំមានមោទនភាពចំពោះអ្វីដែលខ្ញុំធ្វើ អ្វីដែលខ្ញុំមាន និងអ្វីដែលខ្ញុំនឹងធ្វើនៅថ្ងៃស្អែក » ។

ម៉ាថាក៏ដឹងផងដែរថា អ្វីៗនឹងបានល្អ ទោះបីជាជីវិតអាចមានការពិបាកនៅពេលខ្លះ ពេលនាងថែទាំម្ដាយនាង ។ នាងឃើញថា មនុស្សគ្រប់គ្នាមានឧបសគ្គខុសៗគ្នា ។ នាងនិយាយថា « គ្មានជីវិតនរណាម្នាក់ល្អឥតខ្ចោះនោះទេ » ។ ប៉ុន្តែ សូម្បីតែមានឧបសគ្គផ្ទាល់ខ្លួនរបស់នាងក្ដី ម៉ាថានៅតែរកឃើញនូវអ្វីៗដែលល្អនៅក្នុងគ្រប់ស្ថានភាព—ចំណងទាក់ទងដែលនាងមានជាមួយនឹងម្ដាយនាងគឺជាគំរូមួយ ។ « ម្ដាយខ្ញុំមានដែនកំណត់ខាងរាងកាយ ប៉ុន្តែបញ្ញាស្មារតី និងអារម្មណ៍គាត់មានភាពវាងវៃណាស់ ។ យើងពិតជាមិត្តដ៏ល្អណាស់ » ។

## មើលឆ្ពោះទៅមុខ

ដូច្នេះ តើមានអ្វីនៅក្នុងពេលអនាគតសម្រាប់ម៉ាថា និងសូណៃ ? ម៉ាថានិយាយថា « ខ្ញុំចង់នៅជិតម្ដាយខ្ញុំ ហើយពិតណាស់ខ្ញុំចង់រៀបការ មានកូន និងមានគ្រួសារមួយ ។ ប៉ុន្តែនៅក្នុងពេលអនាគត ប្រសិនបើអាច ខ្ញុំចង់ទិញផ្ទះមួយសម្រាប់គ្រួសារខ្ញុំ និងម្ដាយខ្ញុំ ដោយសារខ្ញុំមិនចង់នៅឆ្ងាយពីគាត់ទេ សូម្បីតែមួយថ្ងៃ ! »

សូណៃមានអារម្មណ៍សុទិដ្ឋិនិយមអំពីអនាគតផងដែរ ហើយនឹងតែងតែមានអំណរគុណសម្រាប់ភាពជាដៃគូ និងសេចក្ដីស្រឡាញ់របស់ម៉ាថា ។ « វាអស្ចារ្យណាស់ដែលមានកូនស្រីដ៏ប្រពៃម្នាក់ ។ វាល្អណាស់ដែលមានម៉ាថាក្នុងជីវិតខ្ញុំ ។ នាងជាអំណោយទានមកពីព្រះ ។ ទ្រង់បានរៀបចំម៉ាថាដើម្បីមកនៅជាមួយនឹងខ្ញុំ ។ ■



ខ្ញុំបានរស់នៅក្នុងសុបិនដ៏អាក្រក់មួយ ។
ប៉ុន្តែក្រោយមកខ្ញុំបានរៀនថា អំឡុងគ្រា
ដ៏ងងឹតបំផុតរបស់ខ្ញុំ ខ្ញុំអាចពឹងផ្អែកទៅ
លើព្រះអង្គសង្គ្រោះរបស់ខ្ញុំ ។

# របៀបដែលខ្ញុំបានរកឃើញការព្យាបាល *ពីការរំលោភបំពានផ្លូវភេទ*

ឈ្មោះត្រូវបានដកចេញ

ស្បិនអាក្រក់របស់ខ្ញុំបានចាប់ផ្តើម ពេលខ្ញុំទើបតែមានអាយុប្រាំពីរឆ្នាំ ហើយម្តាយខ្ញុំបានរៀបការម្តងទៀត ។ យើងពិតជាចូលចិត្តឪពុកចុងថ្មីរបស់ខ្ញុំ ។ គាត់មានសន្តានចិត្តល្អ ហើយចុះសម្រុងនឹងគ្រួសារយើងណាស់ ។ ខ្ញុំមានអារម្មណ៍ថាមានសុវត្ថភាពណាស់ពេលនៅក្បែរគាត់ ។ អ្វីៗគ្រប់យ៉ាងគឺល្អណាស់ រហូតដល់ថ្ងៃមួយ ពេលដែលសមាជិកគ្រួសារគ្រប់គ្នាផ្សេងទៀតរវល់ គាត់បានរំលោភខ្ញុំ ។

ខ្ញុំមិនយល់ពីអ្វីដែលគាត់បានធ្វើចំពោះខ្ញុំនោះទេ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាច ភាន់ច្រឡំ ហើយអាម៉ាស់ខ្លាំងណាស់ ។ ប៉ុន្តែខ្ញុំក៏មានការបារម្ភនឹងប្រាប់គ្រប់គ្នាផងដែរ ។ ខ្ញុំបានគិតថា វានឹងបំផ្លាញសុភមង្គលថ្មីរបស់គ្រួសារខ្ញុំ ហើយថានឹងគ្មាននរណាជឿខ្ញុំឡើយ ។ ដូច្នេះ ខ្ញុំបានសម្រេចចិត្តមិននិយាយពីវា ។

គាត់បានធ្វើឲ្យខ្ញុំឈឺចាប់តែម្តងនោះ តែការចងចាំពីការរំលោភងតែមានឥទ្ធិពលលើគំនិតខ្ញុំ ។ ទីបំផុត ខ្ញុំបានក្លាយជាមនុស្សដែលមានគំនិតចេះតែភ័យខ្លាចថា នរណាម្នាក់នឹងមើលឃើញពីការឈឺចាប់របស់ខ្ញុំ ហើយលាតត្រដាងការសម្ងាត់របស់ខ្ញុំ រហូតដល់ខ្ញុំបានព្យាយាមលាក់ការពិតដោយការធ្វើជាមិត្តល្អជាមួយឪពុកចុងខ្ញុំទៀតផង ។ គាត់មានសន្តានចិត្តល្អជាពិសេសចំពោះខ្ញុំ ហើយតាមពិតទៅខ្ញុំបានចាប់ផ្តើមចូលចិត្តគាត់ម្តងទៀត ។

ប៉ុន្តែបន្ទាប់មកអ្វីៗក្លាយកាន់តែអាក្រក់ឡើង ។ ពេលម៉ាក់បានចាប់ផ្តើមធ្វើការពេលយប់ ឪពុកចុងខ្ញុំបានចាប់ផ្តើមរំលោភខ្ញុំជាប្រចាំ ។ ខ្ញុំមានអារម្មណ៍ថាគ្មានទីពឹងងសោះ ។ ខ្ញុំចង់ប្រាប់ពីវា ប៉ុន្តែគ្រប់គ្នាចូលចិត្តឪពុកចុងខ្ញុំណាស់ ហើយខ្ញុំបានគិតថា គ្រប់គ្នានឹងនៅខាងគាត់ ។ ដូច្នេះនៅពេលយប់ ពេលខ្ញុំនៅតែឯង ខ្ញុំបានទូលអង្វរព្រះឲ្យជួយខ្ញុំរក្សារឿងសម្ងាត់របស់ខ្ញុំ ។

## ត្រូវហ៊ាននិយាយ

នៅទីបំផុតថ្ងៃណាមួយ ការរំលោភបំពាននោះត្រូវបានបញ្ឈប់ ។ ខ្ញុំមិនដឹងថាហេតុអ្វីនោះទេ ។ ទោះបីជាគាត់មិនបានរំលោភខ្ញុំទៀត ក៏ខ្ញុំតែងតែមានអារម្មណ៍ថាកខ្វក់ ហើយអាម៉ាស់ ។ ខ្ញុំបានស្អប់ខ្លួនឯង ។ ពេលខ្លះខ្ញុំថែមទាំងបានវែកញែកថា បើការស្លាប់វាងាយស្រួលជាងភាពពិតរបស់ខ្ញុំឬទេ ។ ខ្ញុំនៅតែចង់ប្រាប់ពីវា ប៉ុន្តែខ្ញុំបារម្ភពីអ្វីដែលនឹងកើតឡើងបើខ្ញុំប្រាប់ការពិតនោះ ។

បន្ទាប់មក នៅថ្ងៃអាទិត្យមួយនៅព្រះវិហារ ពេលខ្ញុំអាយុ ១៤ ឆ្នាំ ខ្ញុំបានស្តាប់ដល់មេរៀនមួយអំពីការធ្វើការសម្រេចចិត្តដ៏ធំទាំងឡាយ ។ គ្រូរបស់ខ្ញុំបានលើកទឹកចិត្តយើងឲ្យតមអាហារ ហើយអធិស្ឋាន និងបានសន្យាថា ព្រះនឹងពង្រឹងយើងឲ្យធ្វើអ្វីដែលត្រឹមត្រូវ ។ បន្ទាប់ពីចេញពីព្រះវិហារ ខ្ញុំបានបន្តគិតអំពីអ្វីដែលគាត់បាននិយាយ ។ ខ្ញុំឆ្ងល់ថា បើខ្ញុំទូលសូម តើព្រះនឹងពិតជាជួយខ្ញុំឲ្យនិយាយប្រាប់ដែរឬទេ ?

ស្អែកឡើង ខ្ញុំបានតមអាហារដើម្បីទទួលបានភាពក្លាហានដើម្បីប្រាប់ម្តាយខ្ញុំ អំពីការរំលោភបំពាននោះ ។ ខ្ញុំមិនអាចផ្តោតអារម្មណ៍នៅសាលាទេ ដោយសារអ្វីដែលខ្ញុំអាចគិតឃើញ គឺថាតើគាត់នឹងមានប្រតិកម្មយ៉ាងណា ? ទម្រាំដល់ពេលខ្ញុំមកដល់ផ្ទះ ខ្ញុំមានអារម្មណ៍ឈឺខ្លាំងមែនទែន ។ ខ្ញុំបានអធិស្ឋានម្តងទៀតដើម្បីបានកម្លាំង ប៉ុន្តែខ្ញុំពុំមានអារម្មណ៍ថាបានត្រៀមរួចរាល់ដើម្បីប្រាប់គាត់ទេ ។

រូបថតមកពី Getty Images បានប្រើសម្រាប់គោលបំណងជាឧទាហរណ៍ បង្ហាញដោយតារា



នៅល្ងាចនោះ ខ្ញុំបានទៅកាន់ម្ដាយខ្ញុំពេលគាត់កំពុងចម្អិនអាហារពេលល្ងាច ។ ខ្ញុំមិនដឹងថាត្រូវនិយាយអ្វីនោះទេ ប៉ុន្តែពេលខ្ញុំបានសម្លឹងទៅក្នុងក្រសែភ្នែកគាត់ ខ្ញុំបានរកឃើញភាពក្លាហានដើម្បីចាប់ផ្ដើមនិយាយ ។ ពេលខ្ញុំបានចាប់ផ្ដើម អ្វីៗគ្រប់យ៉ាងដែលបានលាក់ទុកអស់ជាច្រើនឆ្នាំបានហូរចេញមកអស់ ។

ម៉ាក់ និងខ្ញុំបានអង្គុយនៅលើសាឡុង ហើយយំជាមួយគ្នា ។ ក្រោយពីនោះមក យើងបានទាក់ទងទៅប្រធានសាខារបស់យើង ហើយបានហៅប៉ូលីស ។ ឪពុកចុងខ្ញុំបានទទួលខុសត្រូវចំពោះអ្វីដែលគាត់បានធ្វើចំពោះខ្ញុំ ហើយខ្ញុំបានទទួលការការពារដែលខ្ញុំត្រូវការ—ខ្ញុំនឹងមិនបាច់ជួបគាត់ម្ដងទៀតទេ ។

## ផ្លូវទៅកាន់ការជាសះស្បើយ

អំឡុងពេលនោះ វាពិបាកក្នុងការប្រាប់ឡើងវិញពីបទពិសោធន៍របស់ខ្ញុំដល់អ្នកមានសិទ្ធិអំណាច និងការមានមិត្តភក្តិសួរថា ឪពុកចុងខ្ញុំទៅណា ប៉ុន្តែដោយមានការគាំទ្រពីគ្រួសារខ្ញុំ ខ្ញុំមិនឯកោទៀតទេ ។ ជាមួយគ្នាយើងបានប្រមូលគ្នាប្រកាន់នូវបាវចនាគ្រួសារថ្មីមួយ « ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ » ( ភីលីព ៤:១៣ ) ។ គ្រួសារជិតឆ្ងាយយើងក៏បានផ្ដល់ក្ដីស្រឡាញ់ និងការគាំទ្ររបស់ពួកគេផងដែរ ហើយបន្តិចម្ដងៗ យើងបានចាប់ផ្ដើមជាសះស្បើយជាមួយគ្នា ។

ម៉ាក់ និងខ្ញុំ យើងទាំងពីរបានទទួលការប្រឹក្សាជំនាញដែលបានជួយយើងខ្លាំងណាស់ ! ទីប្រឹក្សារបស់ខ្ញុំគឺជាអ្វីដែលខ្ញុំពិតជាត្រូវការ ។ គាត់បានជួយខ្ញុំឲ្យយល់ពីអារម្មណ៍ទាំងអស់ដែលខ្ញុំបានមាន ហើយបានជួយខ្ញុំឲ្យដោះស្រាយនឹងការចងចាំអាក្រក់ៗរបស់ខ្ញុំ ។ ខ្ញុំមិនដែលបានដឹងទេថាខ្ញុំឈឺចាប់ប៉ុណ្ណា រហូតដល់ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍សះស្បើយឡើងវិញ ។

ខ្ញុំពុំបានគិតថា ការឈឺចាប់នោះនឹងបាត់ទៅវិញ ដោយគ្រាន់តែដោយសារខ្ញុំបាននិយាយប្រាប់នោះទេ ប៉ុន្តែខ្ញុំមិនបានដឹងផងដែរថា វាត្រូវការពេលវេលា ( និងការអត់ធ្មត់ ) ច្រើនប៉ុណ្ណាដើម្បីបានជាសះស្បើយនោះ ។ ខ្ញុំបានមានអារម្មណ៍ថាគ្មានតម្លៃអស់រយៈពេលយ៉ាងយូរ ។ ខ្ញុំត្រូវតែរៀនឡើងវិញដើម្បីស្រឡាញ់ខ្លួនឯង ។

ខ្ញុំបានរកឃើញភាពសុខសាន្តបំផុត ពេលខ្ញុំងាកទៅរកព្រះអង្គសង្គ្រោះ និងព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ការដឹងថា ពួកទ្រង់*ពិតជា*ត្រាស់ដឹងថា ខ្ញុំបានមានអារម្មណ៍បែបណា បានផ្ដល់នូវកម្លាំង និងក្ដីសង្ឃឹមដល់ខ្ញុំ ។ ខ្ញុំបានពឹងផ្អែកលើពួកទ្រង់ អំឡុងគ្រាដ៏ងងឹតបំផុត ។ យូរៗទៅ ការចងចាំទាំងនោះបានចាប់ផ្ដើមរសាយទៅ ហើយខ្ញុំពិតជាមានអារម្មណ៍សុខសាន្តតាមរយៈសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។

ផ្នែកដ៏មានរង្វាន់បំផុតមួយនៃដំណើរការជាសះស្បើយ គឺការដឹងថា ខ្ញុំ*ពិតជា*មានអនាគតដ៏ចែងចាំងមួយ ។ ពេលដែលខ្ញុំត្រូវបានរំលោភបំពាន ខ្ញុំមិនទាំងអាចស្រមៃពីការមានជីវិតដ៏ធម្មតាមួយផង ។ ខ្ញុំបានមានអារម្មណ៍ថាត្រូវបាក់បែករហូត ។ ប៉ុន្តែតាមរយៈជំនួយ និងការជាសះស្បើយ ខ្ញុំបានរកឃើញអ្វីៗដែលខ្ញុំទន្ទឹងរង់ចាំ ។ ខ្ញុំបានចាប់ផ្ដើមប្រាប់រឿងខ្ញុំដល់ក្មេងស្រីផ្សេងៗទៀត ដែលមានការឈឺចាប់ ហើយថែមទាំងបានសម្រេចចិត្តដើម្បីបម្រើបេសកកម្មទៀតផង ។ ការចែកចាយទីបន្ទាល់របស់ខ្ញុំជាមួយមនុស្សដទៃទៀត បានពង្រឹងខ្ញុំ ។

ខ្ញុំមិនត្រូវបានកំណត់អត្តសញ្ញាណដោយអ្វីដែលឪពុកចុងខ្ញុំបានធ្វើចំពោះខ្ញុំនោះទេ ។ គាត់បានផ្លាស់ប្ដូរជីវិតខ្ញុំជារៀងរហូត ប៉ុន្តែខ្ញុំជ្រើសរើសដើម្បីប្រើប្រាស់បទពិសោធន៍របស់ខ្ញុំដើម្បីជួយមនុស្សផ្សេងទៀត ។ ថ្ងៃខ្លះនៅតែពិបាក ប៉ុន្តែតាមរយៈអ្វីៗគ្រប់យ៉ាង ព្រះអម្ចាស់បានពង្រឹងខ្ញុំ ហើយខ្ញុំដឹងថា ទ្រង់នឹងបន្តជួយដល់ខ្ញុំ ។ ខ្ញុំបានប្រែក្លាយពីជនរងគ្រោះទៅជាអ្នករស់រានមានជីវិតម្នាក់ ។ ■

## ប្រសិនបងប្អូនជាជនរងគ្រោះនៃការរំលោភបំពាន

### តើអ្វីជាការរំលោភបំពាន ?

ការរំលោភបំពានគឺជាការមិនយកចិត្តទុកដាក់ ឬធ្វើបាបមនុស្សដទៃ ( ដូចជា កុមារ មនុស្សចាស់ មនុស្សពិការ ឬនរណាផ្សេងទៀតក៏ដោយ ) តាមវិធីមួយដែលមានទុក្ខទោសខាងរាងកាយ ខាងសតិអារម្មណ៍ ឬខាងផ្លូវភេទ ។ វាប្រឆាំងនឹងការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ។

« ជំហររបស់សាសនាចក្រគឺថា ការរំលោភបំពានពុំអាចត្រូវបានអត់ឱនបានឡើយ ទោះនៅក្នុងទម្រង់ណាក៏ដោយ » ( *ក្បួនខ្នាតទូទៅ ៖ ការបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* [ ឆ្នាំ ២០២០ ] ចំណុច ៣៨.៦.២ ។ ការរំលោភបំពានគឺល្មើសនឹងក្រឹត្យវិន័យរបស់ព្រះ ហើយក៏អាចនឹងល្មើសនឹងច្បាប់ក្នុងសង្គមផងដែរ ។

### ប្រភេទខុសៗគ្នានៃការរំលោភបំពាន

**ការរំលោភបំពានខាងរាងកាយ ៖** អាកប្បកិរិយាដែលឈ្លានពាន ឬហឹង្សាដោយចេតនារបស់បុគ្គលម្នាក់ ទៅកាន់មនុស្សផ្សេងទៀត ដែលអាចធ្វើឲ្យមានរបួសខាងរាងកាយ ។

**ការរំលោភបំពានខាងផ្លូវភេទ ៖** សកម្មភាព ឬទំនាក់ទំនងផ្លូវភេទដែលមិនចង់ ដែលជនល្មើសប្រើកម្លាំង ធ្វើការគំរាមគំហែង ឬយកប្រៀបលើជនរងគ្រោះដែលមិនអាចមានលទ្ធភាពផ្តល់ការយល់ព្រម ។ សកម្មភាពផ្លូវភេទទាំងអស់រវាងមជ្ឈិមវ័យម្នាក់ និងកុមារម្នាក់គឺជាការរំលោភបំពានមិនថាមានការយល់ព្រមឬអត់នោះទេ ។

**ការរំលោភបំពានខាងពាក្យសម្ដី ឬខាងសតិអារម្មណ៍ ៖** ជាលំនាំនៃអាកប្បកិរិយាមួយដែលបុគ្គលម្នាក់វាយប្រហារដោយចេតនា និងដដែលៗ ទៅលើនរណាម្នាក់ក្នុងរបៀបមួយដែលមិនមែនខាងរាងកាយ ដូចជា ពាក្យគំរោះគំរើយ ការបំភិតបំភ័យ ការគ្រប់គ្រងដោយឧបាយកល ឬការធ្វើឲ្យអាម៉ាស់ ។ ការណ៍នេះបណ្ដាលឲ្យមានអារម្មណ៍បន្ទាបតម្លៃ និងភាពថ្លៃថ្នូររបស់ខ្លួនឯង ។ ទោះបីវាមិនមែនខាងរាងកាយ ក៏ការរំលោភបំពានប្រភេទនេះ ធ្វើឲ្យមានទុក្ខទោសដល់សុខុមាលភាពរបស់មនុស្សម្នាក់ខាងផ្លូវចិត្ត និងសតិអារម្មណ៍ទូទៅ ។

### របៀបដើម្បីទទួលបានជំនួយ

ព្រះអម្ចាស់រំពឹងឲ្យយើងធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើទៅបាន ដើម្បីការពារពីការរំលោភបំពាន ហើយការពារ និងជួយដល់អស់អ្នកទាំងឡាយដែលជាជនរងគ្រោះមកពីការបំពាន ។ គ្មាននរណាម្នាក់ត្រូវបានរំពឹងឲ្យស៊ូទ្រាំនឹងឥរិយាបថរំលោភបំពាននោះទេ ។ មិនថាវាកំពុងកើតឡើងឥឡូវនេះ ឬបានកើតឡើងយូរមកហើយក្ដី បងប្អូនអាចស្វែងរកធនធាននានាដើម្បី ជួយបងប្អូន នៅគេហទំព័រ abuse.ChurchofJesusChrist.org ។

### ចូរទទួលជំនួយឥឡូវនេះ

« ប្រសិនបើបងប្អូនកំពុងត្រូវគេរំលោភបំពានឥឡូវនេះ ឬត្រូវបានរំលោភបំពានពីមុន សូមស្វែងរកភាពក្លាហានដើម្បីស្វែងរកជំនួយ ។ . . . សូមស្វែងរកការគាំទ្រពីនរណាម្នាក់ដែលបងប្អូនអាចទុកចិត្ត ។ ប៊ីស្សព ឬប្រធានស្ដេករបស់បងប្អូន អាចផ្ដល់ប្រឹក្សាដ៏មានតម្លៃដល់បងប្អូន ហើយជួយបងប្អូនជាមួយនឹងអាជ្ញាធរស៊ីវិល ។ . . . សូមកុំភ័យខ្លាច—ត្បិតការភ័យខ្លាចគឺជាឧបករណ៍ដែលសាតាំងនឹងប្រើប្រាស់ដើម្បីឃុំបងប្អូនឲ្យរងទុក្ខ ។ ព្រះអម្ចាស់នឹងជួយបងប្អូន ប៉ុន្តែបងប្អូនត្រូវតែឈោងទៅរកជំនួយ » ។

**អែលឌើរ រីឆាត ជី ស្កត ( ១៩២៨–២០១៥ ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « To Heal the Shattering Consequences of Abuse »** ***Liahona,*** **ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៤២ ។**



# តើខ្ញុំអាចយកឈ្នះលើអារម្មណ៍ឯកោបានយ៉ាងដូចម្ដេច ?

*« ការឈឺចាប់នៃភាពឯកោហាក់ដូចជាផ្នែកមួយនៃបទពិសោធន៍ក្នុងជីវិតរមែងស្លាប់ ។ ប៉ុន្តែ ព្រះអម្ចាស់បានធ្វើដូច្នោះដោយនៅក្នុងក្ដីមេត្តារបស់ទ្រង់ ដើម្បីកុំឲ្យយើងដោះស្រាយឧបសគ្គទាំងឡាយនៃជីវិតរមែងស្លាប់នេះតែម្នាក់ឯងឡើយ ។ . . . យើងត្រូវបានសន្យាឲ្យមានភាពជាដៃគូដ៏ខ្ជាប់ខ្ជួននៃសមាជិកទីបីនៃក្រុមព្រះហេតុដូច្នោះហើយ មានឯកសិទ្ធិក្នុងការទទួលវិវរណៈសម្រាប់ជីវិតយើងផ្ទាល់ ។ យើងពុំបាននៅតែឯងទេ ! »*

សេរី អិល ឌូ អតីតទីប្រឹក្សានៅក្នុងគណៈប្រធានសមាគមន៍សង្គ្រោះទូទៅ « **We Are Not Alone** » ***Liahona,*** ខែ មករា ឆ្នាំ ១៩៩៩ ទំព័រ ១១២ ។



## អភិវឌ្ឍទេពកោសល្យរបស់បងប្អូន

ខ្ញុំយកឈ្នះលើអារម្មណ៍ឯកោរបស់ខ្ញុំដោយការអភិវឌ្ឍទេពកោសល្យរបស់ខ្ញុំ មិនថាវាជាឧបករណ៍តន្ត្រី ចំណង់ចំណូលចិត្ត ។ ល ។ វាជួយបង្វែរបងប្អូនពីអារម្មណ៍ឯកោរបស់បងប្អូន ហើយជាញឹកញាប់វានឹងទៅបាត់ទាំងស្រុងតែម្ដង ។ ការណ៍នេះក៏នឹងនាំទៅកាន់ការស្វែងរកមនុស្សផ្សេងទៀតដែលមានចំណាប់អារម្មណ៍ដូចបងប្អូនផងដែរ ។

*ស្ទីវិន អេចហ៍ អាយុ ១២ ឆ្នាំ រដ្ឋនូវ ម៉ិកស៊ីកូ ស.រ.អា.*



## ស្វែងរកពន្លឺ

ខ្ញុំស្វែងរកការគាំទ្រ ការលើកទឹកចិត្ត និងសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និងព្រះវិញ្ញាណបរិសុទ្ធ ដើម្បីផ្ដល់ភាពសុខសាន្ត ក្ដីសង្ឃឹម និងកម្លាំងដល់ខ្ញុំនៅពេលតាំងសមាធិ អធិស្ឋាន និងអានព្រះគម្ពីរ ។ ដូចមានចែងនៅក្នុង នីហ្វៃទី៣ ១១:១១ ព្រះយេស៊ូវគ្រីស្ទ « គឺជាពន្លឺ និងជាជីវិតនៃពិភពលោក » ។ ទ្រង់យាងមកដើម្បីបណ្ដេញភាពងងឹតទាំងអស់ ។

*អែនឌ្រៀ ប៊ី អាយុ ១៨ ឆ្នាំ រដ្ឋហ្សូលៀ ប្រទេសវ៉េណេស៊ុយអេឡា*

## ងាកទៅរកមិត្តភក្តិ និងគ្រួសារ

ពេលខ្ញុំមានអារម្មណ៍ឯកោ ខ្ញុំចូលចិត្តងាកទៅរកមិត្តភក្តិ និងគ្រួសាររបស់ខ្ញុំ វាពិតជាធ្វើឲ្យខ្ញុំមានអារម្មណ៍រីករាយ ។ ខ្ញុំសម្លឹងមើលពរជ័យទាំងឡាយនៅក្នុងជីវិតខ្ញុំ ហើយអរព្រះគុណព្រះវរបិតាសួគ៌ចំពោះអ្វីៗជាច្រើនដែលទ្រង់បានប្រទានដល់ខ្ញុំរួចហើយ !

*ថាលលី អិន អាយុ ១៦ ឆ្នាំ រដ្ឋអូរីហ្គិន ស.រ.អា.*



ចងចាំអំពីផែនការរបស់ព្រះ

សូមដឹងថា តាមរយៈផែនការរបស់ព្រះ យើងមិនចាំបាច់មានអារម្មណ៍ឯកោឡើយ ។ ព្រះវិញ្ញាណបរិសុទ្ធតែងតែគង់នៅជាមួយយើង ហើយព្រះទ្រង់ជ្រាបដឹងពីអ្វីដែលយើងកំពុងលំបាក ។ ព្រះអម្ចាស់បានឆ្លងកាត់គ្រប់ការសាកល្បង និងការលំបាកទាំងអស់ដែលបងប្អូនប្រឈមមុខ ។ អ្វីដ៏សំខាន់បំផុតមួយដែលយើងទទួលអារម្មណ៍នៅក្នុងជីវិតរមែងស្លាប់នេះ គឺសុភមង្គល ប៉ុន្តែយើងពុំអាចមានសុភមង្គលដោយគ្មានភាពសោកសៅនោះទេ ( សូមមើល នីហ្វៃទី២ ២:១១ ) ។ សូមអធិស្ឋានទៅព្រះ ហើយទូលសូមជំនួយ ទ្រង់នឹងមិនភ្លេចយើងម្នាក់ណាឡើយ ។

*ប្រ៊ុក អេស អាយុ ១៧ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.*

សូមទុកចិត្តលើព្រះអម្ចាស់

ការចាកចេញពីផ្ទះទៅប្រទេសប្រេស៊ីល សម្រាប់បេសកកម្មរបស់ខ្ញុំគឺពិបាក ។ ខ្ញុំស្ទើរតែមិនចេះនិយាយភាសានោះសោះ ! ប៉ុន្តែខ្ញុំបានរៀនថា ប្រសិនបើបងប្អូនមានព្រះវិញ្ញាណរបស់ព្រះអម្ចាស់គង់ជាមួយបងប្អូន នោះបងប្អូនមិនដែលមានអារម្មណ៍ឯកោឡើយ ។ ទ្រង់ស្គាល់បងប្អូន ហើយទ្រង់នឹងជួយបងប្អូន ។ សូមទុកចិត្តទ្រង់ !

*អែលឌើរ យ៉ូសែប ថូលិន អាយុ ២០ ឆ្នាំ បេសកកម្មប្រេស៊ីល កាពីណាស់*

ថតរូបដោយ យេ ជីន ហាន់

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។ ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និងទស្សនវិស័យមិនមែនជាសេចក្តីប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។

***តើអ្នកគិតដូចម្តេច ?***

« តើខ្ញុំគួរតែធ្វើអ្វី ប្រសិនបើខ្ញុំបានប្រែចិត្តហើយ ប៉ុន្តែមិនអាចឈប់គិតអំពីអ្វីដែលខ្ញុំបានធ្វើខុស ? »

សូមផ្ញើចម្លើយរបស់បងប្អូន ហើយប្រសិនបើចង់ សូមផ្ញើរូបថតមានគុណភាពច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ នៅគេហទំព័រ liahona.ChurchofJesusChrist.org ( សូមចុច « Submit an Article or Feedback » ) ។



## ប្រសិនបើខ្ញុំមានឧបសគ្គខាងសុខភាពផ្លូវចិត្ត តើខ្ញុំអាចបម្រើបេសកកម្មមួយបានដែរឬទេ ?

ប្រាកដណាស់ ។ អ្នកទាំងអស់ដែល « មានបំណងចង់បម្រើព្រះ . . . បានហៅឲ្យធ្វើកិច្ចការនោះហើយ » ( គោលលទ្ធិ និងសេចក្តីសញ្ញា ៤:៣ ) ។ *ទីកន្លែង*ដែលយើងបម្រើ គឺមានសារៈសំខាន់តិចជា*របៀប*ដែលយើងបម្រើ ។ ហើយនរណាក៏ដោយដែលគិតចង់បម្រើបេសកកម្មមួយ នឹងត្រូវបានគេយកទៅពិចារណាពីសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ ។

ប្រសិនបើបងប្អូនមានបំណងប្រាថ្នាដើម្បីបម្រើបេសកកម្មមួយ សូមនិយាយជាមួយនឹងប៊ីស្សពរបស់បងប្អូន ។ គាត់អាចជួយបងប្អូនឲ្យចាប់ផ្តើមដំណើរការនៃការដាក់ពាក្យ ។ ផ្នែកនៃដំណើរការនេះគឺរួមមាន ការប្រឹក្សាជាមួយវេជ្ជបណ្ឌិត និងអ្នកជំនាញផ្សេងៗទៀត ក៏ដូចជាថ្នាក់ដឹកនាំសាសនាចក្រ ព្រមទាំងឪពុកម្តាយផងដែរ ។ ការប្រឹក្សាទាំងនេះមិនមែនជាការវាយតម្លៃថាតើបងប្អូន « ល្អគ្រប់គ្រាន់ » សម្រាប់ព្រះអម្ចាស់នោះទេ ប៉ុន្តែដើម្បីជួយកំណត់ជម្រើសល្អបំផុតសម្រាប់ការបម្រើរបស់បងប្អូន ។

*ការហៅ*ឲ្យបម្រើអាចកើតមានចំពោះនរណាដែលមានបំណងប្រាថ្នាដើម្បីបម្រើ ។ *ការចាត់តាំង* ដែលបងប្អូនទទួលដើម្បីបម្រើនៅក្នុងកន្លែងជាក់លាក់មួយ ឬនៅក្នុងរបៀបជាក់លាក់មួយ អាចផ្អែកទៅលើកត្តាជាច្រើន ។ បងប្អូនដែលមានឧបសគ្គខាងសុខភាព ( រួមទាំងសុខភាពផ្លូវចិត្ត ) ជួនកាលបានព្យាយាមដកចេញនូវព័ត៌មានទាំងនេះចេញពីដំណើរការការដាក់ពាក្យ ដោយគិតថានឹងជួយពួកគេឲ្យទទួលបានការចាត់តាំងដែលពួកគេចង់បាន ។ ប៉ុន្តែ ប្រសិនបើបងប្អូនស្មោះត្រង់ទាំងស្រុងអំពីប្រវត្តិវេជ្ជសាស្ត្ររបស់បងប្អូន ( រួមទាំងសុខភាពផ្លូវចិត្ត ) នោះព្រះអម្ចាស់នឹងប្រទានពរដល់បងប្អូន ។ ទ្រង់រំពឹងឲ្យបងប្អូនធ្វើអ្វីទាំងអស់ដែលបងប្អូនអាចធ្វើ ដើម្បីអភិវឌ្ឍសុខភាពរបស់បងប្អូន ។ ហើយការគាំទ្រខាងវេជ្ជសាស្ត្រភាពច្រើនដែលបងប្អូនទទួលនៅផ្ទះ អាចបន្តនៅក្នុងបេសកកម្ម ។

សម្រាប់ព័ត៌មានបន្ថែមអំពីសុខភាពផ្លូវចិត្ត សូមទៅកាន់គេហទំព័រ mentalhealth.ChurchofJesusChrist.org ។
សម្រាប់ព័ត៌មានបន្ថែមអំពីបេសកកម្ម សូមទៅកាន់គេហទំព័រ ChurchofJesusChrist.org/callings/missionary ។

# សេចក្ដីសង្ឃឹមរបស់យើង ពន្លឺរបស់យើង កម្លាំងរបស់យើង

**ដោយអែលឌើរ រ៉ូណល អេ រ៉ាសបាន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

---

នៅពេលខ្ញុំត្រូវបានតែងតាំងជាសាវក ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) ជាទីស្រឡាញ់ បានថ្លែងថា ខ្ញុំគឺជាសាក្សីពិសេសម្នាក់នៃព្រះនាមព្រះយេស៊ូវគ្រីស្ទនៅក្នុងពិភពលោកនេះទាំងមូល ។ ខ្ញុំពុំគួរធ្វេសប្រហែសចំពោះការទទួលខុសត្រូវនេះឡើយ ។ ខ្ញុំបានពិចារណាបទគម្ពីរដែលប្រាប់អំពីព្រះអម្ចាស់តាមព្រះនាម និងងាររបស់ទ្រង់ ។ អ្វីៗទាំងអស់នេះដែលខ្ញុំនឹងចែកចាយដល់បងប្អូនគឺមកពីបទគម្ពីរ ដែលរំឭកយើងអំពីក្ដីសង្ឃឹមរបស់យើងចំពោះទ្រង់ ។

ទ្រង់គឺជា ទីសង្ឃឹមនៃសាសន៍អ៊ីស្រាអែល ( យេរេមា ១៧:១៣ ) ផ្កាយព្រឹកដ៏ភ្លឺចិញ្ចែង ( វិវរណៈ ២២:១៦ ) អ្នកគង្វាលល្អ ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៥០:៤៤ ) ព្រះដ៏ជួយគំនិត ( អេសាយ ៩:៦; នីហ្វៃទី២ ១៩:៦ ) ម្ចាស់នៃមេត្រីភាព ( អេសាយ ៩:៦; នីហ្វៃទី២ ១៩:៦) ព្រះដ៏ប្រោសឲ្យរួច ( រ៉ូម ១១:២៦ ) ពន្លឺលោកីយ៍ ( យ៉ូហាន ៨:១២ ) និង សម្ដេចសង្ឃខាងឯសេចក្ដីល្អដែលត្រូវមក ( ហេព្រើរ ៩:១១ ) ។ ទ្រង់មានឫទ្ធិនឹងសង្គ្រោះ ( អាលម៉ា ៣៤:១៨; គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៣:៤៧ ) និងជា អ្នកដែលមានអស់ទាំងព្រះចេស្ដា ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៦១:១ ) ។

ឥទ្ធិពលរបស់ព្រះគ្រីស្ទគឺហ៊ុមព័ទ្ធទាំងស្រុង ។ ទ្រង់គង់នៅទីនោះ នៅពេលយើងពុះពារ និងព្យាយាមដើម្បីដើរឆ្ពោះទៅមុខ ។ ហើយបើយើងរអិលដួល « ពន្លឺរបស់ទ្រង់ដែលបំភ្លឺនៅក្នុងទីងងឹត » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៦:២១ ) គឺកាន់តែភ្លឺឡើង ។ ទ្រង់ស្រឡាញ់យើងទាំងនៅពេលល្អ និងពេលអាក្រក់របស់យើង ។

ការធ្វើជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ គឺពុំមែនជាការស្មានទេ ។ ផ្លូវរបស់ទ្រង់ត្រូវបានគូសយ៉ាងល្អដោយដានព្រះបាទារបស់ទ្រង់ ។ នៅពេលយើងធ្វើតាមទ្រង់ យើងកាន់តែស្រឡាញ់អ្វីដែលទ្រង់ស្រឡាញ់ ។ នៅពេលយើងរំឭកសេចក្ដីសញ្ញារបស់យើងជាមួយទ្រង់រាល់សប្ដាហ៍ ដោយការទទួលទានសាក្រាម៉ង់ដ៏បរិសុទ្ធ នោះយើងចម្រើននៅ ក្នុងការយល់ដឹងអំពីទ្រង់ ជាព្រះប្រោសលោះនៃពិភពលោក ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:៩ ) ព្រះវិញ្ញាណនៃសេចក្ដីពិត ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:៩ ) និងនៃពិភពលោក ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:៨ ) ។

មិត្តជាទីស្រឡាញ់ នោះគឺជាព្រះអង្គសង្គ្រោះដែលខ្ញុំស្គាល់ ដែលខ្ញុំស្រឡាញ់ ហើយគោរពអស់ពីដួងចិត្ត ។ ចេញពីជម្រៅនៃព្រលឹងខ្ញុំ ខ្ញុំសូមថ្លែងទីបន្ទាល់អំពីទ្រង់ និងសេចក្ដីល្អ និងក្ដីមេត្តាករុណារបស់ទ្រង់ ។ ទ្រង់បានសន្យាថា « ដ្បិតអ្នកជាមិត្តរបស់យើង ហើយអ្នករាល់គ្នាមានកេរមរតកនៅជាមួយនឹងយើងដែរ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:៤៥ ) ។

ព្រះយេស៊ូវគ្រីស្ទតែងតែឆ្លើយតបដល់បញ្ហា និងឧបសគ្គទាំងឡាយ ដែលជាផ្នែកនៃបទពិសោធន៍នៃជីវិតរមែងស្លាប់ ។ ពេលយល់ដឹងអំពីបេសកកម្ម និងដំណឹងល្អរបស់ទ្រង់ ក្ដីស្រឡាញ់របស់យើងចំពោះទ្រង់ ព្រមទាំងជំនឿរបស់យើង និងការពឹងផ្អែកទៅលើទ្រង់ ផ្ដល់ជាកម្លាំងដល់យើង ។ ■

*ដកស្រង់ចេញពី ល្ងាចមួយជាមួយអ្នកមានសិទ្ធិអំណាចទូទៅ ការចាក់ផ្សាយសម្រាប់គ្រូអប់រំខាងសាសនា ដែលបានធ្វើឡើងនៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៩ ។*

# បងរបស់យ៉ារេឌ



**បានដឹកនាំគ្រួសារ និងមិត្តភក្តិរបស់គាត់**
ពីប៉មនៃក្រុងបាបិលទៅកាន់ដែនដីសន្យា ។



បានសង់កេត្រាទាំងឡាយដើម្បី
**ឆ្លងមហាសមុទ្រ ។**





បានទូលសូមដល់ព្រះអម្ចាស់ឲ្យប៉ះគ្រួស ១៦ ដុំ ដើម្បី
**បំភ្លឺកេត្រា ។**



បានឃើញ**ការនិមិត្តដ៏មហស្ចារ្យ**មួយ ដែលបានកត់ត្រាទុកនៅក្នុងផ្នែកដែលបានបិទទុកនៃផ្ទាំងទាំងឡាយ ( សូមមើល អេធើរ ៤:៤–៥ ) ។



**« ជាបុរសម្នាក់មាឌធំ ហើយខ្លាំងពូកែ**
ហើយជាបុរសម្នាក់ដ៏សំណប់ជាខ្លាំងនៃព្រះអម្ចាស់ »
( អេធើរ ១:៣៤ ) ។



បាននិយាយជាមួយនឹងព្រះយេស៊ូវគ្រីស្ទ
**ដោយផ្ទាល់**
( សូមមើល អេធើរ ៣:១៣–២០ ) ។

រូបក្រដាសកាត់ដោយ ហ្គេល អាមស្ត្រុង រូបភាពបន្ទាត់ដោយ ខេធី ដក់ហ្សៀល

### យុវមជ្ឈិមវ័យ

*តើបងប្អូន ឬនរណាម្នាក់ដែលបងប្អូនស្គាល់*
*មានការលំបាកនឹងការញៀនដែរឬទេ ?*
*មានសេចក្ដីសង្ឃឹមសម្រាប់ការផ្លាស់ប្ដូរ ។*

ទំព័រ ៤៤



កុមារ និងយុវវ័យ

ការការពារ និងការជាសះស្បើយពីការរំលោភបំពាន

ទំព័រ ៥៨
ឧ១២

យុវវ័យ

សុខភាពផ្លូវចិត្ត និងអ្នកត្រៀមធ្វើអ្នកផ្សព្វផ្សាយសាសនា

ទំព័រ ៦៣

ឪពុកម្ដាយ

ការបង្រៀនអំពីជង្ហាយមួយភាគក្នុងដប់

ទំព័រ ឧ១៦,
ឧ១៨

## មកដល់នៅឆ្នាំក្រោយ

*ទស្សនាវដ្ដីសាសនាចក្រ*
*សម្រាប់យុវវ័យ និងកុមារ !*
*សូមចុចជាវឥឡូវនេះនៅហាង*
*ChurchofJesusChrist.org ឬនៅ*
*មជ្ឈមណ្ឌលចែកចាយ ។*

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02167 25258 0

# ប្រិយមិត្ត

ខែ តុលា ឆ្នាំ ២០២០

វគ្គរបស់កុមារនៅក្នុងទស្សនាវដ្ដី *លីអាហូណា* ដែលបោះពុម្ពដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



ព្រះយេស៊ូវបានយាងទៅជួបកុមារ
នៅក្នុងព្រះគម្ពីរមរមន

សូមមើលទំព័រ ខ២០–២២

សារលិខិតគណៈប្រធានទីមួយ



ដោយប្រធាន
ដាល្លិន អេក អូក
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# ពិធីសាក្រាម៉ង់ និងខ្ញុំ

សាក្រាម៉ង់គឺជាផ្នែកដ៏សំខាន់បំផុតនៃ នៃការប្រជុំសាក្រាម៉ង់ ។ នៅពេលយើងទទួលទានសាក្រាម៉ង់ យើងសន្យាថានឹងចងចាំព្រះនាមរបស់ព្រះអង្គសង្គ្រោះជានិច្ច ។ ដើម្បីធ្វើឲ្យសាក្រាម៉ង់ពិសេស យើង



ស្លៀកពាក់ដើម្បីបង្ហាញថា យើងគោរពដល់សាក្រាម៉ង់ ។



អង្គុយដោយស្ងៀមស្ងាត់មុនការប្រជុំចាប់ផ្ដើម ។



ច្រៀងទំនុកតម្កើងសាក្រាម៉ង់ ។



គិតអំពីព្រះយេស៊ូវ ហើយសន្យាថាចងចាំទ្រង់ជានិច្ច ។

ពិធីសាក្រាម៉ង់ជួយយើងឲ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។ វាជួយយើងឲ្យបន្តនៅលើផ្លូវត្រឡប់ទៅកាន់ដំណាក់សួគ៌ារបស់យើងវិញ ។●

*កែសម្រួលមកពី ដាល្លិន អេក អូក* « Sacrament Meeting and the Sacrament » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ១៧–២០ ។

# បង្ហាញសេចក្ដីស្រឡាញ់ដល់ព្រះយេស៊ូវ

យើងអាចបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវ ដោយការមានគារវភាព
អំឡុងពេលពិធីសាក្រាម៉ង់ ។ តើបងប្អូនធ្វើអ្វីខ្លះអំឡុងពេលពិធីសាក្រាម៉ង់ ?



អង្គុយដោយស្ងៀមស្ងាត់ ។



គិតអំពីទំនុកតម្កើងសាក្រាម៉ង់ដែលខ្ញុំចូលចិត្ត ។



គិតដល់រឿងមួយអំពីព្រះយេស៊ូវ ។



អធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ។

រចនារូបភាពដោយ ដូលៀន ឡូ

ខាលីគ្រាន់តែចង់បានមិត្តម្នាក់ប៉ុណ្ណោះ ។

# អាហារថ្ងៃត្រង់ដ៏ឯកោ

ដោយ ស្តេស៊ី លីន ឃៃរ៉ូល
( ផ្អែកទៅលើដំណើររឿងពិត )

« *ព្រះវិញ្ញាណបរិសុទ្ធខ្សឹបដោយសំឡេងតូចរហៀង* »
( សៀវភៅចម្រៀងកុមារ *ទំព័រ ៥៦* ) ។

ខាលីបានដើរទៅបន្ទប់អាហារ ហើយមើលជុំវិញ ។ ក្មេងៗផ្សេងទៀតទាំងអស់រត់តម្រង់ទៅមិត្តភក្តិរបស់ពួកគេ ហើយបានប្រមូលផ្តុំគ្នានៅតុ ។ បន្ទប់នោះអ៊ូអរដោយមានសម្លេងរំភើប និងសំណើចដ៏រីករាយ ។ វាទើបតែជាថ្ងៃទីពីរនៅសាលា ប៉ុន្តែវាហាក់ដូចជាគ្រប់គ្នាមាននរណាម្នាក់ដើម្បីអង្គុយជាមួយរួចទៅហើយ លើកលែងតែខាលី ។

នាងបានច្របាច់ដៃកាបូបអាហាររបស់នាង ហើយបានដើរទៅកាន់តុមួយ ។ « តើខ្ញុំអាចអង្គុយនៅក្បែរឯងបានទេ ? » ខាលីបានសួរ ។

ក្មេងស្រីម្នាក់មានសក់ក្រងវែងពណ៌ត្នោតបានសម្លឹងមើលមក ។ នាងបានច្រឡេត ហើយគ្រវីក្បាលរបស់នាង ។ នាងបាននិយាយថា « អត់ទេ ។ មានអ្នកអង្គុយហើយ » ។

« មិនអីទេ ! » ខាលីបានខិតទៅកន្លែងអង្គុយទំនេរមួយទៀត ហើយបានអង្គុយចុះជាមួយនឹងកាបូបអាហាររបស់នាង ។

« ឯងមិនអាចអង្គុយទីនេះបានទេ ! « ខ្ញុំទុកកន្លែងអង្គុយហ្នឹងហើយ » ក្មេងប្រុសម្នាក់ពាក់អាវផ្ទុតពណ៌បៃតងបាននិយាយ ។ គេបានរុញកាបូបអាហាររបស់ខាលីទៅក្រោម ។ មិត្តគេទាំងអស់គ្នាបានសើច ។

ខាលីបានឱនចុះទៅរើសកាបូបអាហាររបស់នាងម្តងទៀត ។ នាងបានដើរទៅផ្នែកម្ខាងទៀតនៃបន្ទប់អាហារ ហើយអង្គុយនៅនឹងតុទំនេរមួយ ។ នាងបានឃើញក្មេងម្នាក់មកពីសហគមន៍នាង ហើយបានព្យាយាមគ្រវីដៃ ប៉ុន្តែគេបានសម្លឹងទៅម្ខាងទៀត ។ ខាលីបានជ្រួញចិញ្ចើម ។ ហេតុអ្វីគ្មាននរណាម្នាក់ចង់ធ្វើជាមិត្តរបស់នាង ?

ខាលីបានឈ្ងោកមុខមើលទៅស្បែកជើងរបស់នាង ។ នាងមិនមានអារម្មណ៍ចង់ញ៉ាំទៀតទេ ។ នាងបានជូតភ្នែកនាង បិទកាបូបអាហាររបស់នាង ហើយបានដើរទៅខាងក្រៅ ។

គ្រប់គ្នាកំពុងលេងជាមួយមិត្តភក្តិពួកគេទៅហើយ ។ ខាលីបានអង្គុយតែម្នាក់ឯងនៅលើកៅអីវែង ហើយបានមើលក្មេងផ្សេងទៀតលេងសប្បាយដោយគ្មានរូបនាង ។





បន្ទាប់មកខាលីបានសម្គាល់ឃើញក្មេងប្រុសម្នាក់អាយុប្រហែលនាង កំពុងអង្គុយម្នាក់ឯងនៅលើស្មៅ ។ គេពាក់អាវដែលមានស្នាមប្រឡាក់ពណ៌លឿង ហើយសក់គេបះទៅក្រោយ ។

ខាលីបានបែរមុខចេញ ។ នាងបានឃើញក្មេងស្រីមួយក្រុមមកពីថ្នាក់នាងកំពុងលេងបោះបាល់ទៅវិញទៅមក ។ នាងពិតជាចង់ឲ្យពួកគេអញ្ជើញនាងឲ្យលេងជាមួយពួកគេណាស់ ។

ខាលីបានក្រឡេកមើលទៅក្មេងប្រុសនោះម្តងទៀត ។ គេឱនក្បាលចុះ ហើយកំពុងបោចស្មៅនៅនឹងជើងរបស់គេ ។ ខាលីបានចងចាំពីអ្វីមួយដែលម្តាយនាងបាននិយាយនៅពេលខ្លះ ៖ *រកមើលក្មេងៗដែលឯកោ* ។

ខាលីបានជ្រួញចិញ្ចើម ។ *នាង*ក៏ឯកោដែរ ។ គ្មាននរណាម្នាក់ព្យាយាមធ្វើជាមិត្ត*របស់នាង*ទេ !

ប៉ុន្តែ បន្ទាប់មកខាលីបានគិតអំពីពេលដែលនាងបានទទួលបុណ្យជ្រមុជទឹកកាលពីឆ្នាំមុន ។ នាងបានសន្យាថានឹងស្តាប់ព្រះវិញ្ញាណបរិសុទ្ធ ។ ប្រហែលជាព្រះវិញ្ញាណបរិសុទ្ធបានជួយនាងឲ្យចងចាំនូវអ្វីដែលម្តាយនាងបានប្រាប់ ។ ប្រហែលជាព្រះវិញ្ញាណបរិសុទ្ធកំពុងព្យាយាមប្រាប់នាងឲ្យលេងជាមួយក្មេងប្រុសពាក់អាវពណ៌លឿងនោះ ។

ខាលីដកដង្ហើមធំ ហើយបានក្រោកឈរឡើង ។ អារម្មណ៍ដ៏កក់ក្តៅមួយជ្រាបក្នុងចិត្តរបស់នាង ។ នាងបានដើរទៅ ហើយបានអង្គុយជិតក្មេងប្រុសនោះនៅលើស្មៅ ។

នាងបាននិយាយថា « សួស្តី » ។

គាត់បាននិយាយរហឹមៗតបវិញថា « សួស្តី » ។

« តើឯងចូលចិត្តពណ៌អ្វីជាងគេ ? »

« អើ . . .បៃតង » ។

ខាលីបាននិយាយថា « ល្អណាស់ ។ ខ្ញុំចូលចិត្តពណ៌ផ្កាឈូក » ។ « តើឯងមានសត្វមួយដែលឯងចូលចិត្តទេ ? »

ក្មេងប្រុសនោះបានតម្រង់ខ្លួនបន្តិច ហើយបានសម្លឹងមើលនាង ។ « មែនហើយ ។ ខ្ញុំចូលចិត្តសត្វដាយណូស័រណាស់ » ។

« អូ ខ្ញុំក៏អញ្ចឹងដែរ ។ ខ្ញុំចូលចិត្តត្រៃសេរ៉ាថបស៍ជាងគេ » ។

ក្មេងប្រុសនោះបានញញឹម ។

ហើយកណ្តឹងក៏បានរោទ៍ឡើង ។ ខាលីបានក្រោកឈរឡើង ហើយបានគ្រវីដៃលាទៅក្មេងប្រុសនោះ ។ នាងបានញញឹម កាលដែលនាងបានដើរត្រឡប់ទៅថ្នាក់រៀននាងវិញតែម្នាក់ឯង ។ នាងអាចនឹងមិនមានមិត្តល្អបំផុតម្នាក់ ប៉ុន្តែនាងបានមានអារម្មណ៍សប្បាយរីករាយ ដោយដឹងថា នាងបានធ្វើឲ្យម៉ោងចេញលេងរបស់មនុស្សម្នាក់បានប្រសើរឡើងបន្តិច ។●

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា.* ។





ខ្ញុំប្រញាប់ទៅសាលា ។ ប៉ុន្តែ ខ្ញុំបានមានអារម្មណ៍ថា ខ្ញុំគួរតែយកដំឡូងចៀនមួយកញ្ចប់ពីផ្ទះសិន ។ បន្ទាប់ពីអាហារថ្ងៃត្រង់ហើយ ឌ្រូ មិត្តរបស់ខ្ញុំមើលទៅដូចជាសោកសៅ ។ ខ្ញុំបានសួរគាត់ថាតើមានរឿងអ្វី ។ គាត់បានប្រាប់ថា គាត់ភ្លេចយកអាហារថ្ងៃត្រង់របស់គាត់មក ។ ខ្ញុំនឹកឃើញពីដំឡូងចៀនរបស់ខ្ញុំ ដូច្នេះខ្ញុំបានឲ្យទៅគាត់ ។ ឌ្រូបាននិយាយថា « នោះជារឿងដ៏ល្អបំផុតដែលមនុស្សម្នាក់បានធ្វើសម្រាប់ខ្ញុំនៅសាលា » ។

ឡាំ អិម អាយុ ១១ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា




# សួស្ដីមកពីប្រទេសម៉ាដាហ្គាស្ការ !



**ប្រទេសម៉ាដាហ្គាស្ការ** ជាកោះមួយនៅឆ្នេរសមុទ្រខាងកើតនៃទ្វីបអាហ្វ្រិក ។ វាមានរុក្ខជាតិ និងសត្វជាច្រើន ដែលមិនមាននៅទីកន្លែងណាទៀតនៅលើពិភពលោកនេះ—ដូចជាសត្វលិម័រដែលមានរង្វង់កង់ៗនៅកន្ទុយបែបនេះ !



ក្មេងប្រុសទាំងនេះកំពុងជួយអូសទឹកក្នុងក្នុងរទេះសម្រាប់គ្រួសាររបស់ពួកគេ ។ តើបងប្អូនជួយគ្រួសារបងប្អូនដោយរបៀបណា ?





សាសនាចក្រគឺតូចនៅក្នុងប្រទេសម៉ាដាហ្គាស្ការ ប៉ុន្តែវាកំពុងតែរីកចម្រើន ។ ឥឡូវនេះមានវួដចំនួន ១៤ និង ២៦ សាខានៅទីនោះ ។



មានសត្វសណ្ដានបង្គួយឈ្មោះខាមៀលលានជាច្រើនប្រភេទរស់នៅប្រទេសម៉ាដាហ្គាស្ការជាងនៅប្រទេសណាផ្សេងទៀតទាំងអស់នៅក្នុងពិភពលោក !

## សូមជួបជាមួយមិត្តភក្តិមួយចំនួនរបស់យើងមកពីប្រទេសម៉ាដាហ្គាស្ការ !



ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់យើង ។

ណាថាន អាយុ ៧ ឆ្នាំ ខេត្តអានតាណាណារីវ៉ូ ប្រទេសម៉ាដាហ្គាស្ការ



ប្រធាន រ័សុល អិម ណិលសុន គឺពិតជាព្យាការីរបស់ព្រះ ។

ណូមេណា អាយុ ៦ ឆ្នាំ ខេត្តអានតាណាណារីវ៉ូ ប្រទេសម៉ាដាហ្គាស្ការ



ដើមព្រាលដ៏ធំទាំងនេះអាចផ្ទុកទឹកជាច្រើននៅក្នុងដើមរបស់វា—រហូតដល់ ១២០០០០ លីត្រឯណោះ !



មនុស្សជាច្រើននៅប្រទេសម៉ាដាហ្គាស្ការទទួលទានបាយពីរ ឬបីដងក្នុងមួយថ្ងៃជួនកាលជាមួយបន្លែ សណ្ដែក ឬជាមួយសាច់ ។

តើបងប្អូនមកពីប្រទេសម៉ាដាហ្គាស្ការឬ ?
សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូនៗ ។




រចនារូបភាពដោយ ខាធី ម៉ាក់ឌី

ពាក្យម៉ាដាហ្គាស៊ីសម្រាប់ « ប្រិយមិត្ត » គឺ *namana* ។ ប្រសិនបើបងប្អូនអាចជួបនឹងមិត្តម្នាក់នៅក្នុងប្រទេសម៉ាដាហ្គាស្ការ តើបងប្អូននឹងប្រាប់អ្វីដល់គេ ?





# ហ្វានៅ៉ា ជាអ្នកផ្សព្វផ្សាយសាសនា

ដោយ ម៉ារីស្សា វីដឌីសុន
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

ហ្វានៅ៉ាបានសម្លឹងទៅក្រៅបង្អួចទៅផ្លូវដ៏រវល់នៅខាងក្រៅផ្ទះរបស់គាត់ ។ គាត់អាចឃើញមនុស្សម្នាទាញរទេះបន្លែ អង្ករ សំលៀកបំពាក់ និងទំនិញផ្សេងៗទៀតដើម្បីលក់ ។ គាត់អាចឮសុីភ្លេនឡាន និងឆ្កែព្រុស ។ បន្ទាប់មកគាត់បានឮសំឡេងមួយ ។

« ម៉ាម៉ា មាននរណាម្នាក់កំពុងគោះទ្វារ ! » ហ្វានៅ៉ាបានស្រែកប្រាប់ ។ ម៉ាម៉ាបានបើកទ្វារ ។ យុវជនពីរនាក់ពាក់អាវធំ និងក្រវ៉ាត់ក នៅឯមាត់ទ្វារ ។ ហ្វានៅ៉ាមិនដែលបានឃើញនរណាម្នាក់ស្លៀកពាក់បែបនោះនៅក្នុងភូមិរបស់គាត់នៅក្នុងប្រទេសម៉ាដាហ្គាស្ការពីមុនមកឡើយ ។

ម្នាក់បាននិយាយថា « ពួកយើងជាអ្នកផ្សព្វផ្សាយសាសនាមកពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។ « យើងបង្រៀនមនុស្សអំពីព្រះយេស៊ូវ ។ តើយើងអាចចែកចាយសារមួយជាមួយនឹងបងបានទេ ? »

ហ្វានៅ៉ារំភើបចិត្តពេលម៉ាម៉ាបានអញ្ជើញពួកគេឲ្យចូលក្នុង ។ គ្រួសារទាំងមូលបានប្រមូលផ្ដុំគ្នា ដើម្បីស្ដាប់អំពីព្រះយេស៊ូវគ្រីស្ទ និងរបៀបដែលសាសនាចក្ររបស់ទ្រង់បានមានលើផែនដីម្ដងទៀត ។

បន្ទាប់ពីថ្ងៃនោះមក ពួកអ្នកផ្សព្វផ្សាយសាសនាបានមកជួបគ្រួសាររបស់ហ្វានៅ៉ាជាច្រើនដង ។ ពួកគេបានយកសៀវភៅមួយមកហៅថា *ដំណើររឿងព្រះគម្ពីរមរមន* ។ ហ្វានៅ៉ាចូលចិត្តអានវាជាមួយគ្រួសារគាត់ !

ហ្វានៅ៉ាបាននិយាយទៅកាន់ខ្លួនឯង *ថ្ងៃមួយខ្ញុំនឹងធ្វើជាអ្នកផ្សព្វផ្សាយ*

*សាសនា ហើយចែកចាយព្រះគម្ពីរមរមនជាមួយមនុស្ស ផ្សេងទៀត* ។



នៅពេលផ្សេងទៀត ពេលដែលពួកអ្នកផ្សព្វផ្សាយសាសនាបានមក ពួកគេបានបង្រៀនគ្រួសារហ្វានៅអំពីរបៀបអធិស្ឋាន ។ ហ្វានៅបានរៀនថា គាត់អាចនិយាយទៅកាន់ព្រះវរបិតាសួគ៌គ្រប់ពេល គ្រប់ទីកន្លែង ។

ហ្វានៅបានគិតថា *ថ្ងៃមួយខ្ញុំនឹងធ្វើជាអ្នកផ្សព្វផ្សាយសាសនា ហើយបង្រៀនមនុស្សអំពីការអធិស្ឋាន* ។



ថ្ងៃមួយពួកអ្នកផ្សព្វផ្សាយសាសនាបានមានសំនួរដ៏សំខាន់មួយ ។

អ្នកផ្សព្វផ្សាយម្នាក់បានសួរថា « តើបងប្អូននឹងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ហើយទទួលបុណ្យជ្រមុជទឹកដែរឬទេ ? »

ហ្វានៅមានអារម្មណ៍សប្បាយ នៅក្នុងចិត្តគាត់ ។ គាត់បានឆ្លើយថា « បាទ ! »

បងប្រុស និងម៉ាម៉ាគាត់បាននិយាយថា « បាទ និងចាស៎ ! »

ប៉ាប៉ាបាននិយាយថា គាត់មិនទាន់រួចរាល់ដើម្បីទទួលបុណ្យជ្រមុជទឹកនៅឡើយទេ ។ ប៉ុន្តែ គាត់យល់ស្របបើគ្រប់គ្នានៅក្នុងគ្រួសារទទួលបុណ្យជ្រមុជទឹក ។ ដូច្នេះ ពួកគាត់ទទួលបុណ្យជ្រមុជទឹក ! ហ្វានៅបានទទួលបុណ្យជ្រមុជទឹកដោយអ្នកផ្សព្វផ្សាយសាសនាម្នាក់ដែលបានបង្រៀនគាត់អំពីព្រះយេស៊ូវ ។



ហ្វានៅបានគិតថា *ថ្ងៃមួយខ្ញុំនឹងធ្វើជាអ្នកផ្សព្វផ្សាយសាសនា ហើយជួយមនុស្សឲ្យទទួលបុណ្យជ្រមុជទឹក* ។

ផ្នែកដ៏ល្អបំផុតមួយនៃការធ្វើជាសមាជិករបស់សាសនាចក្រគឺការទៅថ្នាក់កុមារ ។ ហ្វានៅចូលចិត្តសកម្មភាពនានា និងការជួបមិត្តថ្មី ។ ប៉ុន្តែ អ្វីដែលគាត់ចូលចិត្តជាងគេទាំងអស់ គឺការច្រៀងចម្រៀងកុមារ ។ នៅថ្ងៃអាទិត្យមួយក្នុងថ្នាក់កុមារ ពួកគេកំពុងច្រៀងចម្រៀងអំពីការចែកចាយដំណឹងល្អ ។

ហ្វានៅបានច្រៀងថា « ខ្ញុំចង់ក្លាយជាអ្នកផ្សាយសាសនាពេលនេះ » ។ « ខ្ញុំមិនចង់រង់ចាំរហូតធំឡើងឡើយ » ។

ហ្វានៅបានដឹងថា *ខ្ញុំអាចចាប់ផ្ដើមធ្វើជាអ្នកផ្សព្វផ្សាយសាសនាឥឡូវនេះ* ។ *ខ្ញុំពុំចាំបាច់រង់ចាំរហូតដល់ថ្ងៃមួយនោះទេ !*

តាំងពីពេលនោះមក ហ្វានៅបានស្វែងរករបៀបនានាដែលគាត់អាចចែកចាយដំណឹងល្អ ។ គាត់បានព្យាយាមធ្វើជាគំរូល្អ ។ គាត់បានអញ្ជើញមនុស្សឲ្យមកព្រះវិហារ ។ គាត់បានជួយអ្នកជិតខាងរបស់គាត់ ។ ប៉ុន្មានឆ្នាំក្រោយមក គាត់ធំគ្រប់គ្រាន់ដើម្បីជួយដល់ពួកអ្នកផ្សព្វផ្សាយសាសនាដើម្បីបង្រៀនមនុស្សនៅក្នុងទីក្រុងរបស់គាត់ ។ នៅតែប៉ុន្មានឆ្នាំទៀត គាត់បានបម្រើបេសកកម្មមួយខ្លួនឯង—ជួបនឹងមនុស្សថ្មី។ និងចែកចាយដំណឹងល្អ គឺដូចជាពួកអ្នកផ្សព្វផ្សាយសាសនាបានចែកចាយជាមួយគាត់ដែរ ។●



ហ្វានៅនិយាយថា « ខ្ញុំចូលចិត្តចំណាយពេលជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ជាជាងធ្វើអ្វីៗផ្សេងទៀត » ។ គាត់ត្រូវបានហៅឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅក្នុងប្រទេសកំណើតរបស់គាត់ គឺប្រទេសម៉ាដាហ្គាស្ការ ។



ប្អូនៗអាចនឹងមិនឃើញ**ពួកទេវតា** ប៉ុន្តែពួកទេវតា
នឹងនៅទីនោះដើម្បី**ជួយដល់ប្អូនៗ ។**

កែសម្រួលពីប្រធាន អែសរ៉ា ថាហ្វ បែនសឹន ( ១៨៩៩–១៩៩៤ ) « To the Children of the Church » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨៩ ទំព័រ ៨៣ ។

គំនូរដោយ

# កម្មវិធីបង្ហាញ ហើយនិទានប្រាប់

សន្និសីទទូទៅគឺនៅខែនេះហើយ ! នេះជាអ្វីដែលកុមារមួយចំនួនបានរីករាយអំពីសន្និសីទ ។



អ៊ីសាប៊ែលឡា ប៊ី អាយុ ៥ ឆ្នាំ ទីក្រុងហ្គូតេម៉ាឡា
ប្រទេសហ្គូតេម៉ាឡា



អ៊ិលស៊ី អាយុ ៥ ឆ្នាំ ទីក្រុង ន្យូ លេអន
ប្រទេស ម៉ិកស៊ិកូ




កាព្រីយ៉េល អេហ្វ អាយុ ១០ ឆ្នាំ ទីក្រុង មីណាស
ហ្គើរេស ប្រទេសប្រេស៊ីល



**សេលិម ហូសស្វេ មែ និងរូធ ស៊ី អាយុ ៥, ៨, ៦ និង ៣ ឆ្នាំ ទីក្រុង ឌូរ៉ាងហ្គោ ប្រទេសម៉ិកស៊ិកូ** រីករាយនឹងការមើលសន្និសីទទូទៅនៅផ្ទះ ។ វាជាសន្និសីទដ៏ពិសេសមួយ !



ខ្ញុំចូលចិត្តតន្ត្រីរបស់ក្រុមចម្រៀងរោងឧបោសថ ។ ខ្ញុំតែងតែមានអារម្មណ៍សុខសាន្ត ។ សូមអរគុណ

**យ៉ារេដ ប៊ី អាយុ ៧ ឆ្នាំ តំបន់ណាម៉ានឌី ប្រទេសបារាំង**



ពេលខ្ញុំបានមើលសន្និសីទទូទៅ ខ្ញុំបានរៀនពីរបៀបដែល យ៉ូសែប ស៊្មីធ បានបកប្រែព្រះគម្ពីរមរមន ដើម្បីយើងមានព្រះបន្ទូលនៃព្រះ ។ ព្រះគម្ពីរមរមនបង្រៀនខ្ញុំអំពីព្រះយេស៊ូវគ្រីស្ទ ។

**សាលូម អេ អាយុ ៦ ឆ្នាំ តំបន់ដាការ ប្រទេសសេណេហ្គាល់**



**អែនណោលេ រូធ សារ៉ា និងសាមីរ៉ា យេ អាយុ ៨ឆ្នាំ, ២ឆ្នាំ, ៦ខែ និង ៦ឆ្នាំ ទីក្រុងលីតតូរ៉ាល់ ប្រទេសបេណាំង** ចូលចិត្តមើលសន្និសីទជាមួយគ្នាជាគ្រួសារ ។

BACKGROUND FROM GETTY IMAGES

# និយាយថាទេ ឮថាទេ

ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ ហើយមានព្រះទ័យចង់ឲ្យខ្ញុំមានសុវត្ថិភាព ! ការនិយាយថា ទេ ពេលយើងត្រូវការនិយាយបែបនោះ និងការគោរពដល់អ្នកដទៃទៀត ពេលពួកគេប្រាប់យើងថា ទេ ជារបៀបដែលយើងអាចរក្សាខ្លួនយើង និងអ្នកដទៃទៀតឲ្យមានសុវត្ថិភាព ។

ជួនកាលប្អូនៗត្រូវនិយាយថា ទេ ក្នុងរបៀបដ៏ល្អមួយ ។



« ទេ សូមអរគុណ ។ តើខ្ញុំសូមទឹកជំនួសវិញបានទេ ? »

ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថា ប្អូនៗត្រូវនិយាយថាទេ ក្នុងរបៀបដ៏ល្អមួយ ។ តើប្អូនអាចនិយាយថាដូចម្ដេច ?

ជួនកាលប្អូនៗត្រូវនិយាយថា ទេ ក្នុងរបៀបដ៏រឹងប៉ឹងមួយ ។



« ខ្ញុំមិនចង់មើលវាទេ ! យើងមិនគួរមើលវាទេ » ។

ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃ
ប្អូនៗត្រូវនិយាយថាទេ ក្នុងរបៀបដ៏រឹង
មួយ ។ តើប្អូនអាចនិយាយថាដូចម្ដេច



ជួនកាលមនុស្សប្រាប់យើងថា ទេ ដើម្បីជួយយើងឲ្យមានសុវត្ថិភាព និងមានសុខភាពល្អ ។

« សូមទោស កូនមិនអាចទៅបានទេ ។ វាមិនមានសុវត្ថិភាពទេ » ។



ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថា មជ្ឈិមវ័យម្នាក់ប្រាប់ប្អូនថា ទេ ហើយប្អូនមិនចូលចិត្តវាទេ ។ តើប្អូនគួរតែធ្វើយ៉ាងដូចម្ដេច ?

ជួនកាលមនុស្សប្រាប់យើងថា ទេ ពេលពួកគេមិនស្រណុកចិត្ត ។



« ឈប់ ! ខ្ញុំពុំចូលចិត្តល្បែងនេះទេ » ។

ឥឡូវ ដល់វេនប្អូនៗហើយ ! សូមស្រមៃថា មនុស្សម្នាក់សុំប្អូនឲ្យឈប់ធ្វើអ្វីមួយ ។ តើប្អូនគួរតែធ្វើយ៉ាងដូចម្ដេច ?

ចុះបើមនុស្សមិនស្ដាប់ ពេលប្អូននិយាយថា ទេ នោះ ? ចុះបើពួកគេធ្វើបាបប្អូន ឬធ្វើអ្វីដែលអាក្រក់នោះ ?

- ★ ដើរចេញបើសិនប្អូនអាចធ្វើបាន ។
- ★ ប្រាប់មជ្ឈិមវ័យម្នាក់ដែលប្អូនទុកចិត្ត អំពីអ្វីដែលបានកើតឡើង ។
- ★ ចូរចាំថា វាមិនមែនជាកំហុសរបស់ប្អូននោះទេ ។
- ★ មិនថាមានអ្វីកើតឡើងទេ សូមដឹងថាព្រះវរបិតាសួគ៌របស់ប្អូន និងព្រះយេស៊ូវគ្រីស្ទតែងតែស្រឡាញ់ប្អូនជានិច្ច ។

# ទូរសព្ទទៅប៉ា

*យូបានគិតថា បើខ្ញុំធាក់កង់ឲ្យខ្លាំង ខ្ញុំអាច ទៅដល់ផ្ទះមុនពេលផ្លូវលេចទឹក ។*



ដោយ ជូលី កូនេសាល ហោង
( ផ្អែកទៅលើដំណើររឿងពិត )
អ្នកនិពន្ធរស់នៅ រដ្ឋ យូថាហ៍ ស. រ. អា ។

*« ចូរសង្ឃឹមឡើង ត្បិតយើងនឹងដឹកនាំអ្នករាល់គ្នា » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៨ ) ។*

យូបានចេញពីសាលារៀនឯកជនទៅលើផ្លូវដ៏អូរអរនោះ ។ ខួរក្បាលគាត់ពេញដោយអង្គហេតុគណិតវិទ្យាពីថ្នាក់បន្ថែមម៉ោងក្រោយសាលាចប់ ។ មនុស្សម្នាបានប្រញាប់ប្រញាល់ជាមួយនឹងឆ័ត្រ ។ ដំណក់ភ្លៀងធំៗធ្លាក់មកឈូៗ ហើយផ្លូវនោះក៏សើមជោក ។

មិត្តរបស់យូ ឈ្មោះលីន បានចេញមកនៅក្បែរគាត់ ។ លីនបាននិយាយថា « ឯងគួរតែទូរសព្ទទៅប៉ាឯងឲ្យមកទទួលឯងទៅ » ។ « លោកស្មៀងនិយាយថា វាមានទឹកជន់នៅផ្នែកខ្លះៗនៃទីក្រុងនេះ » ។

« ខ្ញុំអាចទៅដល់ផ្ទះដោយខ្លួនឯង ! »

« ប៉ុន្តែ មើលទឹកទាំងអស់នោះន៎ ! » លីនបាននិយាយ ដោយចង្អុលទៅទឹកដែលកំពុងហូរយ៉ាងខ្លាំងទៅក្នុងប្រឡាយ ។

យូបានអារម្មណ៍អស់សំណើចមួយសន្ទុះ ។ តើលីននិយាយ

ត្រូវទេ ? ប្រហែលជាគាត់*គួរតែ*ទូរសព្ទទៅប៉ាឲ្យមកយកគាត់ទៅផ្ទះមុនពេលផ្លូវលេចទឹក ។ ប៉ុន្តែគាត់ និងប៉ាទើបឈ្លោះគ្នាកាលពីយប់មិញ ហើយយូនៅខឹងនៅឡើយ ។ គាត់មិនចង់សូមប៉ាឲ្យជួយនោះទេ ។

យូបានដោះច្រវ៉ាក់ចេញពីកង់គាត់ ហើយបាននិយាយលាលីន ។ យូបានគិតថា *បើខ្ញុំធាក់កង់ឲ្យខ្លាំង ខ្ញុំអាចទៅដល់ផ្ទះមុនពេលផ្លូវលេចទឹក* ។

គាត់បានធាក់កង់យ៉ាងខ្លាំង ប៉ុន្តែមិនយូរប៉ុន្មានដៃគាត់ត្រជាក់ សំលៀកបំពាក់គាត់ទទឹកជោក ហើយគាត់អស់កម្លាំង ។ គំនិតឲ្យទូរសព្ទហៅប៉ា បានលេចឡើងម្ដងទៀត ។ តើអារម្មណ៍នេះមកពីព្រះវិញ្ញាណបរិសុទ្ធឬ ? ពួកអ្នកផ្សព្វផ្សាយសាសនាដែលបានជ្រមុជទឹកឲ្យគាត់ បាននិយាយថា ព្រះវិញ្ញាណបរិសុទ្ធអាចជាអ្នកដឹកនាំគាត់ ។ យូបានសម្លឹងមើលមេឃ ។ មេឃងងឹតណាស់ រហូតគាត់មិនអាចមើលឃើញកំពូលអគារទេ ។ ប៉ុន្តែគាត់នៅតែខឹងនឹងប៉ានៅឡើយ ។

យូបានព្រងើយកន្តើយនឹងអារម្មណ៍នោះ ហើយបានបន្តធាក់កង់ទៅទៀត ។ ទឹកបានឡើងខ្ពស់ រហូតដល់ម្ចាស់ហាងទាំងឡាយបានបិទហាងរបស់ពួកគេ ។ មនុស្សបានរើរបស់របរទៅកន្លែងខ្ពស់ ។ យូបានឃើញម្ដាយម្នាក់រុញកូនរបស់គាត់ពីរនាក់កាត់ទឹកជន់នៅក្នុងទូកផ្លាស្ទិចតូចមួយ ។

ឥឡូវនេះដោយទឹកឡើងដល់កជើងគាត់ យូពុំអាចធាក់កង់គាត់បានទៀតទេ ។ គាត់បានចុះពីកង់ ហើបណ្ដើរ ។ វាប្រហែលជាយឺតពេលនឹងទូរសព្ទទៅប៉ាហើយឥឡូវនេះ ហើយភ្លៀងនៅតែធ្លាក់មក ។ ផ្គរលាន់យ៉ាងខ្លាំង ហើយផ្លេកបន្ទោលចាំងឆ្វាចពីលើគាត់ ។ យូមានអារម្មណ៍ភ័យខ្លាច ។ ហើយគាត់ហត់ណាស់ ! គាត់បានមើលទៅមុខ ។ នៅឆ្ងាយទៀតទើបដល់ផ្ទះ ។ គាត់មិនគួរព្រងើយកន្តើយនឹងព្រះវិញ្ញាណបរិសុទ្ធ ដោយព្រោះតែការឈ្លោះដ៏លីលាមួយនោះទេ ។

យូបានឈប់ដើម្បីអធិស្ឋានខ្លីមួយ ។ គាត់មិនអាចឮសំឡេងរបស់គាត់ទេដោយសារតែភ្លៀង និងផ្គរលាន់ ប៉ុន្តែគាត់បានដឹងថា ព្រះវរបិតាសួគ៌អាចឮគាត់ ។

យូបានអធិស្ឋានថា « ព្រះវរបិតាសួគ៌ » ។ « សូមជួយកូនឲ្យទៅដល់ផ្ទះដោយសុវត្ថិភាពផង » ។ ពេលគាត់បានបញ្ចប់ គាត់បានមានអារម្មណ៍ថាមានកម្លាំងគ្រប់គ្រាន់ដើម្បីបន្តទៅមុខទៀត ។

នៅទីបំផុត យូអាចមើលឃើញផ្ទះគាត់ដែលនៅលើទួល ។ ទាំងត្រជាក់អស់កម្លាំង ហើយមិនដឹងថាយ៉ាងណាគាត់បាត់ស្បែកជើងម្ខាង យូបានប្រឹងដើរឡើងទួលនោះទាំងលំបាក ។ គាត់បានឃើញប៉ាចាំគាត់នៅខាងក្រៅ ។ ប៉ាបានប្រញាប់ដើរចុះពីទួលដើម្បីមកជួយគាត់ ទឹកបាចសាចពេលគាត់បានរត់មក ។

ពេលប៉ាមកដល់ គាត់បានឱបយូ ។ « ប៉ាបារម្ភខ្លាំងណាស់! » ប៉ាបាននិយាយ ។ « កូនគួរតែទូរសព្ទមកប៉ា ! »

យូបាននិយាយថា « កូនបានគិតថា យើងខឹងគ្នាទៅវិញទៅមក » ។

ប៉ាបានថា « ប៉ាមិនដែលខឹងកូនរហូតដល់ថ្នាក់មិនជួយកូននោះទេ » ។ បន្ទាប់មក គាត់បានយកកង់របស់យូ ហើយបានរុញវាឡើងទួលរហូតដល់ផ្ទះ ។

ថ្វីបើមានផ្គរលាន់រណ្ដំនៅចន្លោះអគារធំៗ ហើយភ្លៀងធ្លាក់យ៉ាងខ្លាំងក្ដី ក៏យូបានមានអារម្មណ៍កក់ក្ដៅនៅក្នុងចិត្តគាត់ ។ គាត់បានមានអារម្មណ៍សុខសាន្ត និងសុវត្ថិភាព ពេលគាត់ដើរតាមប៉ាទៅផ្ទះ ។ ●



« ព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ជ្រាបដឹងថា នៅក្នុងជីវិតរមែងស្លាប់នេះ យើងនឹងជួបឧបសគ្គ ។ . . . ដើម្បីផ្ដល់ភាពរឹងមាំក្នុងជីវិតរមែងស្លាប់នេះដល់យើង និងផ្ដល់ការណែនាំមកពីព្រះ នោះទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធ » ។

អែលឌើរ រ៉ូណាល អេ រ៉ាសបាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ទុកឲ្យព្រះវិញ្ញាណដឹកនាំ » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៩៣ ។

រូបភាពដោយ ជីន ចាង

# ពេសូដង្វាយមួយភាគក្នុងដប់

ដោយ អាលេន អែវ៉ាន រុស្ស អនធីយូស៍

( ផ្អែកទៅលើដំណើររឿងពិត )




សូហ្វៀបានភ្ញាក់ពីព្រលឹម ។ ថ្ងៃនេះគឺពិសេសណាស់ ។ នាងនឹងលក់ទឹកក្រូចឆ្មារនៅផ្ទះមីង និងពូរបស់នាង ពេលពួកគាត់លក់របស់របរដែលឈប់ប្រើ ។ ម៉ាម៉ាបានធ្វើទឹកក្រូចឆ្មារមួយក្រឡធំសម្រាប់នាង ។

សូហ្វៀបានធ្វើស្លាកមួយ ។ នាងបានសរសេរថា « ទឹកក្រូចឆ្មារ ! »



ដែលមានអក្សរពណ៌ទឹកក្រូច និងពណ៌លឿង ។ នាងបានបិតវាទៅនឹងតុតូចមួយ ។ បន្ទាប់មកនាងបានអង្គុយចុះដើម្បីរង់ចាំ ។

មិនយូរប៉ុន្មានមានបុរសម្នាក់មកដល់ ។ គាត់បានសួរថា « ពូសុំមួយពែងបានទេ ? » គាត់បានដាក់លុយកេសខ្លះក្នុងក្រឡនាង ។

« ចាស៎បាន ! » សូហ្វៀបានតប ។ នាងបានចាក់ទឹកក្រូចឆ្មារមួយពែងឲ្យគាត់ ។

បន្តិចម្តងៗ មនុស្សបានមកមើលការលក់របស់របរ ។ ហើយបន្តិចម្តងៗ ពួកគេបានទិញទឹកក្រូចឆ្មារដ៏ឆ្ងាញ់នោះ ។ ព្រឹកនោះបានកន្លងទៅដោយរីករាយ ។ មិនយូរប៉ុន្មានទឹកក្រូចឆ្មារត្រូវបានលក់អស់រលីង ។

សូហ្វៀបានក្រឡុងក្រឡនាង ។ លុយកេសបន្លឺសូររ៉ឹងៗ ។ នាងបានលុយជាច្រើន !

« ល្អណាស់ ! » ប៉ាប៉ាបាននិយាយ ។

សូហ្វៀមិនដែលមានលុយច្រើនទេពីមុនមក ។ « ខ្ញុំនឹងទិញយ៉ូ-យ៉ូមួយ ! »

ប៉ាប៉ាបានញញឹម ។ « តើកូនដឹងទេថា ម៉ាម៉ា និងប៉ាប៉ាធ្វើអ្វីពេលយើងរកលុយបាន ? »

សូហ្វៀគ្រវីក្បាលនាង ។

ប៉ាប៉ាបាននិយាយថា « យើងបង់ដង្វាយមួយភាគក្នុងដប់ » ។ « ព្រះវរបិតាសួគ៌បានប្រទានអ្វីៗគ្រប់យ៉ាងដល់យើង ។ ទ្រង់ស្នើឲ្យយើងថ្វាយដល់ទ្រង់វិញនូវមួយផ្នែកតូច ។ យើងបង់ដង្វាយមួយភាគក្នុងដប់ ដោយសារយើងស្រឡាញ់ទ្រង់ » ។

សូហ្វៀបានញញឹម ។ នាងចង់បង្ហាញព្រះវរបិតាសួគ៌ថា នាងក៏ស្រឡាញ់ទ្រង់ដែរ ។

ប៉ាប៉ាបានជួយសូហ្វៀរាប់លុយកេសរបស់នាង ។ ពេលណាដែលនាងរាប់ដល់ ១០ នាងដាក់មួយកេសទៅក្នុងស្រោមសំបុត្រ ។ ប៉ាប៉ាបានជួយនាងសរសេរលេខនៅលើក្រដាសពណ៌សតូចមួយ ។ ពួកគេបានដាក់ក្រដាសនោះទៅក្នុងស្រោមសំបុត្រជាមួយនឹងលុយកេស ។ បន្ទាប់មកពួកគេបានបិទវា ។ សូហ្វៀនឹងជូនវាទៅប៊ីស្សពនៅថ្ងៃស្អែកនៅព្រះវិហារ ។

« តើកូនមានអារម្មណ៍បែបណា ? » ប៉ាប៉ាបានសួរសូហ្វៀ ។

« សប្បាយចិត្តណាស់ ! ហើយនៅតែមានលុយសល់សម្រាប់ប្រដាប់លេងយ៉ូ-យ៉ូមួយ ។ » នាងមានអារម្មណ៍ថា ព្រះវរបិតាសួគ៌មានព្រះទ័យរីករាយនឹងជម្រើសរបស់នាង ។●

*អ្នកនិពន្ធរស់នៅរដ្ឋឈីវ៉ាវ៉ា ប្រទេសម៉ិកស៊ិក ។*



# ពេលវេលាដង្វាយមួយភាគក្នុងដប់

ព្រះវរបិតាសួគ៌សុំឲ្យយើងបង់ដង្វាយមួយភាគក្នុងដប់ ។ នោះមានន័យថា ការថ្វាយនូវមួយក្នុងដប់នៃលុយដែលយើងរកបាន ។ ប្អូនៗអាចប្រើប្រាស់ទំព័រនេះដើម្បីអនុវត្តបាន !

រាប់កាក់ ។ ពេលបងប្អូនរាប់ដល់ ១០ ម្ដងៗ សូមផាត់ពណ៌មួយ ។ កាក់ដែលប្អូនៗផាត់ពណ៌ គឺជាកាក់ដែលប្អូនៗនឹងបង់ជាដង្វាយមួយភាគក្នុងដប់ !







ត្រៀមខ្លួនសម្រាប់អ្វីដែលពិបាកជាងនេះបន្តិចហើយឬនៅ ? សូមបូកលុយខាងក្រោមនេះ ។ បន្ទាប់មកផាត់ពណ៌កាក់ប៉ុន្មានដែលប្អូនៗនឹងបង់ជាដង្វាយមួយភាគក្នុងដប់ ។ ( សូមចាំថា រាល់ ១០ កាក់ ប្អូនបង់មួយ ) ។●




រចនារូបភាពដោយ ជូលៀ ឈាវ



# ការចែកចាយដំណឹងល្អ

ដោយអែលឌើរ អែតវីត ឌូប
ក្នុងពួកចិតសិបនាក់

*« រៀននឹងខ្ញុំចុះ . . . នោះអ្នករាល់គ្នានឹងបានសេចក្ដីសម្រាកដល់ព្រលឹង » ( ម៉ាថាយ ១១:២៩ ) ។*

ប្រុសម្នាក់ដែលខ្ញុំបានធ្វើការឲ្យគាត់ បានឲ្យព្រះគម្ពីរមរមនមួយក្បាលដល់ខ្ញុំ ។ ប៉ុន្តែខ្ញុំមិនបានអានវាទេអស់ជិតពីរឆ្នាំ ។ ថ្ងៃអាទិត្យមួយ ខ្ញុំបានយកព្រះគម្ពីរមរមនមក ហើយបានទៅឯផ្លូវរថភ្លើងក្រៅក្រុងដែលខ្ញុំបានរស់នៅក្នុងប្រទេសហ្ស៊ីមបាវេ ។ ខ្ញុំបានអង្គុយចុះ ហើយបានចាប់ផ្ដើមអាន ។

ពីដំបូង វាពិបាកនឹងយល់ ។ ប៉ុន្តែ ខ្ញុំបានអានអំពីទីបន្ទាល់របស់ យ៉ូសែប ស្ម៊ីធ ម្ដងហើយម្ដងទៀត ។ ពាក្យសម្ដីរបស់លោកបានរំជួលចិត្តខ្ញុំ ។

ក្រោយមក មានមនុស្សម្នាក់បានអញ្ជើញខ្ញុំឲ្យទៅព្រះវិហារ ។ ពីដំបូង ខ្ញុំមិនស្រណុកចិត្តទេ ដូច្នេះខ្ញុំបានអង្គុយនៅជួរខាងក្រោយ ។ ប៉ុន្តែពេលមនុស្សម្នាក់បានចាប់ផ្ដើមចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ និងពីព្រះគម្ពីរមរមន ខ្ញុំបានទទួលអារម្មណ៍អស្ចារ្យមួយនៅក្នុងចិត្ត ។

មិនយូរប៉ុន្មានបន្ទាប់ពីនោះ ពួកអ្នកផ្សព្វផ្សាយសាសនាបានមកភូមិរបស់ខ្ញុំ ។ មិនយូរប៉ុន្មាន ខ្ញុំបានទទួលបុណ្យជ្រមុជទឹក ។ ប៉ុន្មានឆ្នាំក្រោយមក ខ្ញុំបានមានកិត្តិយសបម្រើបេសកកម្មមួយ ហើយចែកចាយដំណឹងល្អជាមួយមនុស្សផ្សេងទៀតជាច្រើន ។

សាសនាចក្របានលូតលាស់យ៉ាងច្រើននៅក្នុងប្រទេសហ្ស៊ីមបាវេ ។ ប៉ុន្តែនៅតែមានអ្វីៗជាច្រើន ដែលយើងអាចធ្វើបានដើម្បីចែកចាយដំណឹងល្អ មិនថាយើងរស់នៅទីណានោះទេ ។ តាមរយៈការអធិស្ឋាន ការសិក្សាព្រះគម្ពីរ និងរាត្រីជួបជុំគ្រួសារ បងប្អូនអាចពង្រីកទីបន្ទាល់របស់បងប្អូន ហើយបន្តនៅជិតព្រះវរបិតាសួគ៌ ។ ទីបន្ទាល់របស់បងប្អូនអាចផ្ដល់ពរជ័យដល់ជីវិតមនុស្សជាច្រើននៅទូទាំងពិភពលោកនេះ ។●

# មនុស្សស្មោះត្រង់ដើរតាមព្រះយេស៊ូវ



ពេលព្រះយេស៊ូវបានយាងមកជួបនឹងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ទ្រង់បានបង្រៀនពួកគេអំពីបុណ្យជ្រមុជទឹក និងរបៀបដើម្បីទទួលសាក្រាម៉ង់ ។



ព្រះយេស៊ូវបានប្រទានពរដល់កុមារតូចៗ ។ ពួកទេវតាបានយាងមក ! ព្រះយេស៊ូវបានប្រោសព្យាបាលប្រជាជន ហើយបានអធិស្ឋានសម្រាប់ពួកគេ ។ បន្ទាប់មកទ្រង់បានយាងទៅស្ថានសួគ៌វិញ ។



បន្ទាប់ពីព្រះយេស៊ូវបានយាងចេញទៅ ប្រជាជនបន្តធ្វើអ្វីដែលទ្រង់បានបង្រៀន ។ មនុស្សគ្រប់គ្នាបានធ្វើការជាមួយគ្នា ហើយបានចែកចាយអ្វីដែលពួកគេមាន ដូច្នេះគ្មាននរណាម្នាក់ក្រីក្រឡើយ ។ ថ្នាក់ដឹកនាំសាសនាចក្របានប្រសិទ្ធពរដល់ពួកអ្នកឈឺ ។



ជាជាងការឈ្លោះប្រកែកគ្នា ប្រជាជនបានជ្រើសរើសដើម្បីស្រុះស្រួលគ្នាវិញ ។ គ្រប់គ្នាបានធ្វើតាមបទបញ្ញត្តិរបស់ព្រះ ។ ហើយពួកគេបានរីករាយអស់រយៈពេលជាយូរ !

រចនារូបភាពដោយ អាបរីល ស្កុត



ជីវិតរបស់ខ្ញុំនឹងកាន់តែរីករាយ ពេលខ្ញុំធ្វើតាមបទបញ្ញត្តិរបស់ព្រះ ។
ខ្ញុំអាចចែកចាយអ្វីដែលខ្ញុំមានជាមួយអ្នកដទៃ ។ ខ្ញុំអាចជួយមនុស្សឲ្យស្រុះស្រួលគ្នា ។●

*រៀនអំពីការណ៍នេះនៅក្នុង នីហ្វៃទី៣ ១៧ ដល់ នីហ្វៃទី៤ ១ ។*

# ប្រជាជនបានរស់នៅដោយរីករាយ



តើប្អូនៗអាចធ្វើអ្វីខ្លះដើម្បីជួយគ្រួសារប្អូនឲ្យបានរីករាយ ?

រចនារូបភាពដោយ អាព្រីល ស្តុត

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ជូនចំពោះមាតាបិតា

កុមារម្នាក់ៗគប្បីត្រូវបានការពារ និងថែទាំ ។ ព្រះយេស៊ូវបានផ្តល់ជាគំរូអំពីការណ៍នេះនៅក្នុងព្រះគម្ពីរមរមន ដោយបានប្រទានពរ និងអធិស្ឋានសម្រាប់ក្មេងៗម្នាក់ៗ ( សូមមើល ទំព័រ ខ២០–២៣ ) ។ តើយើងអាចផ្តល់ពរ និងការពារកុមារៗដែលយើងស្គាល់ដោយរបៀបណា ? ទាំងនេះគឺជាយោបល់មួយចំនួន ៖

- យើងអាចការពារពួកគេខាងរាងកាយ ហើយបង្រៀនពួកគេឲ្យគោរពដល់រាងកាយរបស់មនុស្សផ្សេងទៀត ( សូមមើល ទំព័រ ខ១២–១៣ ) ។
- យើងអាចការពារពួកគេខាងវិញ្ញាណ ដោយការលើកទឹកចិត្តពួកគេឲ្យទទួលទានសាក្រាម៉ង់ ( សូមមើល ទំព័រ ខ២–៣ ) ។
- យើងអាចបង្រៀនពួកគេឲ្យសូមជំនួយ ពេលពួកគេត្រូវការវា ( សូមមើល ទំព័រ ខ១៤–១៥ ) ។

បងប្អូនអាចជ្រើសរើសសារមួយក្នុងចំណោមសារទាំងនេះដើម្បីអានជាមួយគ្នាជាគ្រួសារ ។ សូមប្រាកដថា កូនៗរបស់បងប្អូនដឹងថា បងប្អូនស្រឡាញ់ពួកគេខ្លាំងប៉ុណ្ណា !

យើងស្រឡាញ់បងប្អូន ។

ទស្សនាវដ្តី *ប្រិយមិត្ត*

**សូមផ្ញើរបតំនូរ ឬបទពិសោធន៍នានារបស់កូនបងប្អូនមកកាន់ទស្សនាវដ្តី *លីអាហូណា***

សូមចូលទៅ liahona.ChurchofJesusChrist.org ហើយចុចលើ « Submit an Article or Feedback » ។ ឬអ៊ីម៉ែលវាមកកាន់យើងតាម liahona@ChurchofJesusChrist.org ដោយដាក់ឈ្មោះ អាយុកូនរបស់បងប្អូន ទីក្រុង ព្រមទាំងសេចក្តីថ្លែងការណ៍អនុញ្ញាតនេះ ៖ « ខ្ញុំ [ សរសេរឈ្មោះរបស់បងប្អូន ] ផ្តល់ការអនុញ្ញាតដល់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយប្រើប្រាស់ការដាក់បញ្ជូនរបស់កូនខ្ញុំនៅក្នុងទស្សនាវដ្តីសាសនាចក្រ នៅលើគេហទំព័រសាសនាចក្រ និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ព្រមទាំងអាចមាននៅក្នុងសម្ភារសាសនាចក្រផ្សេងទៀត » ។ ពួកយើងទន្ទឹងរង់ចាំពីបងប្អូន !

មាតិកា


ខ២ មកពីគណៈប្រធានទីមួយ ៖ ពិធីសាក្រាម៉ង់ និងខ្ញុំ
ខ៤ អាហារថ្ងៃត្រង់ដ៏ឯកោ
ខ៦ សួស្តីមកពីប្រទេសម៉ាដាហ្គាស្ការ !
ខ៨ ហ្វានៅរ៉ា ជាអ្នកផ្សព្វផ្សាយសាសនា
ខ១០ គំនិតឆ្លាតវៃ
ខ១១ កម្មវិធីបង្ហាញ ហើយនិទានប្រាប់
ខ១២ និយាយថាទេ ឮថាទេ
ខ១៤ ទូរសព្ទទៅប៉ា
ខ១៦ ភេសូជង្វាយមួយភាគក្នុងដប់
ខ១៨ គ្រឿងកំសាន្ត ៖ ពេលវេលាដង្វាយមួយភាគក្នុងដប់
ខ១៩ មិត្តចំពោះមិត្ត ៖ ការចែកចាយដំណឹងល្អ
ខ២០ រឿងក្នុងព្រះគម្ពីរ ៖ មនុស្សស្មោះត្រង់ដើរតាមព្រះយេស៊ូវ
ខ២៣ ទំព័រផាត់ពណ៌ ៖ ប្រជាជនបានរស់នៅដោយរីករាយ




សូមស្វែងរករូបលីអាហូណាដែលលាក់នៅខាងក្នុង !

នៅលើក្របទស្សនាវដ្តី *ប្រិយមិត្ត*
រចនារូបភាពដោយ ជីម មេដសិន

© 2020 by Intellectual Reserve, Inc. All rights reserved.

CAMBODIAN
4 02167 25258 0